

# ហត់ជីវិត

(ដោយឧបាសក ម៉ិញ សាវ៉ាន)

គេហដ្ឋាន អភិរក្សមរតកព្រះពុទ្ធសាសនាខ្មែរ
ក្រុងម៉ុងរេអាល - កេបិក - កាណាដា
ព.ស. ២៥៦៧ - គ.ស. ២០២៤

**សម្រាប់ចែកជាធម្មទាន**

# មាគ៌ាជីវិត

## បទពាក្យ ៧

មាគ៌ាត្រូវទៅជ្រៅបំផុត　　កាត់ព្យុះសមុទ្រក្នុងភពត្រៃ
តាមផ្លូវកើតស្លាប់យ៉ាប់យ៉ាកក្រៃ　　ច្រើនអសង្ខេយ្យក្នុងសង្សារ ។
មាគ៌ាជីវិតវៀចវិលវង់　　កើតងាប់ជាប់ផង់វង់តណ្ហា
ឡើងចុះឡុងចុងក្នុងលោកា　　ហេតុចាញ់ចេស្ដាកិលេសបី ។
មាគ៌ាជីវិតវែងបាត់ត្រើយ　　មើលមិនឃើញឡើយហួសមេឃដី
កើតស្លួចរលត់ជាប្រក្រតី　　បន្តវិថីក្នុងវដ្ដៈ ។
មាគ៌ាជីវិតពិតអាចខ្លី　　បើជនប្រុសស្រីភក្ដីស្ម័គ្រ
ត្រៃសិក្ខហ្វឹកហាត់កាត់ច្រវាក់　　ខ្ទាស់សង្សារចក្របំបាក់កង ។
រៀនបរិយត្តិបំបាត់ឆោត　　បដិបត្តិផ្ដោតពិសោធល្បង
ឃើញច្បាស់ខ្លួនឯងលែងសៅហ្មង　　យូរឆាប់អាចឆ្លងបុថុជ្ជន ។
ដល់នាមាគ៌ាអរិយៈ　　សទ្ធាជឿជាក់ព្រះពុទ្ធមន្ត
ចិត្តជាកណ្ដាលមិនស្រាលធ្ងន់　　មិនស្ពឹកស្រពន់ធន់លត់ដំ ។
ញាណទស្សនៈ[១]ក៏កើតមាន　　យកព្រះនិព្វានជាអារម្មណ៍
ឃើញសច្ចៈ ៤ ឥតបន្លំ　　កើតជនឧត្ដមគោត្រភូ [២]... ៕

(ដោយឧបាសក ហ៊ុំម ឆាន់)

---

១- ញាណទស្សនៈ = ប្រាជ្ញាដែលដឹង ដែលឃើញនូវសេចក្ដីពិត
២- គោត្រភូ = បុគ្គលដែលមានប្រាជ្ញខ្ពស់ជិតនឹងបានលុះសោតាបត្តិមគ្គ

សម្រាប់ចែកជាធម្មទាន

# មាគ៌ាជីវិត

## សៀវភៅជាស្នាដៃរបស់ឧបាសក ម៉ិញ សាវ៉ាន ៖

- កំណាព្យ ស្រណោះដីខ្មែរ
- ជីវិត និងវ័យ
- កំណាព្យ នាវាជីវិត
- មរណកថា
- ឧបនិស្ស័យ
- ជីវិតកថា
- ធម្មទ្វេស ៤ យ៉ាង
- ភ័យបីប្រការ
- ចំណងដៃឆ្នាំថ្មី
- គុណមាតាបិតា
- មាគ៌ាជីវិត

# មាគ៌ាជីវិត

រៀបរៀងដោយ

ឧបាសក មិុញ សាវ៉ាន

កំណាព្យ ហុិម ឆាន់

ចម្លង-រចនា វ៉ាត ភិរក្ស

រចនាគ្របគញ្ញា វ៉ាត ទារីយា

ផ្សព្វផ្សាយដោយ

គេហដ្ឋាន
**អភិរក្សមរតកព្រះពុទ្ធសាសនាខ្មែរ**


មិុញ សាវ៉ាន / ហុិម ឆាន់ / វ៉ាត ភិរក្ស

ក្រុងម៉ុងរេអាល - កេបិក - កាណាដា

ព.ស. ២៥៦៧ - គ.ស. ២០២៤

# សៀវភៅចាស់ដែលបានចម្លងជាថ្មី ៖

១. ស្នាព្រះហស្តក្រោយបង្អស់នៃសម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត**
២. ធម៌នមស្ការព្រះរតនត្រ័យ ពិស្តារ - សង្ខេប ( វ៉ាត ភិរក្ស ) ថ្មី
៣. ប្រស្នា គិហិប្រតិបត្តិពិស្តារ ( ឈឹម ទូច, សុង ស៊ីវ )
៤. ប្រជុំនានាធម៌សង្វេគ ( ជ័យ ម៉ៃ )
៥. អានាបាណស្សតិកម្មដ្ឋាន វិបស្សនាបញ្ហាធម្មបរិយាយ ( គង់ ឌីប )
៦. ធម្មនិយាម ៣០ និងកំណាព្យផ្សេង ៗ ( ប៊ុត សាវង្ស, ភិក្ខុ សាន សុជា )
៧. ជីវិតកថា ( ម៉ិញ សារ៉ាន ) ថ្មី
៨. ធម្មប្រទីប ( ប្រជុំកងធម៌ យិន វន់ )
៩. រឿង ព្រះភិក្ខុពនេចរ ( ឱម ណាគ្រី )
១០. រឿង នគរកាយ ( ចាប ពិន )
១១. ច្បាប់គោរពមាតាបិតា ( អ៊ូ ចុង )
១២. នត្ថិធម្មាធិប្បាយ ( ព្រះបិដកធម្ម អ៊ុម ស៊ុម )
១៣. ត្រៃកូដធម៌ ( សុង ស៊ីវ )
១៤. ឱវាទបាតិមោក្ខ ( ចាប ពិន )
១៥. កម្រងកំណាព្យ ( ហ៊ុម ឆាន់ ) ថ្មី
១៦. ឧបនីយតិសូត្រ ( ព្រះមហាវីរិយបណ្ឌិតោ ប៉ាង ខាត់ )
១៧. ធម្មទ្វេស ៤ យ៉ាង ( ម៉ិញ សារ៉ាន ) ថ្មី
១៨. ធម៌នមស្ការសម្រាប់យុវវ័យ Khmère – Français ( វ៉ាត ភិរក្ស ) ថ្មី
១៩. ធម៌នមស្ការសម្រាប់យុវវ័យ Khmère – Anglais ( វ៉ាត ភិរក្ស ) ថ្មី
២០. លោកនីតិបករណ៍ ( ព្រះ អ៊ុក ជា វជិរញ្ញាណាភយវង្ស )
២១. អធិប្បាយមង្គលសូត្រ ( ព្រះវិន័យធរ អនុគណ ឯក ញឹម ធម្មិស្សរោ )
២២. កម្រងកំណាព្យ ទី ២ ( ហ៊ុម ឆាន់ ) ថ្មី
២៣. ព្រះបាទឡាត់ឃោសនាគ ហែម ចៀវ ( គង់ សម្ការ )
២៤. ចំណងដៃឆ្នាំថ្មី ( ម៉ិញ សារ៉ាន ) ថ្មី
២៥. ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាសង្ខេប (សម្តេចហួត តាត)
២៦. ឱវាទ ៤ «ខ» របស់លោក លៀវ ហ្វាន (បកប្រែដោយលោកយាយ ចំរើន ចារូន)
២៧. គុណមាតាបិតា ( ម៉ិញ សារ៉ាន ) ថ្មី
២៨. ទស្សនៈសម្តេចព្រះសង្ឃរាជ ជួន ណាត (គង់ សម្ការ )
២៩. អភិធម្មបរមត្ថសង្ខេប (ព្រះគ្រូ. យ៉ាង ផាន់ និង ព្រះមហា. អ៊ុមប៊ុណ្ណ)
៣០. កម្រងកំណាព្យ ភាគទី ៣ ( ហ៊ុម ឆាន់ ) ថ្មី
៣១. រឿង ព្រះភិក្ខុពនេចរ ភាគ ២ ( ធម្មឃោស - ចំរើន ចារូន )
៣២. អ្នករូតវាំងននសង្គម ( បណ្ឌិត កែម ឡី )
៣៣. រឿង ព្រះភិក្ខុពនេចរ ភាគ ៣ ( ធម្មឃោស - ចំរើន ចារូន )
៣៤. ចតុរារិយសច្ចធម៌ ( ប៉ុស ឆេងអ៊ាង )
៣៥. កម្រងកំណាព្យ ភាគទី ៤ ( ហ៊ុម ឆាន់ ) ថ្មី
៣៦. បដិបត្តិធម៌ គឺការអភិវឌ្ឍជីវិត ( ភិក្ខុ ឃឿន សំណាង ) ថ្មី
៣៧. កើតទៀតឬទេ ? ( ព្រះមហាវីរិយបណ្ឌិតោ ប៉ាង ខាត់ )
៣៨. ឃើញធម៌ ឃើញព្រះ ( ភិក្ខុ ឃឿន សំណាង ) ថ្មី
៣៩. ១០ ឆ្នាំប៉ុន្មានដង ( ភិក្ខុ ហ៊ុម គីមសត់ ) ថ្មី
៤០. វិបរិណាមធម៌ ( ហ៊ុម ឆាន់ ) ថ្មី
៤១. សំណោរបច្ចឹមវ័យ ( ហ៊ុម ឆាន់ ) ថ្មី
៤២. ឧបនិស្ស័យ (ម៉ិញ សារ៉ាន)

# មាតិកាធម៌


០១- អារម្ភកថា........................................................ vii

០២- ឧទ្ទិសកថា ...................................................... ១១

០៣- ជីវប្រវត្តិសង្ខេប .............................................. ១៣

០៤- នមស្ការសំវេជនីយដ្ឋាន.......................................... ១៧

០៥- តួនាទីជាពុទ្ធសាសនិក........................................... ១៩

០៦- វិចារណកថា កាលវេលា និងជីវិត............................ ២១

០៧- អាហារសម្រាប់ជីវិត.............................................. ២៣

០៨- ភព ឬសង្សារវដ្ត កំណត់មិនបាន............................ ២៥

០៩- អ្វីដែលកន្លងផុតទៅ មិនអាចត្រឡប់វិញ.................... ២៧

១០- ជីវិត និងធម៌ ...................................................... ៣១

១១- តម្រូវការសម្រាប់ជីវិត ........................................... ៤១

១២- គោលដៅនៃព្រះពុទ្ធសាសនា................................ ៤៧

១៣- គេអាចសម្គាល់និញ្វានបានដូចម្តេច?........................ ៥៣

១៤- អត្ថន័យបន្ថែម .................................................. ៦៧

១៥- គោលដៅរបស់ជីវិតពិត......................................... ៧៧

១៦- យោធាជីវបីប្រការ .............................................. ៨៣

១៧- សាកល្បងសន្ទនាគ្នា ............................................ ៨៩

១៨- អវសានកថា........................................................ ១០៧

១៩- ហេតុបួនយ៉ាងនៃមរណៈ ........................................ ១០៩
២០- សារៈសំខាន់នៅនាទីចុងក្រោយ.............................. ១១៥
២១- ទស្សនៈដែលត្រឹមត្រូវ ........................................ ១១៩
២២- មតិបញ្ចប់ ........................................................ ១២១
២៣- សមាសភាពចូលរួម ............................................ ១២៥
២៤- ឯកសារពិគ្រោះ .................................................. ១២៧
២៥- នាមសប្បុរសជន ................................................ ១២៩

*សុខទុក្ខវិលដូចកង់រទេះ មិនអាចគេចវេះអ្វីមកដល់*
*បើទទួលបានក្សាន្តជាផល បើចិត្តកង្វល់ខ្វល់ខ្លោចផ្សា។*
*ទុក្ខ ១២ កងចងចាប់ដាប់ ឱ្យរស់ក្លេចងាប់ផ្គាប់តណ្ហា*
*មិនគ្រប់មិនគ្រាន់ព្រោះប្រាថ្នា ដល់ពេលមរណាដែនទេ៕*

ដោយឧបាសក ហ៊ិម ឆាន់

# អារម្ភកថា

ពំនោលរបស់ព្រះអរហន្ត ជាសាវករបស់ព្រះសាស្ដាសម្មាសម្ពុទ្ធ « កាលទាំងឡាយ ដើរទៅដូចមានជើង រាត្រីទាំងឡាយហើរផ្លូងទៅដូចមានស្លាប វ័យគឺអាយុរបស់សត្វទាំងឡាយ លះបង់ចោលជីវិតទៅបន្តិចម្តងៗ ហាក់ដូចជាមានសេចក្តីស្អប់ខ្ពើម » ។

ដោយការសន្មតិ កាលវេលាពិតជាកន្លងផុតទៅមែន អ្វីដែលនៅសល់គឺ « សញ្ញា » ការចងចាំខ្លះ និងការភ្លាំងភ្លេចស្រពេចស្រពិលទៅវិញខ្លះ តែប៉ុណ្ណោះ ។ មកដល់កាលនេះ វេលានេះ (ខ្ញុំព្រះករុណាខ្ញុំបាទបានឈានចូលវ័យចិតសិបប្រាំមួយ (៧៦) ឆ្នាំហើយ បើគិតទៅតាមសាមញ្ញភាសា វោហារការសន្ទនាគ្នា អាចពោលថា ខ្ញុំព្រះករុណាខ្ញុំបាទរស់នៅបានចិតសិបប្រាំមួយឆ្នាំ ឬថាខ្ញុំព្រះករុណា ខ្ញុំបាទមានអាយុចិតសិបប្រាំមួយឆ្នាំហើយ តែបើពោលទៅតាមធម្ម-ភាសា បានន័យថា កាលវេលានៃការរស់នៅរបស់ខ្ញុំព្រះករុណា ខ្ញុំបាទបានអស់ទៅចិតសិបប្រាំមួយឆ្នាំ និងកំពុងតែបន្តការអស់ទៅ គ្រប់ពេលគ្រប់ខណៈ រហូតដល់ទៅគ្មានអ្វីសេសសល់នៅឱ្យអស់តទៅទៀត ក៏គឺការបញ្ចប់នៃការរស់នៅរបស់ជីវិតនេះឯង ។ អ្វីៗ ដែលជាអតីតកាលបានកន្លងផុតទៅ បន្សល់ទុកនៅតែការស្រមើស្រមៃ ព្រមទាំងការគិតរបស់ចិត្ត និងសញ្ញាការចងចាំ របស់ចេតសិកតែប៉ុណ្ណោះ។

គ្រប់តែជីវិត អ្វីៗ ដែលបានព្យាយាម ប្រឹងប្រែង អន្ទះអន្ទែង ខំរកឱ្យបាន បំពេញឱ្យមាន ក៏បានត្រឹមតែចិត្តប្រកាន់នឹក នៅទីបំផុតអ្វីៗទាំងអស់នោះ ត្រូវបានរលាយរលត់ វិនាសប្រាសព្រាត់ទៅ នៅពេល

ដែលជីវិតនេះ ត្រូវបញ្ចប់អស់ទៅក្នុងមួយជាតិៗ (ជាតិក្ខយមរណៈ) ។

ការពោលដូច្នេះ ពុំមែនបានន័យថា ពញ្ញាក់បំបាក់ស្មារតីយប់ថ្ងៃឱ្យរាថយក្នុងដំណើរជីវិតនោះទេ ពំនោលនេះ គឺជាការបញ្ជាក់ពីសភាវៈពិតរបស់ជីវិតជាទូទៅ និងធ្វើឱ្យមានការទទួលយល់ដឹងនូវអ្វីជាសភាវៈពិតរបស់ជីវិត និងបានឈោងយកជាទីពឹង ពិតប្រាកដច្បាស់លាស់ មានគោលដៅជាក់លាក់ក្នុងដំណើរជីវិត ដែលកំពុងតែប្រព្រឹត្តទៅ ទោះបីក្នុងកាលវេលាជារយៈវែងក្តី ខ្លីក្តី ក្នុងន័យថា ជីវិតនេះត្រូវចេះយល់ព្រម និងរកដំណោះស្រាយ ចំពោះបញ្ហាដែលកើតមានចំពោះជីវិតនេះ ដោយពឹងទៅលើការព្យាយាម តស៊ូអំណត់ធន់ហាត់អានរៀនស្តាប់ ត្រង់ត្រាប់ពិចារណាតាមពន្លឺនៃបញ្ញា បានផ្តុះបញ្ចាំងគោលដៅមួយដ៏ពិតប្រាកដសម្រាប់ជីវិត ។

រយៈកាលវេលានៃការអស់ទៅ ចិតសិបប្រាំ (៧៥) ឆ្នាំរបស់ខ្ញុំព្រះករុណា ខ្ញុំបាទ ប្រាកដជាច្រើនពេកហើយ ចំណែកកាលវេលានៃការរស់នៅទៅខាងមុខទៀតនោះ ពិតជាពុំបានច្រើន ឬវែងឆ្ងាយតទៅទៀតឡើយ ព្រោះជីវិត គឺការរស់នៅរបស់សព្វសត្វទាំងឡាយ គ្មានអ្នកណាម្នាក់អាចកំណត់ដឹងបាន ។ ជីវិតនេះតិចផង លំបាកផង ត្រូវសេចក្តីទុក្ខគ្របសង្កត់ផង ត្រូវសត្រូវបៀតបៀនជានិច្ចផង មានសត្រូវរួបរឹតជានិច្ចផង ឯការកន្លងទៅនៃកាលវេលា គឺទិវារាត្រីពុំបានឈ្មោះថា កន្លងទៅទទេៗ នោះឡើយ ។ អាស្រ័យដូចបានពោលមកនេះ ទើបធ្វើឱ្យខ្ញុំមានការព្យាយាម បន្តការសរសេរបញ្ចប់ និងរចនាសៀវភៅនេះឱ្យបានសម្រេចឡើង ពីព្រោះអត្ថបទក្នុងសៀវភៅនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ បានចាប់ផ្តើមសរសេរតាំងពីឆ្នាំ ២០១៩ មកម្ល៉េះលុះចូលដល់ដើមឆ្នាំ ២០២០, ដោយមានរោគកូវីដកំណាច បាន

រាគត្បាតទូទាំងសកលពិភពលោកផង បន្ថែមទាំងបន្ទុកមួយទៀតគឺ ឧបាសិកា **សឹម ចាន់ធូរ៉ា** ជាភរិយា ខ្ញុំព្រះករុណា ខ្ញុំបាទ ត្រូវ រោគាពាធបៀតបៀនរាងកាយ កាន់តែធ្ងន់ធ្ងរឡើងទៀតផងនោះ ទើប ឱ្យខ្ញុំព្រះករុណា ខ្ញុំបាទ បានបោះបង់សំណេរនេះចោល អស់មួយរយៈ កាល ។ លុះមកដល់ថ្ងៃទី ២៦ ខែ ១១ ឆ្នាំ ២០២២, ភរិយារបស់ខ្ញុំព្រះ ករុណា ខ្ញុំបាទ គាត់បានលាចាកលោកនេះទៅ បន្សល់ទុកនៅភាព សង្វេគ ដក់ជិតជាប់ក្នុងដួងចិត្តរបស់ខ្ញុំដោយពុំអាចពិពណ៌នាបាន ។ នៅថ្ងៃអាទិត្យ ទី ៤ ខែ ធ្នូ ឆ្នាំ ២០២២ ជាថ្ងៃដែលបានបំពេញបុណ្យ ទក្ខិណានុប្បទាន ឧទ្ទិសជូនឧបាសិកា **សឹម ចាន់ធូរ៉ា**, ធ្វើឱ្យខ្ញុំព្រះ ករុណា ខ្ញុំបាទ មានបីតិរីករាយរំភើបចិត្តឥតឧបមា ដោយបានឃើញ ព្រះវត្តមានព្រះករុណាព្រះគុណម្ចាស់ ព្រមទាំងបងប្អូន កូនចៅ ញាតិ មិត្តសាច់សាលោហិតទាំងអស់កុះករគ្រេកអរសាទរ ចូលរួមក្នុងការ បំពេញបុណ្យជាមួយនឹងយើងខ្ញុំព្រះករុណា ខ្ញុំបាទ ដោយចិត្តមេត្តា ករុណា ប្រោសប្រណី ។ សន្តានចិត្ត ទឹកព្រះទ័យដ៏ល្អបវរប្រពៃនេះ ហើយ ធ្វើឱ្យខ្ញុំព្រះករុណា ខ្ញុំបាទបានកត់ត្រា ចងចាំទុកក្នុងជម្រៅដួង ចិត្តពុំអាចបំភ្លេចបាន ។ ក្រោយពីបានបញ្ចប់កិច្ចបំពេញបុណ្យមក ខ្ញុំ ព្រះករុណាខ្ញុំបាទ តែងមានការគិតថា តើខ្ញុំបាទអាចមានអ្វីហ្ន៎ ដើម្បី តបស្នងសងព្រះគុណព្រះករុណា ព្រះគុណម្ចាស់ ព្រមទាំងញាតិមិត្ត សាច់សាលោហិត ទាំងអស់ឱ្យបានប្រពៃវិញ ។ ដោយការសង្វេគពី សភាវៈពិតរបស់ជីវិតផង និងដោយការជ្រះថ្លាចំពោះទឹកព្រះទ័យរបស់ ព្រះករុណាព្រះគុណម្ចាស់ផង ព្រមទាំងទឹកចិត្តដែលជាបុណ្យ ជា គុណរបស់សាធុសប្បុរសទាំងអស់គ្នាផង ព្រមទាំងការជំរុញឱ្យកម្លាំង ចិត្តពីប្អូន **ទ៉ាត តិរក្សា**, បានប្រាប់ខ្ញុំឱ្យសរសេរបញ្ចប់ នឹងអាលបាន

រចនាឱ្យកើតបានជាសៀវភៅ ទុកសម្រាប់ប្រគេនចែកជូនជាធម្មទាន ព្រោះឃើញថា អត្ថន័យខ្លឹមសារអាចទទួលយកបាន ។ ទើបធ្វើឱ្យជាកម្លាំងរុញច្រាន ចិត្តខ្ញុំឱ្យខិតខំព្យាយាម សរសេរបន្តឡើងវិញ រហូតបានដល់បញ្ចប់សព្វសេចក្ដីដើម្បីបានជាបណ្ណាការ អាហាររបស់ចិត្ត និងបានជាផ្នត់គំនិតក្នុងការត្រិះរិះពិចារណា តាមអត្ថន័យនៃព្រះធម៌ បង្កើតបានជាទុនបណ្ដុះគុណគឺបញ្ញា បំពេញនៅធម្មាហារ ការសប្បាយខាងផ្លូវចិត្ត ដ្បិតមានព្រះធម៌ជាអាហារ ឬជាអារម្មណ៍របស់ចិត្តតាមសមគួរដល់ការហាត់អាន រៀនទន្ទេញនោះ ។

អត្ថន័យក្នុងសៀវភៅនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ បានព្យាយាមសរសេរជាពាក្យសម្រាយដោយច្រើន ពុំបានសរសេរបាលីគាថា ជាមគធៈភាសាដែលជាព្រះពុទ្ធដីកា ក្នុងពុទ្ធសម័យនោះទេ ដោយមានបំណងចង់ឱ្យលោក-អ្នកអានទាំងឡាយ បានងាយស្រួលក្នុងការអាន និងបានចាប់សេចក្ដី យល់អត្ថន័យខ្លះៗ ពីសៀវភៅនេះ ។

ទន្ទឹមជាមួយគ្នានេះដែរ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមទានព្រះករុណា ព្រះគុណម្ចាស់ ព្រមទាំងលោក-អ្នកទាំងឡាយ ដែលជាពហុស្សូត មេត្តាអភ័យនៅរាល់ទោសកំហុសឆ្គងទាំងពួង ដោយអចេតនា និងសូមមេត្តាប្រោសប្រណី ជួយកែតម្រូវនូវពាក្យពេចន៍ ព្យញ្ជនៈ អក្ខរៈ វគ្គឃ្លា ទាំងឡាយណាដែលមិនត្រឹមត្រូវ តម្រូវឱ្យបានសមរម្យ ដើម្បីទុកជាគុណ ជាប្រយោជន៍ក្នុងព្រះពុទ្ធសាសនាផង ក្នុងគោលបំណងប៉ងរក្សាការពារ អរិយធម៌ វប្បធម៌ អក្សរសាស្ត្រជាតិ ឱ្យបានគង់វង្សជាស្ថាពរតទៅ អស់កាលជាយូរអង្វែង ។

ឧបាសក **ម៉ិញ សាវ៉ាន**

# ឧទ្ទិសគថា

យើងខ្ញុំព្រះករុណា ជាបច្ឆាជន សូមលំអុតលំអោនកាយគោរព ថ្វាយបង្គំ ចំពោះលោកអ្នកប្រាជ្ញ រាជបណ្ឌិត អត្ថកោវិទ កវីនិពន្ធ គ្រប់ជំនាន់សម័យដែលតាំងនៅក្នុងភេទជាព្រះសង្ឃក្តី ជាគ្រហស្ថក្តី ដែលបានលាចាកលោកនេះទៅហើយក្តី ទាំងមានជីវិតស្ថិតនៅសព្វថ្ងៃនេះក្តី ដោយសេចក្តីគោរព ដ៏ឧត្តមខ្ពង់ខ្ពស់ក្រៃលែងជាទីបំផុត ។

ព្រះគុណដ៏មហាសាលនៃលោកអ្នកប្រាជ្ញ ជាបុព្វបុរសទាំងអស់នោះ បានធ្វើពលីកម្មបូជា កម្លាំងកាយ កម្លាំងស្មារតី យប់ថ្ងៃ ដើម្បីបូរណភាព ទឹកដី អរិយធម៌ វប្បធម៌ អក្សរសាស្ត្រ ភាសាជាតិ ឱ្យបានឋិតថេរចីរកាល ជារៀងដរាបមក ទុកជាសញ្ញាណជាតិតំណាដល់កូនចៅគ្រប់ជំនាន់ ។ ព្រះគុណដ៏ធំធេង ពុំអាចកាត់តម្លៃបាននេះ រមែងហូរជ្រួតជ្រាប ចូលក្នុងដួងហឫទ័យ និងបានដាស់តឿនក្រើនរំលឹកស្មារតីនៃយើងខ្ញុំ (ថាសូមកុំឱ្យភ្លេចជាតិមាតុភូមិ ចូររួមចងបាច់គ្នាជាផ្លូងមួយ លើកស្ទួយថែរក្សាការពារ មាតុប្រទេសព្រមទាំងអ្វីៗ ជាអរិយធម៌ វប្បធម៌ជាតិ ទុកឱ្យបានគង់វង្សជាស្ថាពរ ជានិរន្តរកាលតរៀងទៅ) ។ ពាក្យពេចន៍ដ៏សែនពីរោះរណ្តំ បានបន្លឺជាសូរសៀងរងំប្រគំជាប់ ជានិច្ចក្នុងសោតប្រសាទនៃយើងខ្ញុំជាកុលបុត្រ កុលធីតា ជាបច្ឆាជនគ្រប់ជំនាន់ ដែលពុំអាចបំភ្លេចបាន ។

យើងខ្ញុំព្រះករុណា ខ្ញុំបាទ សូមលើកហត្ថប្រណម្យ ផ្គុំប្រម

ទាំងដប់ តាំងចិត្តផ្ចិតយកនូវគុណប្រយោជន៍ណា ជាមហាកុសល ដែលយើងខ្ញុំព្រះករុណាទាំងអស់គ្នា បានបំពេញធ្វើហើយ ប្រកប ដោយចេតនា ជ្រះថ្លាតាមទ្វារកាយ វាចា ចិត្ត ឧទ្ទិសផ្សាយ ថ្វាយ ប្រគេន ជូន ចំពោះលោកអ្នកដ៏មានគុណទាំងឡាយនោះ មានមាតា បិតា គ្រូឧបជ្ឈាយាចារ្យ ព្រះករុណា ព្រះគុណម្ចាស់ រាជបណ្ឌិត អត្ថកោវិទ កវីនិពន្ធគ្រប់ជំនាន់ ព្រមទាំងបងប្អូនញាតិមិត្ត សាច់-សាលោហិត រួមទាំងសព្វសត្វគ្រប់ប្រភេទ ក្នុងសង្សារវដ្តនេះ សូមឱ្យ មានដំណើរជីវិតប្រព្រឹត្តទៅប្រកបដោយសេចក្តីសុខ ក្សេមគ្រប់ៗ ជាតិ កុំបីឃ្លៀងឃ្លាតជាបការៈដទៃឡើយ និងសូមឱ្យមានបញ្ញាស្មារតី ជា ពន្លឺសម្រាប់ជីវិតបច្ចុប្បន្ន សម្រេចជោគជ័យក្នុងការសិក្សា ប្រកប ការងារ ជាសម្មាជីវៈ នឹងបានចម្លងនាវាជីវិតនេះ ឱ្យមានដំណើរទៅ កាន់ត្រើយនៃអមតៈ សមតាមសេចក្តីប្រាថ្នា និងការកសាងសន្សំបារមី កុំបីខានឡើយ ។

**ម៉ិញ សាវ៉ាន / ហ៊ិម ឆាន់ / វ៉ាត តិរគៀ**

សូមអនុមោទនា! សូមអនុមោទនា! សូមអនុមោទនា!

*សូមញាតិឃ្លាតឆ្ងាយទុក្ខកាយចិត្ត សូមសុខសណ្ឋិតនៃបនិត្យនៅ*
*ស្ដើងចិត្តអាក្រក់ល្អក់ឃោរឃៅ ចិត្តល្អនាំទៅតាមផ្លូវធម៌ ។*

*ដោយឧបាសក* **ហ៊ិម ឆាន់**

# ជីវប្រវត្តិសង្ខេប

ឧបាសក **មិុញ សាវ៉ាន** កើតក្នុងឆ្នាំ ជូត ខែចេត្រ ថ្ងៃសុក្រ ត្រូវនឹងឆ្នាំ ១៩៤៧/០៥/០៦ នៅភូមិខ្ពប ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល បិតានាម មិុញ វ៉ែន មាតានាម ហិុន អាង ជាកូនទី ៣ ក្នុងចំណោមបងប្អូនទាំងប្រាំនាក់ ។

មាតាបិតា ប្រកបមុខរបរ ជាអ្នកជំនួញ កាលនៅវ័យកុមារភាព **មិុញ សាវ៉ាន** បានចូលសិក្សា សាលាបឋមសិក្សា ភូមិខ្ពប ពុំទាន់បានមួយឆ្នាំផង លោកឪពុកត្រូវបាន ធ្វើមរណកាលទៅ ដោយរោគាពាធ ។

អ្នកម្តាយបានប្តូរទីលំនៅ មកនៅភូមិតាសល់ ឃុំចំណោម ស្រុកមង្គលបូរី ខេត្តបាត់ដំបងវិញ ដែលជាភូមិស្រុកលោកយាយ ។ កុមារា **មិុញ សាវ៉ាន** បានបន្តការសិក្សាដល់ថ្នាក់ ទី ៨ នឹងត្រូវបាន ចេញចាកពីសាលារៀន ដោយភាពក្រីក្រ មកបម្រើការងារ យកកម្រៃឈ្នួល ដើម្បីជួយសម្រួលការខ្វះខាត របស់អ្នកម្តាយ ។

លុះដល់ឈានចូលអាយុ ២១ ឆ្នាំ យុវជន **មិុញ សាវ៉ាន** បានសូមការអនុញ្ញាតពីមាតា ចូលឧបសម្បទា ជាភិក្ខុភាវៈក្នុងវត្តរោងគោ ឃុំចំណោម ស្រុកមង្គលបូរី ខេត្តបាត់ដំបង (បច្ចុប្បន្នគឺខេត្តបន្ទាយមានជ័យ) ក្នុងឆ្នាំ ១៩៦៨ ។

# បំពេញការសិក្សា

ក្នុងភាពជាភិក្ខុ, ភិក្ខុ **ម៉ិញ សាវ៉ាន** បានសិក្សាចប់ធម្មវិន័យថ្នាក់ត្រី - ទោ ក្នុងឆ្នាំ ១៩៦៨ - ១៩៦៩ នឹងបានបន្តការសិក្សាធម្មវិន័យ ថ្នាក់ឯកនៅវត្តបវេល ស្រុកបវេល ខេត្តបាត់ដំបង ក្នុងឆ្នាំ ១៩៧០ ហើយបានចេញជំនួយការសង្ឃ ក្នុងការបង្រៀនថ្នាក់ត្រី នៅវត្តចក ឃុំរហាត់ទឹក ព្រមទាំងធ្លាប់ចេញទៅប្រជុំសន្និបាត ក្នុងស្រុកមង្គលបូរី ជំនួសលោកគ្រូចៅអធិការ និងធ្វើជាមេប្រយោគ ប្រឡងធម្មវិន័យប្រចាំឆ្នាំ ក្នុងឆ្នាំ ១៩៧១ - ៧២, ធ្លាប់បានធ្វើដំណើរមកកាន់ប្រទេសថៃម្តង ដើម្បីស្វែងយល់ពីភាពរីកចម្រើនរបស់ប្រទេសគេ ។ ក្នុងឆ្នាំ ១៩៧៣ បានចូលសិក្សាភាសាបាលី នៅវត្តព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង ហើយបានជាជំនួយក្នុងការធ្វើមេប្រយោគប្រឡង និងកែវិញ្ញាសារប្រឡងធម្មវិន័យ ថ្នាក់ត្រី-ទោ នៅវត្តព្រះនេត្រព្រះទៀតផង ។

ពីឆ្នាំ ១៩៧៤ រហូតដល់ ថ្ងៃទី ១ ខែមេសា ឆ្នាំ១៩៧៥ ដោយស្ថានការណ៍ប្រទេសជាតិមាតុភូមិ បានត្រូវភ្លើងសង្គ្រាមឆាបឆេះកាន់តែធ្ងន់ធ្ងរឡើងៗទើបសម្រេចចិត្តចេញចាកទាំងភេទជាព្រះសង្ឃមកស្នាក់អាស្រ័យក្នុងប្រទេសថៃ ខេត្តសុរិន្ទ ស្រុកចំព្រាក អស់រយៈមួយវស្សា ហើយបានក្លាយជាជំនួយការព្រះអនុគណ ក្នុងការធ្វើជាធម្មទូត តាមសាលា ភូមិ ឃុំ ដែលសម្បូណ៌ដោយប្រជាជន ដែលមានសញ្ជាតិជាខ្មែរ (ហៅថាខ្មែរសុរិន្ទ ឬខ្មែរលើ) ហើយបានទេសនាជាភាសាខ្មែរ អប់រំទូន្មានឱ្យអ្នកទាំងអស់នោះបានស្តាប់ខ្លះផង ។

ឆ្នាំ១៩៧៦ បានប្រឡងថ្នាក់ត្រី ក្នុងវត្តគោកឆាង ស្រុកឧថ័យ ខេត្តអាយុធ្យា ប្រទេសថៃ ហើយនៅឆ្នាំ ១៩៧៧ បានប្រឡងថ្នាក់ទោ ក្នុងវត្ត បានប្រាវ ស្រុកបាណា ខេត្ត ណាខនណាយ៉ុក ។

ក្នុងខែសីហា នាឆ្នាំ ១៩៧៩ បានលាចាកភេទជាបព្វជា ជាភេទគ្រហស្ថ សូមច្បាប់ចូលមករស់នៅក្នុងជំរំ ជនភៀសខ្លួនខ្មែរ អារញ្ញប្រាធេថ ខេត្តប្រាជីនបុរី ។ អស់រយៈវេលាប្រាំមួយខែ ទើបសូមច្បាប់មកជ្រកកោន ក្នុងប្រទេសកាណាដា ។ នៅខែមេសាក្នុងឆ្នាំ ១៩៨០ បានមកដល់ទឹកដីថ្មី គឺខេត្តកេបិក នៅទីក្រុងដូលបូ-ឡាក់សាំងហ្សង់ (Dolbeau – Lac St.Jean) ។ ឆ្នាំ ១៩៨២ បានមករស់នៅទីក្រុង ម៉ុងរេអាល បានរៀបអាពាហ៍ពិពាហ៍ជាមួយឧបាសិកា **សឹម ចាន់- ធូរ៉ា** ក្នុងខែកក្កដា ឆ្នាំ ១៩៨៤ មានកូនប្រុសម្នាក់នាម **សឹម រតនា** ។

*ការគិតពិតជានាទីចិត្ត ក្លាយជាចរិតជិតដាមដាប់*
*ចរិតផ្ចិតកត់ផ្ចត់ទម្លាប់ រួចក៏តភ្ជាប់ជាវាសនា ។*
*គិតល្អគិតត្រូវផ្លូវទៅសុខ គិតសាញស្មាញស្មុគនាំទុក្ខា*
*ត្រូវតាំងសតិមើលត្រួតត្រា គិតតែការណ៍ណាល្អវិជ្ជមាន ៕*

*ដោយឧបាសក* **ហ៊ិម ឆាន់**

# ខ្មែររស់ ព្រោះតែខ្មែរសាមគ្គី

ខ្មែររួមខ្មែររស់សាងឈ្មោះល្បី សម្រេចជោគជ័យគ្រប់ភារកិច្ច
ថ្កុំថ្កើងកិត្តិយសខ្ពស់ជានិច្ច ខ្មែរអើយកុំភ្លេចត្រូវចងចាំ ។
ពាក្យពេចន៍ជូនតាចារចងទុក រាយជាទំនុកទុកផ្ដែផ្ដាំ
អតីតកាលអង្វែងឆ្នាំ ចារជាបណ្ដាំចាំក្នុងចិត្ត ។
រួបរួមសាមគ្គីជាធ្លុងមួយ ស្មារតីលៃជួយស្ទួយដោយពិត
អរិយធម៌វប្បធម៌ល្អវិចិត្រ សម្រាំងសំរិតឱ្យគង់វង្ស ។
ចេះស្រឡាញ់ជាតិមាតុភូមិ គិតប្រយោជន៍រួមគ្រប់កាយអង្គ
ខ្មែរស្រឡាញ់ខ្មែរសច្ចៈត្រង់ មិនឱ្យបាត់បង់កេរដូនតា ។
អាណិតអាសូរជាតិផងគ្នា កុំបង្កពៀរនាំទុក្ខា
ជម្រុះបោះចោលធម៌ហិង្សា គំនិតឥច្ឆាការនិន្ទា ។
ប្រទេចផ្ដាសាសម្លឹងទោស ជេរដាក់កំហុសខុសធម្មា
ប្រឈ្លោះទាស់ទែងសម្លាប់គ្នា បង្កភ័យពៀរនាំគ្នាលះ ។
បង្កបង្កើនខាងសន្តិភាព បន្ទន់បន្ទាបចិត្តមានះ
យល់ស្គាល់ការពិតចិត្តចាញ់ឈ្នះ អ្វីខុសចេះលះឈ្នះចិត្តឯង ។
បើឃើញគេខុសឱ្យអភ័យ ឥតនៅស្ងៀមហើជួយចាត់ចែង
ចេះកែតម្រូវត្រូវជាក់ស្ដែង លះចិត្តវង្វេងលែងព្រួយភ័យ ។
ត្រូវចេះទទួលរាល់កំហុស គ្រប់ប្រការនោះមកកែច្នៃ
ឱ្យបានត្រឹមត្រូវផ្លូវប្រពៃ ទើបបានជោគជ័យនៃជីវិត ។
កុំគិតតែប្រយោជន៍ខ្លួនឯង ត្រូវចេះចាត់ចែងចែកដោយពិត
ឱ្យដល់ជនជាតិទោះឆ្ងាយជិត បង្កើនញាតិមិត្តចិត្តមេត្តា ។
កុំបរិភោគតែម្នាក់ឯង នាំឱ្យស្លាក់ស្លែងរ៉ែងទុក្ខា
ចេះចែករំលែកញាតិផងគ្នា នឹងបានសុខាចម្រើនអើយ ៕

# នមស្ការសំវេជនីយដ្ឋាន

**កំណាព្យ បទពាក្យច្រាំពីរ**

យើងខ្ញុំសូមឱនអង្គសិរសា　　កាយចិត្តវាចាដោយគោរព
នមស្ការបង្គំទាំងថ្ងៃយប់　　វន្ទាប្រារព្ធសំវេជនីយដ្ឋាន　　។
ទាំងបួនកន្លែងចែងកំណត់　　មានពិតប្រាកដចេះចាំបាន
ទីមួយលុម្ពិនីឧទ្យាន　　នោះគឺជាស្ថានព្រះប្រសូត　　។
ទីពីរពោធិពុទ្ធគយា　　ព្រះអង្គផ្ចាញ់មារឱ្យខ្លាចកោត
កំចាត់អវិជ្ជាភាពល្ងង់ឆោត　　កិលេសរបូតបានត្រាស់ដឹង　　។
ទីបីឥសិបតនមិគទាយវ័ន　　អង្គព្រះអរហន្តជាពំនឹង
សម្ដែងធម្មចក្រជាក់ឱ្យដឹង　　បានជាទីពឹងសព្វសត្តា　　។
ទីបួនទីស្ថានបរិនិព្វាន　　នៅក្នុងឧទ្យានកុសិនារា
ខ្ចាក់ចោលត្រៃភពបីប្រការ　　រំលត់ខន្ធាលែងត្រឡប់　　។
យើងខ្ញុំបង្គំថ្វាយវន្ទា　　កាយចិត្តវាចាដោយគោរព
សំវេជនីស្ថានទាំងបួនគ្រប់　　សូមឆ្លងចាកភពវដ្តសង្សារ　　៕

# គុណព្រះរតនត្រ័យ

គុណរតនត្រៃថ្លៃវិសិទ្ធ　　លំអផ្លូវចិត្តពិតប្រពៃ
ឧត្តមបវរក្នុងលោកីយ៍　　គ្មានវត្ថុអ្វីប្រដូចបាន　　។
ដូច្នេះក្មេងចាស់ទាំងប្រុសស្រី　　លើភពផែនដីគ្រប់ទិសស្ថាន
គោរពបដិបត្តិចាត់ឱ្យមាន　　ក្នុងចិត្តសន្តានបានសុខា　　៕

# មាតុភូមិយើង

(បទពាក្យប្រាំបួន)

សូមមាតុភូមិ ទឹកដីរួម កេរដូនតា
ជាតិខេមរា ដ៏ថ្លៃថ្លា គង់វង្សនៅ
គ្រប់សម័យ កាលអង្វែង ជានិច្ចទៅ
សព្វសត្រូវ វង្វេងផ្លូវ ចាញ់ចេស្ដា ។
សាមគ្គីធម៌ ដ៏បវរ កកើតមាន
ក្នុងសន្ដាន ខេមរៈបុត្រ គ្រប់អង្គា
ស្រឡាញ់ជាតិ មាតុភូមិ រួមការពារ
ស្នេហ៍ស្និទ្ធគ្នា ជាពូជពង្ស វង្សជាខ្មែរ ៕

ដោយឧបាសក **ម៉ិញ សាវ៉ាន**

# ការបំពេញតួនាទី

## ជាពុទ្ធសាសនិក

ឧបាសក **មិុញ សាវ៉ាន** ពុំបានសិក្សាវិជ្ជាផ្លូវលោក ផ្លូវធម៌ ឱ្យបានច្រើននោះទេ ដោយធ្លាប់បានបួសក្នុងព្រះពុទ្ធសាសនា និង ធ្លាប់បានសិក្សាព្រះធម៌ជាពុទ្ធវចនៈ តែងមានឆន្ទៈជឿជាក់ជ្រះថ្លា ចំពោះខ្លឹមសារ និងរសជាតិព្រះធម៌ ។ សូម្បីជាភេទគ្រហស្ថក៏ដោយ នៅតែមានសេចក្តីព្យាយាមរៀនអាន ទន្ទេញ ស្តាប់ ព្រះធម៌ ជាព្រះ ពុទ្ធដីកា ពីសំណាក់លោកអ្នកប្រាជ្ញគ្រប់សម័យកាល ព្រមទាំង ព្យាយាមអានព្រះត្រៃបិដក ដើម្បីបង្កើនការដឹងយល់ និងបានអប់រំចិត្ត ឱ្យបានស្ថិតនៅក្រោមម្លប់ព្រះធម៌ និងបានព្យាយាមរៀបរៀងជា សៀវភៅព្រះធម៌ និងសរសេរចងក្រងជាកម្រងកំណាព្យ វែង ខ្លី ទុក ដើម្បីចែកជាធម្មទាន និងបានជាការបំពេញកងការកុសល តម្កល់ទុក សម្រាប់ខ្លួនឯង និងជាសាធារណប្រយោជន៍ ដល់ញាតិមិត្តសា-លោហិត អស់កាលជាអង្វែងទៅផង ។

### សច្ចំ វេ អមតា វាចា

(ពាក្យពិតជាវាចាមិនស្លាប់)

ពាក្យពិតបណ្ឌិតថ្លែងចរចា មានន័យខ្លឹមសារជាក្បួនច្បាប់
ស្ថិតនៅគ្រប់កាលឥតស្លែងស្លាប់ ជនផងត្រង់ត្រាប់ចាប់ជាគុណ ។


ឧបនិស្ស័យ
- ឧបាសក ម៉ិញ សារ៉ាង
គេហដ្ឋាន អភិរក្សមរតកព្រះពុទ្ធសាសនាខ្មែរ
ក្រុងម៉ុងរ៉េអាល - កេបិក - កាណាដា
ព.ស. ២៥៦៥ - គ.ស. ២០២២

# វិចារណកថា

## កាលវេលា និងជីវិត

កាលវេលា ពិតជាពុំបានអនុញ្ញាតឱ្យជីវិតប្រព្រឹត្តទៅ ឬសម្រេចសមតាមសេចក្តីប្រាថ្នា គ្រប់គោលការណ៍ ទាំងអស់នោះទេ តែងតែលះបង់ចោលជីវិតហើយទៅរាល់ខណៈពេលវេលា ។ ដូច្នេះ ជីវិតពិតជាមានរយៈខ្លី ជីវិតពិតជាត្រូវធន់ទ្រាំតស៊ូ ឬរផ្តាច់ការពារចំពោះឧបសគ្គនានា រហូតដល់គ្រាបញ្ចប់ ប្រៀបដូចជាអំពូលភ្លើងមួយដួង ដែលខំបញ្ចេញពន្លឺរបស់ខ្លួន រហូតដល់សូន្យសោះអស់រស្មី ពុំអាចបំភ្លឺតទៅទៀតបាន យ៉ាងណាមិញ គ្រប់តែជីវិតត្រូវខំតស៊ូធន់ទ្រាំ រហូតដល់ចុងបញ្ចប់ក៏ដូច្នោះដែរ ។

ជីវិតទោះបីមានរយៈខ្លី រស់នៅត្រឹមតែមួយថ្ងៃ ក៏ត្រូវព្យាយាមកែច្នៃរចនាជីវិត ឱ្យប្រព្រឹត្តទៅក្នុងភាពថ្លៃថ្នូរ ជីវិតមានតម្លៃ ជីវិតថ្លៃថ្នូរ គឺជីវិតប្រព្រឹត្តទៅដោយគុណធម៌ ព្យាយាមសន្សំសេចក្តីល្អ អប់រំបន្ទុំជីវិតឱ្យស្ថិតក្នុងភាពជាមនុស្ស ដែលមានចិត្តគំនិតខ្ពស់ ប្រកបដោយហេតុផល សាងគុណសាងប្រយោជន៍ទុកសម្រាប់ខ្លួន ព្រមទាំងចេះចែកចាយ ចំណាយគុណប្រយោជន៍ ដែលខ្លួនមានបាននោះ ជូនដល់ជនដទៃទៅតាមសមត្ថភាព ដែលខ្លួនអាចធ្វើបាន ។

# នាវាត្រៃលក្ខណ៍

(បទពាក្យប្រាំពីរ)

**អនិច្ចំ ទុក្ខំ អនត្តា** ព្រះអង្គទេសនាប្រាកដជាក់
គឺជានាវាព្រះត្រៃលក្ខណ៍ ព្យាយាមពឹងពាក់សព្វសត្តា ។
ដែលមានបំណងឆ្លងវដ្ដៈ ចេញចាកឱឃៈអន្ទាក់មារ
ឆ្ពោះសំដៅត្រើយនៃសង្សារ រួចផុតទុក្ខាភ័យវេរា ។
សត្វណាដែលមាននិស្ស័យខ្ពស់ តក់ស្លុតឃើញទោសត្រៃលោកា
សន្សំបារមីបានចាស់ក្លា បណ្ដុះបញ្ញាថ្លាក្នុងចិត្ត ។
រត់ចុះចេញពីនាវាលោក តែងបញ្ឆោតបោកឱ្យងងឹត
អវិជ្ជាមោហ៍បាំងខាំងរួបរឹត មច្ចុរាជប្រកិតតាមប្រហារ ។
ស្លាប់កើតៗស្លាប់ក្នុងភពបី ជួបទុក្ខទោសភ័យច្រើនប្រការ
វង្វេងដោយរាគៈតណ្ហា ឥតស្គាល់មាគ៌ាគេចវេះរត់ ។
នាវាត្រៃលក្ខណ៍ជាក់ជាយាន ចម្លងសត្វបានឱ្យរួចផុត
ឆ្ពោះដល់ត្រើយនាយពិតប្រាកដ បញ្ញាកំណត់ត្រៃលក្ខណា ។
**អនិច្ចំ**គឺជាភាពមិនទៀង ត្រៃលោកប្រែល្អៀងជាធម្មតា
**ទុក្ខំ**ទុក្ខពិតសព្វសត្តា ធម៌**អនត្តា**ឥតតាំងនៅ ។
ឥតស្ដាប់បង្គាប់បញ្ជាចិត្ត ត្រៃលោកវិប្បរិតសូន្យអស់ទៅ
នាវាត្រៃលក្ខណ៍ជាក់តាំងនៅ ចម្លងសត្វទៅកាន់ត្រើយនាយ ៕

ដោយឧបាសក **ម៉ិញ សាវ៉ាន**

# អាហារសម្រាប់ជីវិត

កវឡឹង្ការាហារ អាហារជាដុំ ជាពំនូត ជាអាហារចំណីសម្រាប់ទ្រទ្រង់រាងកាយរូបជីវិតិន្ទ្រីយ៍ ឱ្យមានចលនាទៅតាមរយៈកាលវេលាបាន ។ លាភ យសស័ក្តិ អំណាច តំណែងនាទី ទ្រព្យសម្បត្តិ មុខវិជ្ជា ជាអាហារ ជាសម្ភារៈ សម្រាប់អបស្ទប ជួយស្ទួយជំនួយដល់ជីវិត ដើម្បីឱ្យបានប្រព្រឹត្តទៅសុខសប្បាយ ងាយស្រួល ជាចំណែកខាងក្រៅ តែក៏នៅពុំបានគ្រប់គ្រាន់ សម្បូណ៌បែបរបស់ជីវិតទេ ។

ដូចបានពោលរៀបរាប់ ពីខាងដើមហើយថា ជីវិតត្រូវធន់ទ្រាំនឹងក្តៅត្រជាក់ ស្រេកឃ្លាន មានក្រ កង្វះខាត ជំងឺរោគាព្យាធិ ចាស់ឈឺ កាលបើជីវិតត្រូវធន់ទ្រាំតស៊ូដូច្នេះហើយ ទើបតម្រូវឱ្យជីវិតក្លាយទៅជាទាសករ ត្រូវមានកង្វះខាតជាដរាប សេចក្តីកង្វះខាតនាំឱ្យមានតម្រូវការ សេចក្តីត្រូវការនេះហើយ នាំឱ្យមានភាពអន្ទះអន្ទែង ក្តៅក្រហាយ ខ្វល់ខ្វាយ ទុក្ខសោក ចង្អៀតចង្អល់ រសាប់រសល់ ភ័យព្រួយ ។

ទាំងនេះបានធ្វើឱ្យជីវិតចិត្ត ឥតជម្រកគ្មានម្លប់ជាទីពឹងជ្រកអាស្រ័យ ត្រូវក្តៅរងាកំព្រាឯកោ ម៉្លោះហើយជីវិតនេះ ចេះតែប្រព្រឹត្តទៅតាមខ្សែទាញ សេចក្តីប្រាថ្នា ចំណង់ចំណូលរបស់ចិត្ត ដោយឥតព្រំដែន ឥតមានអ្វីជាគ្រឿងទប់ស្កាត់ ។ កាលបើបណ្តោយឱ្យជីវិតនេះប្រព្រឹត្តទៅតាមចង្វាក់ ខ្សែទាញរបស់តណ្ហា ការប្រាថ្នាចង់បានពុំចេះចប់ មិនស្កប់ស្កល់ ជីវិតត្រូវរត់ដេញព្យុះរលកបោកបក់នៃតណ្ហា ដោយ

ឥតមានគ្រឿងរាំងរា ការពារ ទប់ស្កាត់ ជីវិតត្រូវរត់រើបម្រះ ស្ទុះស្ទារ ទៅទាំងយប់ថ្ងៃ ដេកដើរឈរអង្គុយ គ្មានបានសុខ ស្រណុកសោះឡើយ ។ សេចក្ដីខ្វះខាតនៅមានដរាបណា សេចក្ដីមិនឆ្អែត សេចក្ដីស្រេកឃ្លាន ការមិនគ្រប់គ្រាន់ ក៏រមែងនៅមានដរាបនោះ ព្រោះតែដូច្នេះហើយ ទើបភាពមិនស្កប់ស្កល់ សេចក្ដីចង្អៀតចង្អល់ ខ្វល់ខ្វាយ ក្ដីក្រហល់ក្រហាយ ក៏នៅមាន ព្រោះគោលដៅ ការកំណត់ព្រំដែនសម្រាប់ជីវិត ឥតប្រាកដ ពុំអាចដឹងយល់ឱ្យពិតច្បាស់បាន ។

**ខន្ធ ៥ នាំមុខទុក្ខប្រចាំ**

**បង្កជាកម្មកើតវិបាក**

**បង្វិលវដ្ដៈមិនស្រាន្តស្រាក**

**បើចង់ចេញចាកចូរពឹងធម៌ ។l**

*ដោយឧបាសក* **ហ៊ិម ឆាន់**

# ភព ឬសង្សារវដ្ត

## កំណត់មិនបាន

ភពឬសង្សារវដ្ត សំដៅដល់ការកើត ទីកើត ទីអាស្រ័យស្នាក់នៅនៃជីវិត របស់សព្វសត្វទាំងឡាយ ឬថាការអន្ទោលទៅនៃជីវិតរបស់សត្វទាំងអស់... ដែលមានទំហំទូលំទូលាយ មិនងាយមានបុគ្គលណាម្នាក់ អាចកំណត់កត់សម្គាល់ ព្រំដែនខាងដើម និង ចុងបញ្ចប់បានសោះឡើយ ។

សូម្បីតែព្រះដ៏មានព្រះភាគ ព្រះអង្គបានត្រាស់ដឹងឡើងក្នុងលោក ក៏ព្រះអង្គមានព្រះពុទ្ធតម្រាស់យ៉ាងនេះថា ៖ (ម្នាលភិក្ខុទាំង-ឡាយ ខាងដើមនៃសង្សារវដ្តនេះ ពុំមាននរណាម្នាក់អាចកំណត់បាន គឺខាងដើមរបស់សព្វសត្វទាំងឡាយ ដែលមានអវិជ្ជាជារនាំង មានតណ្ហាជាចំណង ត្រាច់រង្គាត់ទៅ ពុំមានទីបំផុត មិនប្រាកដឡើយ) ។

ព្រោះតែទំហំព្រំដែននៃសកលពិភពនេះ ពុំអាចកំណត់បានស្មានត្រូវ ទើបតម្រូវ ឱ្យសកលពិភពនេះ ចេះតែវិវដ្តទៅជាលំដាប់ សម្ភារៈទំនើបនិយម បានរីកចម្រើនដុះដាល ត្រកាលភ្នែក បង្កើនសេចក្តីតម្រេក ត្រេកត្រអាលការប្រាថ្នា ឱ្យរឹងរឹតតែកើនឡើង ។ សម្ភារនិយមរបស់លោក បានបោះជំហានឈានទៅមុខជានិច្ច ធ្វើឱ្យចំណូលចំណង់នៃជីវិត ខំស្ទុះស្ទាររត់ប្រដេញ ដោយភាពកន្ទក់កន្ទេញ សោកសៅ អន្ទះអន្ទែង ដែលកើតអំពីចំណូលចំណង់ របស់ចិត្តឥតបើ

មានពេលគ្រប់ល្មមសោះឡើយ ។ សេចក្ដីប្រាថ្នា ការចង់បាននេះហើយ ជាប្រភពនៃការខ្វះខាតក្រីក្រ ត្រដរខំ លាយឡំដោយការសើចយំ សុខ ទុក្ខផ្លាស់ប្ដូរគ្នាជារឿយៗ រហូតដល់ការកំណត់ដៅស្មានព្រំដែនជីវិតពិតពុំបាន ទើបមានការស្រេកឃ្លាន ចង់បាន ចង់មាន មិនចេះចប់ស្កប់ស្កល់ រវល់ខ្វល់ខ្វាយដើម្បីជីវិត តាំងតែពីកើតមករហូតដល់ស្លាប់ទៅវិញ ទាំងនៅតែខ្វះ និងនៅតែស្រេកឃ្លាន កាលបើជីវិតគិតខំរត់ប្រដេញតាមក្រសែលោក ដូច្នោះរឹងរឹតតែខ្វះយ៉ាងនេះឯង ។

*គិតលើអំពើធ្វើរាល់ថ្ងៃ*

*ជាងឱ្យតម្លៃលើកិត្តិយស*

*អំពើរាល់ថ្ងៃថ្នៃឱ្យរស់*

*ល្បីល្បាញកិត្តិយសគេឱ្យទេ ។*

*ដោយឧទ្ទាសក* **ហ៊ិម ឆាន់**

# អ្វីដែលកន្លងផុតទៅ
## មិនអាចត្រឡប់វិញ

ក្នុងសំណេរ ឬការពោលស្តី គេតែងប្រៀបប្រដូច ជីវិតទៅនឹងកាលវេលា ប៉ុន្តែបើញែកចែកចេញពីគ្នា ឃើញថាមានន័យដោយឡែកពីគ្នា ពាក្យថាកាលវេលា គឺជាបញ្ញត្តិ ឬថាការសន្មតិ កំណត់លើកយកមកពោលស្តី ប្រាស្រ័យនិយាយជាភាសា វោហារសាមញ្ញទូទៅ ឱ្យងាយស្តាប់ចាប់យកសេចក្តីអត្ថន័យបាន ដែលហៅថា កាលបញ្ញត្តិ ដូចជាវេលាព្រឹក ថ្ងៃត្រង់ ពេលរសៀល ល្ងាច រាត្រីពេលថ្ងៃ យ៉ាងនេះជាដើម ។ ល ។

ការកំណត់ឈ្មោះខែ មានចេត្រ ពិសាខ ឈ្មោះឆ្នាំ មានជូត ឆ្លូវ យ៉ាងនេះ ហៅថា មាសាបញ្ញត្តិ ។ ក្នុងលោកនេះ សម្មតិបញ្ញត្តិដែលលើកយកមកពោលស្តី ប្រាស្រ័យនិយាយ មានជាអនេកបរិយាយ មិនអាចលើកយកមករៀបរាប់បាន ។ ប៉ុន្តែអ្វី ដែលស្តីថាជាបញ្ញត្តិ គ្រាន់តែជាសន្មតិកំណត់ លើកមកពោលស្តី ប្រាស្រ័យគ្នា និងកំណត់ កត់ចាំ ចំណាំ សម្គាល់បានតែប៉ុណ្ណោះ ព្រោះតែពុំមែនជាសភាវពិត ឥតមានការកើតរលត់ ដូចជាសភាវធម៌ពិតនោះទេ ។ ដូចជាយើងតែងពោល រៀបរាប់អំពីកាលវេលា មាននាទី ម៉ោង ថ្ងៃ ខែ ឆ្នាំ យ៉ាងនេះជាដើម ។ កាលបើយើងកំណត់ពីម៉ោង យើងរាប់យកពីម៉ោងមួយ ដេញទៅម៉ោងដប់ពីរ ហើយក៏ត្រឡប់ រាប់កំណត់មកម៉ោងមួយវិញ ចំណែកថ្ងៃ ក៏កំណត់រាប់ពីថ្ងៃអាទិត្យ ហើយក៏ត្រឡប់មករក

ថ្ងៃអាទិត្យវិញ ចំពោះខែឆ្នាំ ក៏កំណត់រាប់ដូចគ្នា ត្រឡប់សាចុះឡើង ដដែលៗ ឥតមានកាលវេលាណាមួយ ដែលកំណត់ថាជាឈ្មោះថ្ងៃ ខែ ឆ្នាំ ឬថាជាកាលបញ្ញត្តិ ជានាមបញ្ញត្តិ បាត់បង់ទៅដោយប្រការណានោះទេ ។

ចំណែកអ្វីដែលថា រលត់ផុតអស់ទៅ ឬកន្លងផុតទៅហើយ គឺពិតជាអស់ ពុំបានវិលត្រឡប់ក្រោយ តាមការដង្ហើយហៅ អង្វរករ កំណត់រក ឱ្យត្រឡប់មកដដែលតាមសភាពដើមវិញនោះ ក៏គឺជីវិត វ័យ អាយុ របស់សត្វលោកនេះឯង ព្រោះជីវិតនេះ ជាបរមត្ថធម៌ ជាសភាវពិត ជារូបធម៌ ជានាមធម៌ផង មានការកើតចេញ អំពីកម្មជាសមុដ្ឋាន មានការកើតនិងការរលត់ជាបន្ត នឹងមានចលនាឆ្ពោះទៅមុខ គឺទៅរកទីបំផុត គឺការអស់ទៅសូន្យទៅ ដោយពុំមានការត្រឡប់វិញ ឬភាពតាំងនៅ ដូចជាកាលវេលានោះទេ ។ តើមាននរណាម្នាក់មានសមត្ថភាព អង់អាចក្លាហាន មានឫទ្ធិចេស្តា អាចឃាត់ដំណើរជីវិត កុំឱ្យជាយ៉ាងនេះឬយ៉ាងនោះបាន ឬថាមាននរណាម្នាក់ អាចតោងទាញអត្តភាព អាយុវ័យដែលកន្លងទៅហើយ ដូចជាភាពជាកុមារាកុមារី យុវ័នយុវតី មកវិញបានពិតជាគ្មានសោះឡើយ ។ ចុះបើមានសំណួរថា ជីវិតបែកធ្លាយ ជីវិតសូន្យសោះអស់ទៅ ប៉ុន្តែពាក្យថាជីវិតនេះ ពុំបានបាត់បង់ទៅណា ព្រោះគេអាចពោលស្តីនិយាយប្រាស្រ័យ ហៅថា ជីវិតៗ ដដែលៗ បានទៀតទេតើ? ពិតដូច្នោះហើយ ដ្បិតអ្វីដែលស្ថិតនៅអាចហៅបាន គឺជានាម (ឈ្មោះ) ជាបញ្ញត្តិ ព្រោះហេតុនោះ ជីវិតនេះក៏ជាបញ្ញត្តិដែរ តែជាបញ្ញត្តិទៅលើបរមត្ថធម៌ ដែលហៅថា បរមត្ថបញ្ញត្តិ ដែលមានទាំងរូបធម៌ និង

នាមធម៌ ជាសភាវពិត តែងកើតឡើងហើយ រលត់ទៅវិញជាធម្មតា ដែលផ្សេងអំពីសម្មតិបញ្ញត្តិ ។

កាលបើយល់តាមសភាពពិត ថាជីវិតនេះរមែងអស់ទៅ សូន្យទៅ អត្តភាពនេះរមែងបែកធ្លាយរលត់រលាយទៅ ដូច្នេះកាលបើជីវិតកំពុងមានចលនាប្រព្រឹត្តទៅ ទោះបីជាមានរយៈខ្លីក្តី វែងក្តី ជីវិតត្រូវតែមានទីជម្រក ពំនាក់ពឹងពាក់ស្នាក់អាស្រ័យ និងមានគោលដៅសម្រាប់ជីវិត មិនត្រូវប្រមាទភ្លាំងភ្លេចស្មារតី យប់ថ្ងៃបណ្តោយឱ្យជីវិត កំព្រារងាឯកាអនាថានោះទេ ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់ត្រាស់យ៉ាងនេះថា ៖ (ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវមានទីពឹង កុំឱ្យជាអ្នករស់នៅ ដោយគ្មានទីពឹងឡើយ ម្នាលភិក្ខុទាំងឡាយ ព្រោះថាការរស់នៅ ដោយឥតទីពឹង រមែងមានសេចក្តីទុក្ខ) ត្រង់ពាក្យថា ជីវិតត្រូវមានទីពឹង សំដៅត្រង់ជីវិត ត្រូវរស់នៅប្រកបដោយធម៌ ។

***ទោះអ្នកទំនេរមិនធ្វើអ្វី***
***ក៏ជីវិតវ័យខ្លីរេចរិល***
***បើពឹងធម៌ព្រះជ្រះមន្ទិល***
***ទប់ឈប់បង្វិលកង់វដ្តៈ ។***

*ដោយឧបាសក* **ហ៊ឹម ឆាន់**

# កុំខ្លាំងតែម្នាក់ឯង

(បទពាក្យប្រាំពីរ)

ពេលក្តៅត្រូវស្វែងរកម្លប់ជ្រក ពេលឃ្លាននឹកភ្នករកអាហារ
ពេលមានធុរៈកិច្ចការផ្សារ ពឹងញាតិផងគ្នាជាជំនួយ ។
ពេលមានវិបត្តិទុក្ខផ្លូវចិត្ត ខ្វល់ខ្វាយគេងគិតឆ្អិតទ្រូងព្រួយ
ពឹងមិត្តស្នេហ៍ស្និទ្ធជិតចាំជួយ រំលែកទុក្ខព្រួយភ័យវិបត្តិ ។
ពេលមានបញ្ហាការស្មុគស្មាញ រកអ្នកជំនាញគឺបណ្ឌិត
ដោះស្រាយបំភ្លឺសេចក្តីពិត ចេញពីងងឹតចិត្តអន្ធការ ។
រស់នៅត្រូវអាស្រ័យញាតិមិត្ត ទោះបីឆ្ងាយជិតពឹងអាសា
កុំគិតថាខ្លួនឯងអស្ចារ្យ វង្វេងអន្ធការថាខ្លួនខ្លាំង ៕

ដោយឧបាសក **ម៉ិញ សាវ៉ាន**

# ជីវិត និង ធម៌

បើនិយាយពោលស្តីអំពីជីវិត ក៏ឈ្មោះថានិយាយពោលស្តី អំពីពាក្យថាធម៌ដែរ ការនិយាយពោលស្តី ប្រាស្រ័យអំពីធម៌ ក៏ឈ្មោះថាការនិយាយអំពីជីវិតដូចគ្នា ដូចពាក្យគេតែងពោលថា មេរៀនជីវិត ឬបទរៀនជីវិត ក៏សំដៅដល់ការសិក្សា សូត្ររៀន អានទន្ទេញ ឱ្យបានស្គាល់ យល់ជ្រាបពីព្រះធម៌ និងបដិបត្តិតាមព្រះធម៌ ទាំងនេះទើបថាជីវិតត្រូវការធម៌ ជាពំនឹងជាជម្រកសម្រាប់ជីវិត ។

ដូច្នេះពាក្យថាធម៌ ឬធម្មៈ នេះ សំដៅដល់ធម្មជាតិ ដែលកើតឯងមានឯង ទៅតាមហេតុបច្ច័យ ឬសភាវៈរបស់ខ្លួន ដោយពុំចាំបាច់មាននរណា បង្កើតសាងនោះទេ កាលបើកើតឡើងហើយ ក៏ត្រូវរលត់ប្រែប្រួល ទៅតាមសភាពដើមជាធម្មតា ទាំងគ្មានអ្នកណាម្នាក់អាចកែប្រែថាកុំឱ្យទៅជាយ៉ាងនោះបាន ។

ពាក្យថាធម៌ ឬធម្មៈ មានន័យទូលំទូលាយ គ្របដណ្តប់លាតត្រដាង លើពាក្យសម្តី អ្វីៗ ទាំងអស់មាននៅក្នុងសកលពិភពនេះ ទោះបីជាគេចង់ប្រើពាក្យដូចម្តេច ក៏គេចមិនផុតរត់មិនរួច អំពីពាក្យថាធម្មៈនេះទេ ព្រោះពាក្យថាធម៌ គឺជាធម្មជាតិ ធម្មតា ប្រក្រតីនេះឯង បើពោលឱ្យដល់ជម្រៅ ទោះជាបរមត្ថក្តី បញ្ញត្តិក្តី ជាវត្ថុធាតុក្តី ជានាមធាតុក្តី ក៏នៅន័យថាធម៌ទាំងអស់ គឺកើតឡើងហើយបែបណា ក៏តាំងនៅតាមសភាព ឬប្រែប្រួលអស់ទៅតាមសភាពបែបនោះ ដែលពុំ

មានអ្នកបច្ចេកវិជ្ជាណាម្នាក់អាចកែច្នៃ ដូចជាចង់យកវត្ថុធាតុដទៃ មកច្នៃជំនួសវត្ថុធាតុដើម ដូចជាពេជ្រ មាស ឱ្យទៅជាសំណ ស្ពាន់ ឬថាធ្វើសំណស្ពាន់ ឱ្យកើតទៅជាពេជ្រមាស ប្រាកដជាពុំបានសោះឡើយ បានត្រឹមតែកែច្នៃ រចនា ឱ្យបានជាគ្រឿងសម្អិតសម្អាង តាក់តែងតែប៉ុណ្ណោះ បើចង់យកវត្ថុដទៃមកកែច្នៃឱ្យទៅជាមាសពេជ្រនោះ ក៏គ្រាន់តែជាវត្ថុកាឡៃ បន្លំក្លែងតែប៉ុណ្ណោះ ។

នេះគ្រាន់តែពោលទៅតាមបញ្ញត្តិ បើពំនោលជាបរមត្ថវិញ បានដល់ជីវិត អត្តភាពរូបរាងកាយ ខន្ធនេះ ត្រូវការដេក ដើរ ឈរ អង្គុយ ស្រេក ឃ្លាន ទទួលទាន ឬបន្ទោបង់ ព្រមទាំងតម្រូវការជាច្រើនទៀត ដែលពុំអាចរាប់បាន ជាពិសេសជីវិតនេះ មិនទៀងត្រូវចាស់ ឈឺស្លាប់ ទាំងនេះគឺជាសភាវពិត ប្រចាំជីវិត ដែលជាបញ្ហា និងជាដំណោះស្រាយ របស់មនុស្សគ្រប់សម័យកាល ព្យាយាមស្រាវជ្រាវរាវរក គ្រប់វិធីសាស្ត្រ តែក៏គង់គ្មាននរណាម្នាក់ អាចកែប្រែ កុំឱ្យទៅជាសភាពនោះបាន ទើបនាំគ្នាព្យាយាមបង្កើតបាន ត្រឹមតែរូបមន្ត សម្ភារៈសម្រាល បម្រើការ តាមចំណូលចំណង់របស់ជីវិត ទៅតាមកាលសម័យប៉ុណ្ណោះ ។ អាស្រ័យហេតុនេះ បានជាជីវិត ត្រូវរត់ស្ទុះតាមគ្រឿងសម្ភារៈនិយម ដែលគ្មានទីកំណត់គោលដៅ និងគ្មានទីបញ្ចប់បាន បើជីវិតគិតតែប្រដេញ ប្រណាំងប្រជែង តាមចង្វាក់រលកបោកបក់ក្រសែលោក ដោយគ្មានគោលដៅ ទីជម្រកជ្រកស្នាក់ពិតប្រាកដយ៉ាងនេះ ជីវិតត្រូវទទួលភាពអន្ទះអន្ទែងខ្វះខាត កន្ទក់កន្ទេញ ឥតមានទីពំនឹងជាដរាប ។

ដូច្នេះ ជីវិតត្រូវតែមានមាគ៌ាពិតប្រាកដ កំណត់ផ្លូវត្រូវដើរទៅ

កាន់គោលដៅមួយ យ៉ាងពិតប្រាកដ ដោយពុំបាច់រត់ប្រដេញតាមព្យុះបក់បោករលកពិភពលោកទៀត ព្រោះតែជីវិតមានទីពំនឹងពិតប្រាកដ ដោយសារតែជីវិតមានធម៌ ជាធម្មមាគ៌ា ជាផ្លូវ ជាធម្មនាវា ជាយាន ជាទូក ជាធម្មឱសថ ជាថ្នាំ ជាធម្មាហារ ជាអាហាររបស់ចិត្ត ជាធម្មសរណៈ ជាទីពឹងរលឹក ជាធម្មប្បដិបត្តិ សម្រាប់បដិបត្តិ ជាធម្មសប្បាយ ជាទីសប្បាយសម្រាប់ចិត្ត ។

ពាក្យថាធម៌ ឬធម្មៈ ដូចបានពោលរៀបរាប់មកនេះ ដែលថាជាធម្មជាតិប្រក្រតី ធម្មតាក្តី គឺឱ្យនិយមន័យ ទៅលើរូបធាតុ វត្ថុធាតុ នាមធាតុ រួមទាំងបញ្ញត្តិ បរមត្ថ ដើម្បីងាយស្រួលក្នុងការស្តាប់ ចាប់យកសេចក្តីយល់ចូលចិត្តបាន ឱ្យកាន់តែច្បាស់ថែមទៀត គឺថាធម៌ និងជីវិត ពិតជាពុំមានគម្លាតពីគ្នានោះទេ ។

ដូច្នេះត្រង់ពាក្យថា ជីវិតត្រូវមានធម៌ សំដៅយកគុណធម៌ គឺសេចក្តីល្អ ដែលកើតចេញបានមក ពីការប្រព្រឹត្តិបដិបត្តិ តាមផ្លូវកាយ វាចាចិត្ត ដើម្បីបានជម្រះ ដុសខាត់ បំបាត់សម្អាតកងកិលេស មន្ទិល គ្រឿងសៅហ្មង ដែលជាប្រភពនៃការខ្វះខាត អន្ទះអន្ទែង ក្តៅក្រហាយ ខ្វល់ខ្វាយ ចង្អៀតចង្អល់ រសាប់រសល់ សោកសៅ កន្ទក់កន្ទេញ ដែលតែងមានប្រចាំគ្រប់តែជីវិត ដូចបានពោលរៀបរាប់ទុកពីខាងដើមហើយ ទើបជាចាំបាច់ណាស់ ដែលតម្រូវឱ្យជីវិត ត្រូវការទីពឹងព្រះធម៌ ។

ព្រះធម៌ជាព្រះពុទ្ធដីកា ដែលព្រះអង្គទ្រង់ត្រាស់សម្តែង អស់រយៈសែសិបប្រាំព្រះវស្សា មានទាំងសេចក្តីពិស្តារ និងសេចក្តីសង្ខេប

ខ្លី ដើម្បីទុកឱ្យវេនេយ្យសត្វ ស្តាប់ចាប់យកសេចក្តី បដិបត្តិទៅតាមរៀងៗ ខ្លួន នឹងបានជាទីពឹងសម្រាប់ជីវិត ព្រមទាំងធ្វើឱ្យដំណើរជីវិតឆ្ពោះទៅកាន់គោលដៅមួយពិតប្រាកដ ។ ដោយមហាករុណាទិគុណរបស់ព្រះដ៏មានព្រះភាគ ទ្រង់បានចងក្រងជាព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្ម ទាំងសុទ្ធតែមានទំនាក់ទំនងនៃជីវិត ដើម្បីបានបដិបត្តិប្រកបដោយសេចក្តីសុខចម្រើន ទាំងក្នុងឥធលោក (លោកនេះ) និងបរលោក ទាំងបានចម្លងនាវាជីវិតនេះ ឱ្យបានឆ្ពោះទៅកាន់គោលដៅមួយ ដែលមានទីសំចតស្នាក់យ៉ាងពិតប្រាកដ ដោយគ្មានភាពរសេមរសាមទៀតឡើយ ។

ព្រះធម៌ដែលថាមានទំនាក់ទំនងនឹងជីវិត ដូចជាវិន័យបានដល់ច្បាប់ ដែលមានទាំងបញ្ញត្តិ គឺខហាមប្រាមមិនឱ្យធ្វើ ព្រោះជាអំពើមោះហ្មងឆ្គាំឆ្គង ធ្វើឱ្យខ្វះរបៀបរៀបរយក្នុងសង្គម បង្កឱ្យមានការប្រទូស្តឈ្លោះ ទាស់ទែង ឥតក្រែងរអា ពុំមានការគោរពសិទ្ធិរវាងគ្នានឹងគ្នា ជាហេតុនាំឱ្យមានភេរវកម្ម ភេរវភ័យ រកសេចក្តីស្ងប់គ្មាន ។ ដែលថាមានទាំងខអនុញ្ញាត បានដល់អ្វីដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីរៀបរយ មានការគោរពសិទ្ធិដល់គ្នា មានសេរីភាពក្នុងការទទួលខុសត្រូវ ទៅក្នុងដំណែងមុខនាទី កាតព្វកិច្ចរៀងៗ ខ្លួន ។

ព្រះវិន័យបានដល់សីល ប្រៀបដូចជាខ្សែអំបោះ សម្រាប់ដោតចងក្រងផ្កា ទោះបីជាផ្កាមានប្រភេទផ្សេងៗ គ្នា ដោយពណ៌ ដោយក្លិនក្តី តែដោយការឈ្លាសវៃនៃនាយមាលាការ រមែងក្រងផ្កាឱ្យទៅជាកម្រង គួរជាទីពិតពិលរមិលមើលនៃជនានុជន និងគួរជាទីប្រាថ្នា យកកម្រងផ្កា ជាគ្រឿងប្រដាប់លំអកាយ និងបូជា ដល់ព្រះ

រតនត្រ័យ ដោយសេចក្ដីជ្រះថ្លា យ៉ាងណាមិញ ព្រះវិន័យអាចឃុំគ្រង គណៈបក្សពួក ដែលចេញពីត្រកូលជាតិសាសន៍ ឋានៈអំណាចផ្សេង ដោយឡែកពីគ្នា ឱ្យអាចចេះគោរពរាប់អាន រួមរស់ជាមួយគ្នា ប្រកបដោយភាពមេត្រី សេចក្ដីសុខសេចក្ដីចម្រើន រស់នៅក្នុង ក្របខ័ណ្ឌនៃច្បាប់វិន័យ ដោយសុខសន្តិភាព ។

ព្រះសូត្រព្រះអង្គទ្រង់ត្រាស់សម្ដែង ទាក់ទងដោយរឿងរ៉ាវ ដំណើរជីវិត សកម្មភាព របស់សត្វលោក ជាតិសាសន៍ ប្រទេសភូមិ ឋាន ភាពអន្ទោលសេចក្ដីសុខទុក្ខ ដែលមិនប្រាកដរមែងផ្លាស់ប្ដូរ ទៅ តាមអំពើការងារ ដែលសត្វលោកសន្សំកសាង មានទាំងល្អអាក្រក់ ព្រមទាំងផលដែលត្រូវបានទទួលជាបាបបុណ្យ គុណទោស សុខទុក្ខ ចម្រើនវិនាស ទាំងជីវិតក្នុងបច្ចុប្បន្ន អនាគត លោកនេះ លោកខាង មុខ ព្រមទាំងភូមិឋាន មានអបាយ មនុស្ស ទេវតា ព្រហ្ម ជាដើមនេះ ក្នុងការបញ្ជាក់ បើកបង្ហាញឱ្យឃើញពីដំណើរជីវិត បើខ្វះគុណធម៌ គឺ សេចក្ដីល្អ ប្រាកដជាពុំអាចរកសេចក្ដីសុខចម្រើន ឱ្យដល់ខ្លួនឯងបាន ចាំបាច់ពោលថ្វីសម្រាប់អ្នកដទៃនោះ ផ្ទុយទៅវិញ មានតែការបង្កភាព ចលាចល ច្របូកច្របល់ខ្វល់ខ្វាយ ក្ដៅក្រហាយដល់ខ្លួន ដល់សង្គម គ្រួសារ សង្គមជាតិមាតុភូមិ សង្គមលោកតែប៉ុណ្ណោះ ។

នៅក្នុងអត្ថន័យព្រះសូត្រ ព្រះដ៏មានព្រះភាគទ្រង់បានលើក យកគុណនិងទោស សុខទុក្ខ ចម្រើនវិនាសមកជានិទស្សន៍ ។ តាម ធម្មតា គ្រប់មនុស្សសត្វ ជាតិសាសន៍ ក្នុងសកលពិភព រមែងមានការ ស្អប់ខ្ពើម តក់ស្លុតភ័យខ្លាចចំពោះ សេចក្ដីទុក្ខស្មើដូចគ្នា (ព្រះសាស្ដា សម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា ៖ សេចក្ដីទុក្ខ ជាភ័យធំសម្រាប់សត្វលោក)

ដូច្នេះអាចបញ្ជាក់បានថា សត្វលោកតែងប្រាថ្នាចង់បានសេចក្តីសុខ ក៏ប៉ុន្តែសេចក្តីសុខ ពុំមែនកើតឡើង ឬបានមកដោយការបន់ស្រន់ អង្វរករ ដេកចាំ ផ្សងព្រេង វង្វេងចាំវាសនា ការជប់ប្រទានឱ្យពីព្រះជាម្ចាស់ ទេវតាឥន្ទ្រព្រហ្ម ឬពីវត្ថុស័ក្តិសិទ្ធណាមួយនោះទេ ។ សេចក្តីសុខទុក្ខកើតមកពីហេតុបច្ច័យ ដូច្នេះបើសត្វលោកប្រាថ្នាចង់បានសេចក្តីសុខ ស្អប់ខ្ពើមសេចក្តីទុក្ខពិតមែននោះ ជាចាំបាច់ណាស់ត្រូវព្យាយាម រៀនយល់ស្គាល់ដឹងអំពីហេតុបច្ច័យនៃសេចក្តីទុក្ខនោះ ឱ្យបានយល់ចូលចិត្តដោយខ្លួនឯងប្រចក្សចែង នឹងបានជាកម្លាំងដល់ការព្យាយាមកម្ចាត់បង់លះចោល គ្រប់អំពើបាបលាមក ដែលជាហេតុនៃសេចក្តីទុក្ខចោលចេញ ព្យាយាមសន្សំសាងជំនួសវិញ គ្រប់អំពើបុណ្យដែលជាគុណ ជាហេតុបច្ច័យនៃសេចក្តីសុខ ។ ព្រះសូត្រជាថ្នាក់កណ្តាល បើពោលទៅតាមន័យសេចក្តីក៏បានឈ្មោះថា ជាអភិធម្មនោះឯង គ្រាន់តែព្រះដ៏មានព្រះភាគ លើកយកមកសម្តែងជាបុគ្គលាធិដ្ឋានផង ជាធម្មាធិដ្ឋានផង ជាអត្ថានុរូបផង ជាអត្ថប្បដិរូបផង ជាសម្មតិបញ្ញត្តិផង ជាសភាវបរមត្ថបញ្ញត្តិផង ទៅតាមឧបនិស្ស័យរបស់សព្វសត្វក្នុងការយល់ចូលចិត្តនៃធម៌ ដើម្បីដុសខាត់ហាត់អប់រំខាងផ្លូវចិត្តឱ្យរឹងរឹតប្រណីតឡើងទៅ បន្ទាប់ពីសីលបានដល់សមាធិដែលជាគុណធម៌ ជាលំអថ្នាក់កណ្តាល ។

ព្រះអភិធម្ម ជាធម៌ដែលមានកម្រិតខ្ពស់ មានន័យល្អិតសុខុមជាសភាវធម៌ពិតញែកចេញ បើកបង្ហាញឱ្យឃើញថា មិនមែនជាបញ្ញត្តិ ជាសត្វជាបុគ្គល តាមការឃើញយល់ សម្គាល់ដោយសេចក្តីប្រកាន់ ព្រោះការសម្គាល់តាមសភាពគ្រោតគ្រាត ដែលគ្រាន់តែជា

សម្បកខាងក្រៅនោះទេ ។ សត្វលោកតែងមានចិត្ត ងងឹតងប់ងល់ យល់ច្រឡំប្រកាន់ជាប់ស្អិត ចំពោះអត្តភាពជីវិតនេះ ថាជាសត្វបុគ្គល ខ្លួនប្រាណឯងអញ ដោយអំណាចអវិជ្ជា ជាកំពែងរនាំង គ្រឿងប្រក់បាំង ឥតបានព្យាយាមរើបម្រះចេញពីភាពអន្ធការ នឹងឥតបានដឹងថាអាត្មាឯងកំពុងជាប់ហ៊ុមរួបរឹតដោយចំណងនោះទេ ទើបធ្វើឱ្យវង្វេង យល់ច្រឡំ សម្ងំរស់នៅជាមួយសត្រូវ មិនអាចសម្លឹងមើលទិសដៅ ទីចតស្នាក់សម្រាប់ជីវិតនេះ ឱ្យបានពិតប្រាកដឡើយ ។ ជីវិតត្រូវត្រាច់រង្គាត់ក្នុងសង្សារវដ្តទាំងងងឹតវង្វេង សូម្បីតែខ្លួនឯងមកពីណាក៏មិនដឹង អត្តភាពជីវិតបច្ចុប្បន្ន ការរស់នៅដោយស្មាន ឥតបានដឹងថាជីវិតនេះ នឹងត្រូវរលត់ផុតទៅក្នុងពេលណា ដំណើរជីវិតនឹងត្រូវទៅកាន់ទីណា ជាអ្វីទៀតពិតជាពុំដឹងបាន ។

ព្រះសាស្តាសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ត្រាស់សម្តែងព្រះអភិធម្ម មានន័យពិស្តារទូលំទូលាយ បើចែកចេញជាធម្មក្ខន្ធ មានដល់ទៅបួនហ្មឺនពីរពាន់ (៤២,០០០) ព្រះធម្មក្ខន្ធ ឃើញថាច្រើនជាងព្រះវិន័យព្រះសូត្រ តែបើចែក ដោយសង្ខេបមានត្រឹមតែបួនប្រភេទ គឺចិត្ត ចេតសិក រូប និព្វានប៉ុណ្ណោះ ។ ព្រះអភិធម្ម ដែលថាមានន័យពិស្តារ ល្អិតសុខុម ព្រោះលាតត្រដាងគ្របដណ្តប់ រួបរួមទូទាំងព្រះវិន័យព្រះសូត្រ ឬថាទាំងវត្ថុធាតុ ជារូបធាតុ ជាអរូបធាតុ ទាំងវិញ្ញាណធាតុ អវិញ្ញាណធាតុ ទាំងជាលោកិយវិស័យ និងលោកុត្តរវិស័យ ត្រង់ដែលព្រះអង្គសម្តែងអំពីចិត្ត ចេតសិក រូប ជាសភាវកើតឡើងហើយត្រូវរលត់បន្ត ទៅតាមប្រក្រតីនៃធម៌នោះ ។ ចំពោះចិត្ត ចេតសិក រូបណា ដែលមានការកើតរលត់ ឬនៅមានការត្រាច់រង្គាត់ក្នុងលោក

មានកាមលោក រូបលោក អរូបលោក និងមានការជាប់ជំពាក់ដោយកាម ដោយរូប ដោយអរូប ទាំងនេះចាត់ថាជា លោកិយវិស័យ ចំណែកចិត្ត ចេតសិក រូបណាដែលឆ្លងផុតដោយពុំមានការជាប់ជំពាក់ ក្នុងកាមលោក រូបលោក អរូបលោកទៀតទេនោះ ព្រោះមានព្រះនិព្វានជាអារម្មណ៍តែម្យ៉ាង ចិត្ត ចេតសិក រូបនោះ ជាលោកុត្តរ-វិស័យ ។

ដូច្នេះការសម្តែងព្រះធម៌នោះ ទោះជាផ្នែកណាក៏ដោយ សុទ្ធតែបានឆ្លុះបញ្ចាំងនឹងជីវិត ព្រមទាំងបានបញ្ជាក់បង្ហាញ ពីរឿងរ៉ាវបញ្ហា សុខទុក្ខ ព្រមទាំងឱ្យមាន ការដឹងយល់ស្គាល់ អំពីដំណោះស្រាយ ដែលមានទំនាក់ទំនងនឹងជីវិត ទាំងក្នុងបច្ចុប្បន្ន បរលោក ព្រមទាំងជីវិត ដែលមានចលនាវិវដ្ត ត្រាច់រង្គាត់ទៅនៅក្នុងសកលពិភព ឬសង្សារវដ្តនេះ ដោយឥតមានគោលដៅ ទិចតស្នាក់ពិតប្រាកដ ដូចបានពោលរៀបរាប់ពីខាងដើមហើយ ។ ដើម្បីឱ្យជីវិតនេះ មានដំណើរឆ្ពោះទៅកាន់គោលដៅច្បាស់លាស់ ដែលមិនស្រពេចស្រពិលរសេមរសាមតទៅទៀត បានន័យថា ការចម្លងជីវិតនេះពីសភាពមួយឱ្យបានទៅកាន់សភាពមួយ ដែលរឹងរឹតតែប្រសើរឡើងបាន ដូចចម្លងជីវិតពីភាព បុថុជ្ជន ទៅកាន់ភាពជាអរិយជន ពីលោកិយវិស័យឱ្យបានដល់ភាពជាលោកុត្តរវិស័យ ។ អាស្រ័យដូចការពោលរៀបរាប់មកនេះ ទើបតម្រូវឱ្យជីវិតមានធម៌ ពឹងពំនាក់បដិបត្តិ តាមមាគ៌ាព្រះធម៌ ដែលព្រះសាស្តាចារ្យ សម្មាសម្ពុទ្ធ ទ្រង់បានត្រាស់សម្តែង ចង្អុលបង្ហាញមានជាអនេកបរិយាយ ដែលគ្រប់តែជីវិតត្រូវហាត់រៀនអានទន្ទេញ ឱ្យបានចេះដឹង យល់ស្គាល់ដល់ជម្រៅអត្ថន័យនៃព្រះធម៌នោះៗ ទាំង

ព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្ម ឱ្យបានយល់ចូលចិត្ត ទៅតាមសភាពពិតរបស់ព្រះធម៌ នឹងបានបដិបត្តិបានត្រឹមត្រូវ តាមហេតុផលពិត សមតាមចរិតឧបនិស្ស័យរៀងៗ ខ្លួន នឹងបានទទួលផល បំបាត់ចម្ងល់ បន្ទោបង់នូវការសង្ស័យដោយខ្លួនឯង ។

**អានព្រៃត្របិដក បានបុណ្យតក់ៗ បំភ្លឺនេត្រា**
**ទោះយល់តិចច្រើន បង្កើនបញ្ញា ត្រួសផ្លូវកាប់ឆ្ការ**
**ឆ្លងសង្សារវដ្ដ ៕**

*ដោយឧបាសក* **ហ៊ិម ឆាន់**

# សម្លឹងក្រៅ ដៅក្នុង

(បទព្រហ្មគីតិ)

វាចានិងដួងចិត្ត ពិតមិនឃ្លាតចេញពីគ្នា
ព្រោះមានចិត្តបញ្ជា ទើបវាចាចេញមកបាន ។
ទោះបីជាមាយា ចិត្តឫស្យាបង្វែងដាន
យូរឆាប់ចាប់យល់បាន ព្រោះសន្ដានបានសន្សំ ។
បាបបុណ្យគុណឬទោស ចរិយានោះមិនច្រឡំ
កាលបើប៉ះអារម្មណ៍ ដៅត្រូវចំបញ្ជាក់បាន ៕

ដោយឧបាសក **ម៉ិញ សាវ៉ាន**

# តម្រូវការសម្រាប់ជីវិត

## ក្មុងសង្សារវដ្ត

ជីវិតស្ថិតនៅត្រើយខាងអាយ គឺជីវិតត្រូវត្រាច់រង្គាត់ក្នុងសង្សារវដ្ត ជីវិតពិតជាត្រូវការស្បៀងអាហារ សេនាសនៈជាជម្រកជ្រកអាស្រ័យ សំលៀកបំពាក់បិទបាំងកេរ្តិ៍ខ្មាស ការពារត្រជាក់ក្តៅ ថ្នាំការពារព្យាបាលរោគផ្សេងៗ ។ ភោគសម្បត្តិ វិជ្ជាសម្បត្តិ ចំណេះដឹងជំនាញការ សេចក្តីសុខ ភាពចម្រើនរុងរឿង សិទ្ធិសេរីភាព ។ ការមិនបៀតបៀន គំរាមកំហែង ទោសទណ្ឌ ការដាក់តម្លៃ វាយបន្ថោកមើលងាយ បន្តុះបង្អាប់ ទាំងនេះពិតជាខុសផ្ទុយអំពីភាពលើកកម្ពស់ឱ្យតម្លៃសរសើរលើកទឹកចិត្ត ដែលជាតម្រូវការរបស់ជីវិត រហូតដល់ជីវិតនេះចេះតែប្រាថ្នា លើសពីតម្រូវការដោយឥតមានរនាំងបាំងរាំងស្ទាក់ ទើបធ្វើឱ្យជីវិតឥតចេះស្កប់ស្កល់ធួនល្មម ចេះតែមានកង្វះជាដរាប ត្រូវស្ទុះស្ទាររត់ប្រដេញតាមគ្រប់អ្វីៗ ក្នុងលោកិយនេះ ដោយភាពកន្ទក់កន្ទេញ ប្រមាទភ្លេចស្មារតីវង្វេង នឹកស្មានថាខ្លួនឯងកំពុងតែស្វះស្វែងរកសេចក្តីសុខទៅវិញ ។ តែតាមការពិតនោះ កាលបើសេចក្តីប្រាថ្នា ការរត់តាមដេញសម្ភារៈលោក នៅមានដរាបណា ការមិនស្កប់ស្កល់ ខ្វល់ខ្វាយ កាយចិត្តឥតស្ងប់សុខក៏នៅមានដរាបនោះ ។ ដូច្នេះការសម្តែងអំពីព្រះវិន័យ ព្រះសូត្រ គឺព្រះដ៏មានព្រះភាគ ទ្រង់សម្តែងឆ្លុះបញ្ចាំង អំពីសិទ្ធិ សេរីភាព គ្រប់តែជីវិតត្រូវស្ថិតនៅក្នុងក្របខណ្ឌនៃច្បាប់ គោរពសិទ្ធិ សេរីភាពរវាងគ្នានឹងគ្នា ជា

ហេតុធ្វើឱ្យសង្គមក្រុមមានឯកភាព សមូហភាព ក្នុងការបំពេញតួនាទី ធ្វើឱ្យសង្គមគ្រួសារ សង្គមជាតិមាតុភូមិ សង្គមលោក រស់នៅមានរបៀបរៀបរយ មានសេចក្តីសុខស្ងប់ ពុំមានសេចក្តីភ័យព្រួយ ក្នុងការបៀតបៀនគ្នានោះទេ ។ ការហ៊ានទទួលខុសត្រូវ ក្នុងមុខតំណែងនាទីរបស់ខ្លួន ជាហេតុធ្វើឱ្យកិច្ចការងារនោះប្រព្រឹត្តទៅបានល្អប្រពៃ ការបើកចិត្តឱ្យបានទូលាយ សម្លឹងមើលតាំងតែពីទីជិតឆ្ពោះទៅទីឆ្ងាយ ការចេះឱ្យតម្លៃគ្នា សរសើរលើកទឹកចិត្ត ជួយជ្រោមជ្រែងចំពោះការងារជាគុណប្រយោជន៍ ការជូនជាយោបល់ ផ្តល់គំនិតល្អៗឱ្យដល់គ្នា ដោយភាពមេត្រី ស្មោះត្រង់ដល់គ្នានឹងគ្នា ទាំងនេះចាំបាច់ត្រូវពឹងលើព្រះវិន័យ គឺសីលនេះឯង ។ ចំណែកព្រះសូត្រ ព្រះអង្គទ្រង់សម្តែងឆ្លុះបញ្ចាំងអំពីរឿងរ៉ាវ បញ្ហាជីវិតសត្វលោក ប្រទេសភូមិស្ថាន ទង្វើគឺការងារមានទាំងអាក្រក់ល្អ ទាំងផលដែលត្រូវទទួលបាន គឺការចម្រើន វិនាស សុខទុក្ខ សើចយំ មានប្រការផ្លាស់ប្តូរជាតិកំណើត សម្បត្តិ វិបត្តិ សម្រាប់ជីវិត ទាំងក្នុងជាតិជាបច្ចុប្បន្ន អតីត អនាគត អំពីសភាពមួយទៅកាន់សភាពមួយ ដោយពុំអាចការពាររារាំងបាន មកអំពីកិរិយាការធ្វើគឺ (កម្មតែម្យ៉ាង) ដែលគ្រប់តែជីវិតសាងសន្សំខ្លួនឯងដោយពិត ពុំមែនមានព្រះអាទិទេព ឬវត្ថុស័ក្តិសិទ្ធិណាមួយ អាចជួយ ឬជំនួសបាននោះទេ ។

ព្រះសូត្រព្រះអង្គទ្រង់សម្តែង ចង្អុលបង្ហាញ បើកបំភ្លឺ ឱ្យសត្វលោកបានយល់ចូលចិត្ត អំពីដំណើរជីវិត ដែលពិតជាមានចលនាវិវដ្តទៅ ដោយការសាងសន្សំធ្វើខ្លួនឯងពិតៗ នឹងធ្វើឱ្យសត្វលោកដែលជាប់ចិត្តស្អិតប្រកាន់ចំពោះសេចក្តីសុខសប្បាយរីករាយតក់ស្លុត

រន្ធត់ភ័យ ស្អប់ចំពោះទុក្ខទោស កំហុសឆ្គងទាំងពួង មានស្មាតីក្នុងការព្យាយាមលះ រាល់អំពើខុសឆ្គងសៅហ្មង បាបលាមកចោលចេញ នឹងបានបើកឱកាស ឱ្យបានខិតខំសន្សំសាងនូវរាល់អំពើល្អ ឱ្យមានប្រចាំចិត្តខ្លួនឱ្យបានជាប្រក្រតី ដោយការផ្គងចិត្ត ធ្វើជីវិតឱ្យប្រព្រឹត្តដល់កម្រិតកណ្តាល ដែលហៅថាសមាធិ នឹងបានជាជំនួយ ស្ទួយលើកកម្ពស់ចិត្តឱ្យសុខស្ងប់ មិនតក់ក្រហល់ខ្វល់ខ្វាយ រវើរវាយអន្ទះអន្ទែង ប្រណាំងប្រជែង រត់តាមសម្ភារៈរបស់លោក ដោយភ្លាំងភ្លេចស្មារតីនោះទេ គឺអប់រំចិត្តឱ្យស្ថិតនៅក្នុងក្របខណ្ឌនៃសេចក្តីសន្តោស ផ្គងជីវិតឱ្យប្រព្រឹត្តទៅនៅក្នុងតម្រូវការ ដែលថារស់នៅក្នុងភាពល្មម អាចរស់បាន អាចបដិបត្តិតាមគុណធម៌ដោយល្អបាន ។

ព្រះអភិធម្ម ជាធម៌មិនវិបល្លាស មិនប្រែប្រួល ជាសភាវពិត មានន័យល្អិត សុខុមជ្រាលជ្រៅ ទោះបីជាពិបាកយល់ក៏ពិត ប៉ុន្តែសម្រាប់ជីវិតដែលធ្លាប់បានសិក្សា អប់រំបដិបត្តិ តាមសិក្ខាព្រះវិន័យ ព្រះសូត្រ ល្អហើយនោះប្រាកដជាមានឆន្ទៈ ក្នុងការស្វែងយល់អំពីសភាវធម៌គឺបរមត្ថនេះតាមសមគួរបាន ដោយមិនពិបាកពេកនោះទេ ព្រះពិជិតមារ ព្រះអង្គសម្តែងព្រះអភិធម្ម បើកបង្ហាញអំពីសភាវធម៌ពិត ដែលមានចិត្ត ចេតសិក រូប ព្រមទាំងព្រះនិព្វាន ជាបរិយោសាន ។ ព្រះអង្គសម្តែងអំពីចិត្ត ចេតសិក រូប ទាំងនេះបានលាតត្រដាង គ្របដណ្តប់ក្តោបក្រសោប ទាំងព្រះវិន័យ ព្រះសូត្រទាំងអស់ នឹងបានបញ្ជាក់ឱ្យកាន់តែច្បាស់ថា គ្រប់តែជីវិត ទោះបីជាមានប្រភេទផ្សេងៗគ្នា ដោយភាពជាតិកំណើតយ៉ាងណាក៏ដោយ ប៉ុន្តែជីវិតនេះស្មើដោយសភាវធម៌ គឺចិត្ត ចេតសិក រូប ឬហៅថាបញ្ចក្ខន្ធនេះឯង ដែលជា

សភាវពិត កើតមានហើយ ក៏ត្រូវតែរលត់ទៅវិញជាធម្មតា ទៅតាមលំដាប់កាលវេលា គឺជាអនិច្ចំ ទុក្ខំ អនត្តា ជាច្បាប់ធម្មជាតិ ដែលកើតមាន ដោយគ្មានបុគ្គលណា ជាអ្នកបង្កើតសោះឡើយ ហើយក៏គ្មានអ្នកណាម្នាក់ អាចកែប្រែកុំឱ្យជាយ៉ាងនោះបានដែរ ។

ដូច្នេះការសម្តែងព្រះអភិធម្ម ដើម្បីបង្ហាញបញ្ជាក់ ដល់សត្វលោកណាដែលមិនធ្លាប់សន្សំនិស្ស័យ ក្នុងការស្តាប់ អាន ទន្ទេញរៀន ឱ្យបានស្តាប់ បានអានទន្ទេញរៀន ដើម្បីបណ្តុះឧបនិស្ស័យ ក្នុងការស្វែងយល់អំពីសភាវពិត ក្នុងការឆ្លុះបញ្ចាំង អំពីជីវិតពិត និងបានធ្វើឱ្យអ្នកដែលធ្លាប់បានសន្សំឧបនិស្ស័យ ក្នុងការស្តាប់ព្រះអភិធម្មជាអនេកជាតិមកហើយ បានស្តាប់រឹងរឹតតែយល់ចូលចិត្ត អំពីសភាវពិត បណ្តុះបញ្ញាឱ្យកាន់តែប្រណីតឡើងទៀត ។

ការសិក្សាព្រះអភិធម្ម ឈ្មោះថាបានបង្កើនបញ្ញា ក្នុងការដឹងយល់ ស្គាល់ច្បាស់ ញែកចេញនូវបញ្ញត្តិ និងបរមត្ថ ព្រោះសត្វលោកតែងប្រកាន់ចាប់ក្តាប់ណែន យកចិត្ត ចេតសិក រូប ឬថាបញ្ចក្ខន្ធនេះថាជាសត្វ បុគ្គលជាខ្លួនប្រាណ ទើបឱ្យច្រឡូកច្របល់ យល់ថាបញ្ញត្តិជាបរមត្ថ បរមត្ថជាបញ្ញត្តិ ពុំអាចញែកចេញពីគ្នាបាន ។ ដូច្នេះកាលបើបានស្តាប់ព្រះអភិធម្ម ពីសំណាក់ព្រះមានព្រះភាគហើយ ក៏រមែងធ្វើឱ្យយល់ស្គាល់ចូលចិត្ត អំពីសភាវពិតរបស់ជីវិត និងបានកំណត់កត់សម្គាល់ ចំពោះការបដិបត្តិត្រឹមត្រូវទៅតាមមាគ៌ានៃព្រះធម៌ មិនប្រកាន់ហួងហែងថា ជាខ្លួនប្រាណទាំងបានពិចារណាឃើញដោយបញ្ញាថាទោះជា បញ្ញត្តិក្តី បរមត្ថក្តីសុទ្ធតែស្ថិតក្នុងភាពមិនទៀង ជាទុក្ខ

ជាអនត្តា គឺជាសាមញ្ញធម៌ទាំងអស់ ។

ទោះជាព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្មក្តី ត្រូវតែសិក្សាឱ្យបានយល់ស្គាល់ថាអ្វីជាបញ្ញត្តិ អ្វីជាបរមត្ថតាមសភាពពិត សូម្បីតែពោលស្តីពីវត្ថុ សម្ភារៈជារបស់មានវិញ្ញាណក្តី ឥតវិញ្ញាណក្តី ជាសត្វ ជាបុគ្គលជាខ្លួនប្រាណក្តី ជាភូមិឋាន ប្រទេសជាតិសាសន៍ក្តី ក៏នៅក្នុងក្របខណ្ឌនៃធម៌សុទ្ធតែនៅក្នុងភាពមិនទៀង ជាទុក្ខ ជាអនត្តា ពុំអាចតាំងនៅតាមសភាពដើមបាននោះឯង ។ ដូច្នេះកាលបើបានសិក្សា យល់ចូលចិត្ត តាមសភាវពិតនៃបរមត្ថធម៌រមែងដកហូតចិត្ត ដែលធ្លាប់តែប្រកាន់ហួងហែង ឱ្យបានងាកចេញ និងបានជម្រុញការបដិបត្តិ ឱ្យបានដល់ការឃើញគ្រប់នូវសភាវធម៌តាមសច្ចៈ គឺមានការកើតឡើងហើយ ក៏ត្រូវរលត់វិនាសបាត់បង់ទៅវិញជាធម្មតា កាលបើការប្រកាន់ហួងហែង បានធូរស្រាល សេចក្តីនឿយណាយ រមែងកើតមានជាជំហាន ឱ្យបានឈានដល់ការស្រាវជ្រាវយល់បរមត្ថធម៌ជាន់ខ្ពស់មួយកម្រិតទៀត គឺព្រះនិព្វានដែលព្រះទ្រង់ញាណ ព្រះអង្គបានត្រាស់ដឹងថា ជាគុណជាតិខ្ពស់ផុតអំពីចិត្ត ចេតសិក រូប ។ និព្វានជាគោលដៅសំខាន់បំផុតក្នុងព្រះពុទ្ធសាសនា ។

**ធម៌ព្រះសាស្តាអស្ចារ្យពេកក្រៃ អានចានយប់ថ្ងៃព្រះត្រៃបិដក**
**រៀនពិតឡូវកុំនៅដំអក់ សន្សំតក់ៗ បង្កក់និស្ស័យ ៗ**

*ដោយឧបាសក* **ហ៊ិម ឆាន់**

# បណ្ឌិត

(បទពាក្យប្រាំពីរ)

ជាតិជាបណ្ឌិតពិតអ្នកប្រាជ្ញ ឈ្លាសវៃច្នៃអាចស្រាយបញ្ហា
ទោះប្រាប់ប្រដៅជនផងគ្នា ឈរលើមាគ៌ាជាហេតុផល ។
ពន្យល់ណែនាំឱ្យចូលចិត្ត ប្រាកដជាក់ពិតឥតចម្ងល់
បង្កើតបញ្ញាការដឹងយល់ សម្រេចភោគផលសមប្រាថ្នា ៕

# ពាល

(បទពាក្យប្រាំពីរ)

សញ្ជាតិសត្វរុយនិងមមង់ ហិចហើរតម្រង់ស្រង់ក្លិនស្អុយ
ពាលមានគំនិតគិតប្រថុយ បណ្ដោយចិត្តស្លុយសាងបាបកម្ម។
ញុះញង់អេចអូចដូចសត្វមូស រករឿងប្រទូស្តជាប្រចាំ
ចិត្តឥតខន្តីអំណត់ទ្រាំ ខិតខំសន្សំសាងអកុសល ៕

ដោយឧបាសក **ម៉ុញ សាវ៉ាន**

# គោលដៅនៃព្រះពុទ្ធសាសនា

គ្រប់តែជីវិតរមែងប្រាថ្នាចង់បានសេចក្តីសុខ ស្អប់ខ្ពើមសេចក្តីទុក្ខ ក៏ប៉ុន្តែការស្វែងរកសេចក្តីសុខ ដំណោះស្រាយក្នុងការចេញចាកទុក្ខ ខុសដោយឡែកពីគ្នាទៅតាមសមត្ថភាព និងការប្រកាន់ខុសដោយឡែកពីគ្នា រហូតដល់ទៅមានគណាចារ្យ ជាច្រើន បានបង្កើតលទ្ធិសាសនាឡើងក្នុងលោកទៅតាមមហិច្ឆតា ការប្រាថ្នានិងការយល់តែរៀងៗ ខ្លួន ។ ការស្វែងរកសេចក្តីសុខ ក្នុងផ្នត់គំនិតជាបុថុជ្ជនរកឃើញដោយការបង្កើតកម្មវិធី និងការឃ្វេងយល់ក្នុងភាពជាបុថុជ្ជនធ្ងន់ដោយអំណាចកិលេស មាននិកាយខ្លះបង្កើតកម្មវិធី ក្នុងការស្វែងរកសេចក្តីសុខនោះ ផ្ទុយបញ្ញាសទិស ទៅតាមគំហើញ និងមហិច្ឆតារបស់ខ្លួន មានចិត្តគំនិតជាមិច្ឆាទិដ្ឋិ ប្រាថ្នាលាភសក្ការៈ ទោះបីជាដំណោះស្រាយបញ្ហាទុក្ខ ក្នុងការស្វែងរកសេចក្តីសុខបានខ្លះ ក៏បានត្រឹមលោកិយសុខ ឬជាសាមិសសុខប៉ុណ្ណោះ ដែលនៅច្របូកច្របល់លាយឡំផ្សំដោយសេចក្តីទុក្ខជាដដែលៗ ហ្នឹងឯង ។

ចំពោះការដោះស្រាយបញ្ហាទុក្ខ និងការស្វែងរកសេចក្តីសុខដែលកើតចេញពីព្រះពុទ្ធសាសនា ជាគោលការខុសផ្ទុយដោយឡែកព្រោះព្រះដ៏មានព្រះភាគ ព្រះអង្គបានឃ្វេងយល់ពីសង្សារវដ្ត និងសេចក្តីទុក្ខដែលកើតមានអំពីសង្សារវដ្ត ព្រមទាំងបច្ច័យនៃសេចក្តីទុក្ខនោះ លុះតែបានគ្រប់គ្រាន់ ព្រោះឃើញសេចក្តីទុក្ខគ្រប់ប្រការ កើតចេញអំពីវដ្តៈ ដែលមានកិលេសវដ្តៈ កម្មវដ្តៈ វិបាកវដ្តៈ ។

កិលេសវដ្ដៈ គឺជាសេចក្ដីប្រាថ្នា ការចង់បាន ចំណូលចំណង់ ជាហេតុឱ្យសាងកម្ម កាលបើកម្មកើតមានហើយ ទើបបង្កើតឱ្យមាន វិបាក ផលិតឱ្យមានខន្ធគឺនាម និងរូបជាប្រភពនៃទុក្ខទោសគ្រប់ប្រការ ដោយសារតែមានកងកិលេស ជាបច្ច័យបង្វិលទៅឥតបើប្រាកដ រក ទីបំផុតមិនមាន ។ ដរាបណាសត្វលោកពុំទាន់បានយល់ស្គាល់អំពីវដ្ដៈ ឱ្យបានច្បាស់ទេ ដរាបនោះ ទោះជាខំរកដំណោះស្រាយអំពីបញ្ហា សេចក្ដីទុក្ខ ដោយបង្កើតលទ្ធិសាសនាច្រើនប្រការ យ៉ាងណាក៏ដោយ ក៏ឈ្មោះថានៅក្នុងក្របខណ្ឌ ក្រោមអំណាចកងកិលេសទាំងអស់ ដំណោះស្រាយនោះ ពុំអាចរើរួចឱ្យផុតរត់ចាកសេចក្ដីទុក្ខបាន ព្រោះ តែគណាចារ្យនោះ ខ្លួនឯងសោតពុំបានយល់ស្គាល់ ប្រភពនៃសេចក្ដី ទុក្ខ ដែលតែងកើតចេញពីកងកិលេសទាំងពួង សូម្បីតែខ្លួនឯង មាន ចិត្តជាប់ស្អិតដោយអំណាចកិលេស កងកិលេសចោមរោមឡោមព័ទ្ធ ចាក់ស្រែះចិត្តទាំងយប់ថ្ងៃ ក៏ពុំអាចដឹងបានផង ។

ហេតុដូច្នេះ ចំពោះគោលដៅនៃព្រះពុទ្ធសាសនា ឃើញថា ខុសផ្ទុយពីលទ្ធិសាសនាផ្សេងៗ ទាំងនោះ មុននឹងប្រកាសសាសនា ព្រះសម្មាសម្ពុទ្ធ ព្រះអង្គបានព្យាយាមរៀនយល់ អំពីសេចក្ដីទុក្ខដែល ជាផល មានប្រភពកើតចេញពីហេតុគឺកងអកុសលចិត្ត និងអកុសល ចេតសិក បើពោលដោយបរមត្ថ បានដល់ចិត្ត ចេតសិក រូប នេះឯង កាលបើចិត្ត ចេតសិក រូបនេះ ស្ថិតនៅក្នុងភាពជាលោកិយវិស័យ ទោះបីជាមានកុសលចិត្តខ្លះ មហគ្គតចិត្តកើតបានខ្លះក្ដី ក៏រមែងត្រាច់ ទៅបានត្រឹមតែកាមភូមិ រូបភូមិ អរូបភូមិប៉ុណ្ណោះ ដែលពុំអាចឆ្លងផុត អំពីសេចក្ដីទុក្ខបាន ។

ព្រោះអាស្រ័យហេតុដូច្នោះ គ្រប់ទង្វើរបស់ព្រះសាស្តាព្រះសម្មាសម្ពុទ្ធ ក្នុងការដំណោះស្រាយ ចំពោះបញ្ហាសេចក្តីទុក្ខ និងស្វែងរកសេចក្តីសុខ គឺចាប់ផ្តើមរៀនយល់ សម្គាល់ឃើញសេចក្តីទុក្ខ ប្រភពនៃសេចក្តីទុក្ខ ទើបព្យាយាមបំពេញបារមីធម៌ តាំងពីនៅភាពជាបុថុជ្ជនបានឡើងភាពជាកល្យាណបុថុជ្ជន ដែលមាននាមថាជាព្រះបរម-ពោធិសត្វ ។ ការបំពេញបារមីធម៌ ឱ្យបាននាមថ្មីមួយទៀតថាជាពុទ្ធៈនោះ ព្រោះដោយអំណាចការយល់ឃើញ យល់ស្គាល់ពីសេចក្តីទុក្ខដែលមានប្រភពកើតចេញពីកងកិលេសទាំងពួង ព្រមទាំងអកុសលចិត្ត ពោរពេញដោយភាពងងឹត បិទបាំងពុំឱ្យឃើញនូវភាពពិត គឺអរិយសច្ចធម៌បាន ដូច្នេះការបំពេញបរមី ជាបញ្ញាធិក របស់ព្រះសមណគោតមបរមគ្រូនៃយើងរហូតគ្រប់ធួនចំនួន បានសម្រេចមគ្គ-ផល កាត់ប្រហារកងកិលេស ឱ្យអស់ពីខន្ធសន្តានរបស់ព្រះអង្គដោយអំណាចអដ្ឋមគ្គទាំងប្រាំបីប្រការ ធ្វើឱ្យដួងព្រះទ័យរបស់ព្រះអង្គថ្លាបរិសុទ្ធ ឆ្លុះបញ្ចាំងឃើញនូវអរិយសច្ចធម៌បួនប្រការគឺ សេចក្តីទុក្ខហេតុនាំឱ្យកើតសេចក្តីទុក្ខ ទីរំលត់សេចក្តីទុក្ខមគ្គាបដិបទាជាខបដិបត្តិ ដើម្បីរំលត់សេចក្តីទុក្ខនោះៗ ។

ក្នុងពេលដែលចិត្ត ឥតមានកងកិលេសធ្វើឱ្យកករល្អក់ ចិត្តបានប្រែភាពថ្លាបរិសុទ្ធស្អាត ជាហេតុឱ្យឆ្លុះបញ្ចាំងបាននូវភាពភ្លឺស្វាងនិងការដឹងយល់ដល់កម្រិតកំពូល ដែលហៅថា (សព្វញ្ញុតញ្ញាណ) គឺការត្រាស់ដឹងយល់ឃើញសព្វជុំវិញ ដោយឥតមានទើសទាល់ចន្លោះត្រង់កន្លែងណាសោះឡើយ ដូច្នេះហើយព្រះអង្គបានទទួលនាមថ្មីមួយទៀតថាជាព្រះពុទ្ធ ដែលប្រែថា អ្នកត្រាស់ដឹង ពីច្បាប់ធម្មជាតិ គឺ

ព្រះធម៌ ព្រមទាំងហេតុបច្ច័យ ការកើតរលត់នៃចិត្ត ចេតសិក រូប ឬ ភាពចម្រើន វិនាស សុខ ទុក្ខ ដំណោះស្រាយគ្រប់បញ្ហា ដែលកើតមានជុំវិញជីវិតនោះៗ ដោយឥតមានទើសទាល់សោះឡើយ ។

ដោយភាពជាក់លក្ខណ៍ ពិតប្រាកដក្នុងផ្នត់គំនិត ព្រមទាំងការកំណត់ច្បាស់ ក្នុងហេតុការណ៍ ដែលកើតមានព្រមទាំងគោលដៅរបស់ជីវិតពិតដូច្នេះហើយ ទើបការផ្សាយព្រះពុទ្ធសាសនា របស់ព្រះសាស្តាសម្មាសម្ពុទ្ធ ខុសប្លែកពីសាសនាដទៃ ដោយគ្មានច្របូកច្របល់ច្រឡំលាយជាមួយសាសនា ឬនិកាយផ្សេងៗ នោះទេ ព្រោះព្រះពុទ្ធសាសនា រចនាបង្កើតបានពីពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធ, ព្រះពុទ្ធបុគ្គលប្រាសចាកកិលេសពីខន្ធសន្តាន ជាបុគ្គលមានចិត្តបរិសុទ្ធស្អាត ជាបូជនិយបុគ្គលគួរគោរពបូជា វន្ទាសំពះ ព្រះអង្គលែងមានការជាប់ជំពាក់ ដោយលោកធម៌ទៀតហើយ ។ ដូច្នេះការប្រកាសសាសនារបស់ព្រះអង្គ ប្រកបដោយព្រះទ័យករុណា ប្រាថ្នាឱ្យបានជាគុណប្រយោជន៍ដល់សត្វលោក គឺឱ្យសត្វលោកដែលមានឧបនិស្ស័យ បានស្តាប់ព្រះអង្គ ហើយមានការកើតឡើងនៃបញ្ញា យល់ដឹងពីសភាវពិតរបស់ព្រះធម៌ដោយខ្លួនឯង នឹងបានជាចំណែកមួយក្នុងការបដិបត្តិដើម្បីចេញចាកសេចក្តីទុក្ខ ដោយការមិនជាប់ជំពាក់ក្នុងចិត្ត ចេតសិក រូប ព្រោះការប្រកាន់ហួងហែង ថាជាសត្វ ជាបុគ្គលខ្លួនប្រាណ ដែលជាប្រភពនៃសេចក្តីទុក្ខគ្រប់ប្រការ ដែលសត្វលោកពុំងាយដឹងយល់ស្គាល់ និងពុំអាចគេចផុតរត់ឱ្យរួចបាន ប្រសិនណាពុំមានព្រះពុទ្ធត្រាស់ដឹងឡើងក្នុងលោក ត្រាស់បើកបំភ្លឺបង្ហាញនោះទេ ។

ដូច្នេះទើបការត្រាស់សម្តែង ពីសភាវធម៌ដែលប្រាកដបួនប្រការ ដែលហៅថា បរមត្ថធម៌នេះមាន ចិត្ត ចេតសិក រូប បីប្រភេទនេះជាសង្ខតបច្ច័យ ឬថា សង្ខតធម៌ ជាធម៌មានបច្ច័យតាក់តែង និងមានការកើត និងការរលត់នៅក្នុងសង្សារវដ្តនេះ ដែលគ្មានសាសនា ឬគណាចារ្យនិកាយដទៃណា អាចយល់ដល់ជម្រៅ និងលើកយកមកសម្តែង ថ្លែងពន្យល់បាន ក្រៅពីព្រះដ៏មានព្រះភាគតែប៉ុណ្ណោះ ។

បន្ទាប់អំពីសម្តែងបង្ហាញអំពី ចិត្ត ចេតសិក រូប ដែលជាលោកិយវិស័យ ឱ្យឃើញថាជាប្រភពនៃសេចក្តីទុក្ខហើយ ទើបព្រះអង្គទ្រង់សម្តែងបើកបង្ហាញពីព្រះនិព្វាន ថាជាធម្មជាតិមួយប្រភេទផុតស្រឡះចាក ចិត្ត ចេតសិក រូប ពីព្រោះនិព្វាន ជាគោលដៅឬជាចំណុចតែម្យ៉ាង រំលត់ចាកខន្ធ ដែលជាផលរបស់កម្ម ដោយមានកិលេសជាមូល ដូច្នេះនិព្វានអាចកំចាត់នូវវដ្តៈ មានកិលេសវដ្តៈ កម្ម-វដ្តៈ វិបាកវដ្តៈ ។ កាលបើវដ្តៈគ្មាន ភពក៏គ្មាន ខន្ធក៏មិនមាន, កាលបើខន្ធមិនមានហើយ សេចក្តីទុក្ខរមែងមិនមាន, កាលបើទុក្ខមិនមានហើយ ទើបមានតែសេចក្តីសុខស្ងប់តែម្យ៉ាងប៉ុណ្ណោះ ទើបឈ្មោះថាជានិព្វាន ព្រោះមានសេចក្តីស្ងប់ជាលក្ខណៈ ពុំមែននិព្វានសូន្យ ដោយគ្មានការសម្គាល់នោះទេ ឬនិព្វានគ្មានប្រាកដជាសញ្ញារហូតឱ្យយើងគេមាន ចម្ងល់ដល់ទៅយល់ ចូលចិត្តមិនបាននោះទេ ។ ត្រង់ពាក្យថាសូន្យ ក៏ស្មើនឹងពាក្យថាគ្មាន គឺសូន្យចាកហេតុ ពោលគឺកងកិលេសមាន អវិជ្ជា តណ្ហា ឧបាទាន កម្ម ឬថាសូន្យចាកអកុសលចិត្តទាំងអស់ដែលជាប្រភពនៃកងទុក្ខ ។


ជីវិតកថា
រៀបរៀងដោយ
ខ្ញុំព្រះករុណា ខ្ញុំបាទ មិញ សាវ៉ាន
ព.ស. ២៥៥៤ - គ.ស.២០១០
សម្រាប់ជាធម្មទាន

# តើគេអាចស្គាល់
## និព្វានបានដូចម្ដេច?

បើនិព្វានមានត្រឹមតែឈ្មោះ ឥតមានរូបរាងសណ្ឋាន ពណ៌សម្បុរដូច្នេះ ឃើញថាមានការរសាប់រសល់ យល់បានដោយពិបាកពិតមែន រហូតដល់អ្នកខ្លះខ្វះជំនឿ លែងចង់ស្ដាប់ ចង់ឮ ពីពំនោលនៃព្រះនិព្វាន ឬមានគំនិតថា និព្វានមានត្រឹមតែពំនោលប៉ុណ្ណោះ មិនខុសពីពាក្យស្រមើស្រមៃទេ គំហើញបែបនេះ រមែងមាននៅក្នុងផ្នត់គំនិតម្នាក់ៗ ដែលមានការស្រពេចស្រពិល ថែមទាំងខ្ជិលចង់ស្ដាប់ ចង់ឮពីពំនោលនៃនិព្វានទៀតផង ។ អ្វីដែលនៅពុំទាន់បានយល់ ឬនៅពុំទាន់បានស្គាល់ ក៏រមែងនៅមានចម្ងល់ ដូច្នោះជាធម្មតា ដែលគ្មាននរណាម្នាក់អាចប្រកែកបាន កុំថាឡើយចំពោះពំនោលនៃព្រះនិព្វាន ដែលជាវិស័យនៃព្រះអរិយជន ឬថាជាវិស័យនៃលោកុត្តរចិត្តនោះ សូម្បីតែភាពជាបុថុជ្ជនស្ថិតនៅក្នុងភាពជាលោកិយវិស័យ ក៏ពុំអាចដឹងយល់ស្គាល់អ្វីដែលនៅពុំទាន់បានស្គាល់ បានយល់ជួបឃើញប្រទះអ្វីៗដែលមាននៅក្នុងលោកិយនេះបាននោះទេ ដូចជាអ្នកធ្លាប់បរតែរទេះគោ ពុំដែលធ្លាប់បានយល់ ស្គាល់ឃើញរថយន្ត, ប្រសិនបើមានអ្នកធ្លាប់ បានស្គាល់ យល់អំពីការបើកបររថយន្ត បានមកពិពណ៌នារៀបរាប់ អំពីរូបរាងសណ្ឋានពណ៌រថយន្ត ឱ្យអ្នកដែលពុំធ្លាប់បានស្គាល់ស្ដាប់ ក៏បានត្រឹមតែការស្ដាប់ និងនៅមានចម្ងល់ដដែល ព្រោះពុំធ្លាប់បានស្គាល់ និងមិនធ្លាប់បានឃើញ តែបើបានទៅឃើញ ទៅ

ស្គាល់ហើយក៏ដោយ ក៏គង់នៅតែមានចម្ងល់ថាតើរថយន្តនេះ ត្រូវបើកបរទៅបែបណា ។ ការសង្ស័យ និងការងឿងឆ្ងល់ រមែងនៅមាន ព្រោះពុំទាន់បានរៀនអំពីការបើកបរឱ្យបានយល់ចេះ ដូច្នេះការដែលនិយាយរៀបរាប់ រូបរាងសណ្ឋានពណ៌រថយន្ត ពុំបានស្មើនឹងការបានឃើញ បានយល់ស្គាល់ផ្ទាល់ដោយខ្លួនឯង ឯការគ្រាន់តែបានស្ដាប់ការអធិប្បាយរៀបរាប់ពន្យល់ អំពីវិធីនៃការបើកបរ មិនប្រសើរស្មើនឹងការរៀនឱ្យចេះដឹងយល់ ក្នុងការបើកដោយខ្លួនឯងផ្ទាល់ ។ន័យនេះយ៉ាងណា ការរៀបរាប់អំពីព្រះនិព្វាន រឹងរឹតតែមានជម្រៅ និងមានភាពស្មុគស្មាញ ឱ្យពិបាកយល់ចូលចិត្ត ចំពោះបុថុជ្ជនគ្រប់រូប ដែលនៅពុំទាន់ពាល់ត្រូវព្រះនិព្វាន ពាក្យថាមិនទាន់ពាល់ត្រូវបានដល់ខណៈចិត្ត ដែលពុំទាន់បានយល់ ស្គាល់ ឈោងដល់ព្រះនិព្វានជាអារម្មណ៍ដូចជា អរិយបុគ្គលថ្នាក់សោតាបន្ននៅឡើយ ។ ដូច្នេះកាលបើគេមានឆន្ទៈក្នុងការឈ្វេងយល់អំពីព្រះនិព្វានគេនឹងយកចិត្តទុកដាក់ព្យាយាមត្រិះរិះពិចារណា ស្រាវជ្រាវរាវរករៀនយល់ ដោយការស្ដាប់ អានតាមលំនាំហេតុផលនៃព្រះនិព្វាន រហូតមានបញ្ញា បានយល់ហេតុផលបំបាត់ ចម្ងល់ខ្លះៗ ជាក់ជាមិនខាន កាលបើចម្ងល់បានរសាយចេញពីផ្នត់គំនិតហើយ គេប្រាកដជាអាចទទួលស្គាល់ យល់ ចូលចិត្តពីពាក្យថានិព្វានដោយខ្លួនឯងពិត ឥតចាំបាច់មានអ្នកណាមកបង្ខិតបង្ខំសោះឡើយ ។

ការដែលព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់ត្រាស់សម្ដែងពីនិព្វានមានកម្រិតខ្ពស់ផុតដោយឡែក ពីបរមត្ថធម៌បីប្រភេទគឺ ចិត្ត ចេតសិក រូប ដែលស្ថិតនៅក្នុងភាពជាលោកិយវិស័យ ដូច្នេះព្រះនិព្វានមានភាព

ជាលោកុត្តរ ដែលសព្វសត្វក្នុងលោក យល់ដឹងបានដោយកម្រពេក ណាស់ តែទោះបីជាយ៉ាងណា ការសម្តែងពីព្រះនិព្វាន បានបញ្ជាក់ពីទឹកព្រះទ័យ មហាករុណាទិគុណក្នុងការចម្លងសត្វលោក ឱ្យបានយល់ស្គាល់គោលដៅ និងទីស្នាក់ចតនៃជីវិតមួយពិតប្រាកដ ជាចុងបញ្ចប់នៃភាពអន្ទោល និងបានជាចំណែកមួយ ដល់ពពួកសត្វដែលមានការនឿយណាយ លែងសប្បាយធុញទ្រាន់ ដោយភាពក្លែងបន្លំ ផ្សំដោយក្តីទុក្ខសោក ក្នុងទ្រុងដែលពាសព័ទ្ធដោយកំពែងរនាំងដែក ដ៏សែនក្រាស់ឃ្នឹកនៃភព ព្រមទាំងមានការគំរាមកំហែង ដាក់អាជ្ញាទោសទណ្ឌយ៉ាងសែនទារុណកម្មយង់ឃ្នង ពីពួកសេនា និងមច្ចុរាជទាំងយប់ថ្ងៃ ។ ដោយការពិចារណាឃើញ ទុក្ខទោសអាជ្ញាទណ្ឌដូច្នោះហើយ ទើបធ្វើឱ្យមានការនឿយណាយ ស្វែងរកដំណោះស្រាយដោយឡែកមួយ ដើម្បីធ្វើឱ្យជីវិតនេះ មានឥស្សរៈ សេរីភាព គោលដៅ ទីស្នាក់ចតពិតប្រាកដ លែងមានការស្រពេចស្រពិល រសេមរសាមទៀតហើយ ដោយបានត្រាច់តាមមាគ៌ា និងដំណោះស្រាយ ដែលហួរចេញពីផ្ទត់គំនិត ប្រាកដដោយបញ្ញាយ៉ាងច្បាស់លាស់តាមព្រះពុទ្ធដីកា ដោយព្រះមហាករុណាទិគុណ បានសម្តែងបង្ហាញបើកពីព្រះនិព្វាន ។

តើព្រះនិព្វានមាននៅជិតឬនៅឆ្ងាយ តើនៅខាងអាយឬនៅខាងនាយ? សូមបរិយាយឱ្យបានស្តាប់បន្តទៅទៀតផងមើល៍!....

ពិតមែនហើយ ចំពោះលោក-អ្នកដែលធ្លាប់បានអាន ស្តាប់សិក្សាសូត្ររៀន តាមគម្ពីរត្រៃបិដក ព្រះពុទ្ធដីកាបានបញ្ជាក់ថា សត្វលោក ឬថាសង្សារវដ្តនេះ ជាត្រើយខាងអាយ ឯព្រះនិព្វានជាត្រើយ

ខាងនាយ បានជាព្រះភគវាទ្រង់ត្រាស់សម្ដែងថា ព្រះនិព្វានជាត្រើយខាងនាយនោះ ក៏ប្រៀបបីដូចនិព្វាននៅឆ្ងាយ មានគម្លាតពីសង្សារវដ្ត ឬសត្វលោក ដែលពេញប្រៀបទៅដោយកងកិលេស មានអវិជ្ជា តណ្ហា ឧបាទាន កម្ម ចងចាក់ស្រែះ ហ៊ុមព័ទ្ធ ប្រក់បាំងធ្វើឱ្យចិត្តងងឹតអន្ធការ ឥតមានបញ្ញាចាក់ធ្លុះ ធ្លុះបញ្ចាំងឱ្យយល់ពីព្រះនិព្វានបាន ទើបចាត់ថាព្រះនិព្វានមាននៅឆ្ងាយជាត្រើយខាងនាយ ។

ចំណែកពពួកសត្វ ដែលមានឧបនិស្ស័យខ្ពស់ពីអតីតជាតិ ធ្លាប់បានសន្សំអប់រំបន្ទំទុក ដោយការសិក្សាស្ដាប់ បដិបត្តិតាមមាគ៌ាព្រះសាស្ដាសម្មាសម្ពុទ្ធជាអនេកជាតិមកហើយ ទាំងបានព្យាយាមដុសខាត់ កំចាត់បង់កងកិលេសឱ្យបានជ្រះស្រឡះ អស់ពីខន្ធសន្ដានតាមលំដាប់ថ្នាក់ មានឧស្សាហៈអប់រំបន្ទំបណ្ដុះបញ្ញាឱ្យកើតមាន បានជាពន្លឺធ្លុះបញ្ចាំងឃើញយល់ ស្គាល់បានពីព្រះនិព្វាន ដោយគ្មានការស្រពិចស្រពិល ដូចជាព្រះអរិយបុគ្គល តាំងពីថ្នាក់សោតាបន្នឡើងទៅ សកទាគាមី អនាគាមី ព្រះអរហន្ត លោកបានយល់ស្គាល់និព្វានប្រចក្សច្បាស់ដោយចិត្តខ្លួនឯង ដោយឥតមានការសង្ស័យ ស្រពិចស្រពិលទៀតឡើយ ហើយក៏ពុំចាំបាច់សួរព្រះមានព្រះភាគ អំពីព្រះនិព្វាននោះទៀតទេ ព្រោះបានដឹងពិតឃើញពិតដោយខ្លួនឯង ដូចជាអ្នកបរិភោគអាហារឆ្អែត គ្រប់ធ្គួនល្មមបរិបូណ៌ហើយ ក៏ឈប់លែងបរិភោគដោយខ្លួនឯង មិនចាំបាច់ទៅស្រែកសួរ អ្នកដទៃថាតើខ្ញុំឆ្អែតឬនៅ? ដូច្នោះឡើយ ។

ចំពោះព្រះសោតាបន្ន ដែលលោកបានឆ្លងភាពពីបុថុជ្ជនឡើង

កាន់ភាពជាអរិយជនថ្នាក់ដំបូង ឬថាថ្នាក់ខាងដើម គឺលោកមានក្រសែចិត្តហូរទៅកាន់និព្វាន គឺខណៈចិត្តដំបូងរបស់លោក កើតឡើងហើយពាល់ត្រូវព្រះនិព្វាន ដោយចិត្តឈោងយកព្រះនិព្វានមកជាអារម្មណ៍ ដែលថាឃើញនិព្វាន លែងមានការសង្ស័យអ្វីទៀត ទើបបន្លឺវាចាយ៉ាងនេះថា (**ធម្មជាតិណាមានកិរិយាកើតឡើងហើយ ធម្មជាតិនោះមានកិរិយារលត់ទៅវិញជាធម្មតា**) ចំពោះព្រះអរហន្ត ជាព្រះអរិយថ្នាក់ខ្ពស់បានចាក់ធ្លុះនូវព្រះនិព្វាន ទាំងបានជម្រុះកិលេស ដោយឥតមានសេសសល់ក្នុងខន្ធសន្តាន លោកតែងពោលវាចាយ៉ាងនេះថា (**អាត្មាអញដឹងថាជាតិអស់ហើយ ព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញ បានធ្វើស្រេចហើយ មគ្គភាវនាកិច្ចប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនោះទៀត ពុំមានទេ**) ទាំងនេះជាឧទានវាចារបស់ព្រះអរិយបុគ្គលតាំងពីថ្នាក់ដំបូង រហូតដល់ថ្នាក់ទីបំផុតជាសន្ទិដ្ឋិកោ គឺដឹងច្បាស់ឃើញច្បាស់ដោយបច្ចវេក្ខណញ្ញាណពិតៗ ឥត មានការសង្ស័យទៀតឡើយនេះទើបពោលថា ព្រះនិព្វានមាននៅជិតខាងអាយមិនឆ្ងាយអំពីចិត្តនៃព្រះអរិយបុគ្គលទាំងឡាយនោះទេ ។

ត្រង់ដែលមានសំណួរថា តើដឹងព្រះនិព្វានបានដូចម្តេច បើព្រះនិព្វានគ្រាន់តែជានាមធម៌?.. ពិតជាដូច្នោះមែន និព្វានគ្រាន់តែនាមធម៌ តែគ្មានរូបសណ្ឋាន ពណ៌សម្បុរ តើមានអ្វីទៅអាចបញ្ជាក់ឱ្យដឹងបានថា និព្វានមានពិតនោះ ត្រង់ចំណុចនេះដែលថាមាន អាចបញ្ជាក់ថាអ្វី ដែលអាចយល់ស្គាល់និព្វានបាននោះ ក៏គឺចិត្តដែលជានាមធម៌ដូចគ្នា គឺលោកុត្តរចិត្តតែមួយប្រភេទតែប៉ុណ្ណោះ ទើបអាចបានលុះដល់ពាល់ត្រូវនិព្វានបាន ។ ព្រោះហេតុដូច្នេះហើយ បានជា

ក្នុងបរមត្ថធម៌ប្រភេទនៃចិត្ត ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់សម្តែង វែកញែក ចែកចេញជាបួនប្រភេទនៃចិត្តផ្សេងដោយឡែកពីគ្នា មាន កាមាវចរចិត្ត សំដៅដល់ចិត្ត ដែលត្រាច់រង្គាត់នៅក្នុងកាមភូមិ គឺចិត្ត ដែលនៅអន្ទោលក្នុងភពសម្បូរដោយកាម រាប់យកតាំងពីអបាយភូមិ បួន មនុស្សមួយ ទេវតាប្រាំមួយជាន់ រួមត្រូវជាដប់មួយជាន់។ រូបព្រហ្ម ដប់ប្រាំមួយ អរូបព្រហ្មបួន ។ ចិត្តណាដែលត្រាច់ទៅនៅក្នុងរូបភូមិ ហៅថារូបាវចរចិត្ត សំដៅយកព្រហ្មដែលមានរូប ចិត្តណាដែលត្រាច់ ទៅ នៅក្នុងអរូបភូមិក្នុងភពនៃព្រហ្មដែលគ្មានរូប ហៅថាអរូបាវចរចិត្ត ចិត្តទាំងបីប្រភេទដូចបានពោលរៀបរាប់មកនេះ កាមាវចរចិត្ត ពុំអាច យល់ដល់រូបាវចរចិត្តបាន រូបាវចរចិត្ត ពុំអាចយល់ដឹងពីអរូបាវចរចិត្ត បាន ហើយចិត្តទាំងបីនេះ ក៏ពុំអាចយល់ដឹងពីលោកុត្តរចិត្ត និងព្រះ និព្វានបាន ប្រៀបដូចជាមនុស្សដែលដើរឡើងលើកំពូលភ្នំ កាលបើ ដើរដល់ជើងភ្នំ ក៏ពុំទាន់អាចយល់ដឹង ថានៅឯចង្កេះភ្នំមានអ្វីៗ ឱ្យ ប្រាកដច្បាស់បាន រីឯអ្នកឡើងដល់ចង្កេះភ្នំ ក៏ពុំអាចយល់ស្គាល់ដឹង ច្បាស់ អំពីស្ថានភាពលើកំពូលភ្នំបានដែរ ។ ចំណែកអ្នកដែលបាន ឡើងដល់កំពូលភ្នំហើយ ទើបអាចជ្រាបច្បាស់ដឹងយល់ ស្គាល់ចូល ចិត្តតាំងពីជើងភ្នំ ចង្កេះភ្នំ កំពូលភ្នំ ទើបអាចសម្លឹងដឹងយល់ពីខាងលើ រហូតមកខាងក្រោមបាន ។ ន័យនេះយ៉ាងណាមិញ ចំណែកឯប្រភេទ ចិត្តទីបួន គឺលោកុត្តរចិត្ត ជាចិត្តដែលឆ្លងផុតខ្ពស់ហួស ពីចិត្តទាំងបី ប្រភេទខាងដើម ជាចិត្តដែលបានមកពីការអប់រំ បដិបត្តិតាមអង្គ វិបស្សនា មានបញ្ញាឆ្លុះបញ្ចាំង ឃើញកងកិលេស ប្រកបដោយកម្លាំង គឺមគ្គ និងក្នុងការកាត់ផ្តាច់ កងកិលេសតាមលំដាប់ថ្នាក់ ជាសមុច្ឆេទ

ដោយឥតមានសេសសល់ ជាចិត្តមានកម្រិតខ្ពស់ ទើបអាចពាល់ដល់យល់ច្បាស់ពីព្រះនិព្វានបាន ដូចជាអ្នកដែលឡើងដល់លើកំពូលភ្នំហើយ អាចចោលភ្នែកក្រឡេកយល់គ្រប់ទិសទស្សន៍ទាំងអស់ ដោយច្បាស់បាន។ លោកុត្តរចិត្តនេះ ជាចិត្តដែលកើតមួយខណៈក្នុងសង្សារវដ្តហើយក៏រលត់ទៅ ជាចិត្តដែលមានគោលដៅកំណត់ ជាក់ច្បាស់ប្រាកដ គឺព្រះនិព្វាន ទើបពោលថា មានតែលោកុត្តរចិត្តនេះទេ ដែលអាចយល់ ស្គាល់ ដឹងនូវព្រះនិព្វាន ។

ដើម្បីបានជាលោកុត្តរចិត្ត គេត្រូវព្យាយាមហ្វឹកហាត់ចិត្ត តាមមាគ៌ាពីរប្រការ គឺ**សមថៈ** និង **វិបស្សនា** ។ ការអប់រំចិត្តដោយ **សមថៈ** បានដល់ ធ្វើចិត្តឱ្យស្ងប់ចាកនីវរណកិលេស ជាបរិយុដ្ឋានកិលេស ជាកិលេសថ្នាក់កណ្តាល កាលបើចិត្តស្ងប់ ជាឯកគ្គតា នឹងក្នុងអារម្មណ៍តែមួយ ទើបហៅថា **សមាធិ** ក្នុងកាលដែលចិត្តស្ងប់ ជាសមាធិបានត្រឹមតែមួយខណៈៗ ហៅថា**ខណិកសមាធិ** កាលណាចិត្តស្ងប់បានរហូតដល់ជិតនេបនិត្យកាន់ឈាន ហៅថា**ឧបចារសមាធិ** នៅពេលដែលចិត្តស្ងប់ បានឡើងកាន់ឈាន ហៅថា**អប្បនាសមាធិ** ពាក្យថា **ឈាន** បានដល់ការសម្លឹងមើលអារម្មណ៍ សំដៅដល់ការសម្លឹងមើលកសិណណាមួយ មានបឋវីកសិណជាដើម រហូតដល់បាននិមិត្តបី ៖ មានបរិកម្មនិមិត្ត និមិត្តក្នុងការបរិកម្មភាវនា, ឧគ្គហនិមិត្ត និមិត្តដែលជិតដក់ជាប់ក្នុងចិត្ត គឺចាំបានសណ្ឋានពណ៌, បដិភាគនិមិត្ត អាចពង្រីកនិមិត្តតាមចិត្តយោគាវចរ មានបំណងប្រាថ្នា ឱ្យតូចធំតាមបាន តាមចំណង់ប្រាថ្នារបស់ចិត្ត ឈានដែលបានពីសមាធិចិត្ត អាចគ្របសង្កត់កិលេសបានដោយខណៈៗ ក្នុងកាលដែលចិត្តកំពុងស្ងប់ហៅថា

**តង្គណិកសមាធិ** ។ ការដែលរម្ងាប់កិលេសបាន ដូចជាយកដុំថ្មទៅសង្កត់លើស្មៅ កាលបើយកថ្មចេញ ស្មៅក៏ដុះងើបមកវិញដដែល ហៅថា **វិក្ខម្ភណសមាធិ** សមាធិទាំងពីរប្រការ ចាត់ថាជាលោកិយ ឬ ហៅថាលោកិយឈានយ៉ាងនេះក៏បាន រម្ងាប់កិលេសបាន នៅពេលដែលឈានកើតឡើង ។ កាលបើឈានចិត្តសូន្យទៅ កិលេសរមែងមានឱកាសកើតវិញដដែល ចំណែកឯការរម្ងាប់កងកិលេសបាន ដោយការផ្តាច់ផ្តិល ដូចការជីកស្មៅទាំងឫស មិនឱ្យកើតវិញបាន ហៅថា**សមុច្ឆេទសមាធិ** នេះគឺជាលោកុត្តរសមាធិ ឬ ហៅថាលោកុត្តរ-ឈាន ជាសមាធិចិត្ត ឬជាឈានចិត្តរបស់ព្រះអរិយបុគ្គលទាំងពួង ឬ ន័យម្យ៉ាងទៀត ឈាននេះសំដៅដល់ការដុតកម្លោចនូវកិលេស បានន័យថាកាត់កិលេសឱ្យជ្រះស្រឡះពីខន្ធសន្តាន ព្រោះថាកាលបើកិលេសនៅមានដរាបណា ក៏ឈ្មោះថានិព្វានក៏គ្មានដរាបនោះ ពាក្យថានិព្វានគ្មាន សំដៅត្រង់ចិត្តងងឹត កករល្អក់ពុំអាចឃើញនិព្វាន ដូចបានពោលរៀបរាប់រួចមកហើយ សូម្បីចិត្តជាប្រភេទកុសល ហៅថាកាមាវចរកុសល រូបាវចរកុសល អរូបាវចរកុសលក្តី ក៏ចិត្តទាំងនេះគ្រាន់តែជាកម្លាំងជំនួយដល់លោកុត្តរកុសលចិត្តតែប៉ុណ្ណោះ ព្រោះពុំអាចប្រហារបង់កិលេសឱ្យអស់បាន ប្រសិនបើកិលេសនៅមាននិព្វានក៏មានគម្លាតឆ្ងាយ ដូច្នេះដើម្បីអប់រំចិត្តឱ្យបានកម្រិតខ្ពស់ហួសពីចិត្តទាំងបីប្រភេទ ឱ្យបានជាលោកុត្តរចិត្ត ឬថាជាលោកុត្តរកុសល-ចិត្ត ទើបមានមាគ៌ាវិបស្សនា គឺជាមាគ៌ាប្រកប ដោយបញ្ញា ដើម្បីលើកស្ទួយអប់រំចិត្ត ឱ្យមានកម្រិតខ្ពស់ ឆ្លងហួសអំពីចិត្តជាលោកិយបាននាមជាចិត្តថ្មីមួយដោយឡែក ហៅថា **លោកុត្តរចិត្ត** ។

វិបស្សនាបានដល់បញ្ញា ដែលពិចារណាឃើញច្បាស់អំពីសង្ខារ ទោះបីជាសមាធិក្តី វិបស្សនាក្តី សុទ្ធតែប្រសូតចេញពីព្រះឱស្ឋរបស់ព្រះសាស្តាសម្មាសម្ពុទ្ធ ព្រោះសមថវិបស្សនា ទុកដូចជាឃ្នាបសម្រាប់កៀបចិត្ត ឱ្យរីងស្ងួតហួតហែងចាកកងកិលេស ពេលខ្លះព្រះអង្គទ្រង់ត្រាស់សំដែងថា សមាធិជាបាទ ជាគ្រឿងទ្រដល់វិបស្សនា ពេលខ្លះព្រះអង្គទ្រង់ត្រាស់ថា វិបស្សនាជាបាទ ជាគ្រឿងទ្រដល់សមាធិ ប៉ុន្តែទោះបីជាចិត្តស្ងប់ប្រកបដោយសមាធិក៏ដោយ សុទ្ធតែត្រូវមានបញ្ញា ជាគ្រឿងប្រកបព្រម ទើបអាចកំចាត់នូវអនុស័យ-កិលេសឱ្យអស់ នឹងបានធ្វើចិត្តឱ្យជាលោកុត្តរ ឆ្លងចាកលោកិយចិត្ត ឬថាឱ្យបានជាលោកុត្តរកុសល ដែលថាសម្រេចមគ្គផល យល់ស្គាល់ព្រះនិព្វានបាន ។ ដូច្នេះមាគ៌ាវិបស្សនា ក៏គឺបញ្ញាក្នុងការពិចារណាឃើញច្បាស់ទុក្ខទោសរបស់សង្ខារ ដែលស្ថិតនៅក្រោមអំណាចនៃអនិច្ចំ ទុក្ខំ អនត្តា មានការកើតរលត់ ឥតបើតាំងនៅ ។ ពិចារណាឃើញ ទុក្ខទោសច្រើនប្រការ ដែលតែងកើតមានអំពីសង្ខារ រហូតធ្វើឱ្យចិត្តនឿយណាយធុញទ្រាន់ លែងមានចិត្តជាប់ជំពាក់ លែងសោកស្រណោះ អាឡោះអាល័យ យប់ថ្ងៃ គិតរំពៃរកផ្លូវចេញចាកឱ្យបានផុត រត់ឱ្យបានពីសង្ខារនោះៗ ។

កាលបើព្រះយោគាវចរ ព្យាយាមបដិបត្តិតាមមាគ៌ាវិបស្សនា មានបញ្ញាចាស់ក្លា រហូតដល់បានញាណមួយ ហៅថា**គោត្រភូញាណ** ជាញាណមួយកន្លងចាកភាពជាលោកិយវិស័យ បញ្ញាចាស់ក្លាពិចារណា អនុលោមតាមពោធិបក្ខិយធម៌ ទាំងសាមសិបប្រាំពីរប្រការ ចិត្តបរិសុទ្ធថ្លាស្អាត ដោយបានសម្រេចដល់មគ្គនិងផល កាត់ផ្តាច់

កិលេសបានតាមលំដាប់ថ្នាក់ ជាសមុច្ឆេទប្បហានៈ ជាចិត្តបានឆ្លង ចាកភាពជាបុថុជ្ជន ឡើងកាន់ភាពជាអរិយជន ទើបបានចិត្តជាលោកុត្តរ ពិចារណានូវមគ្គនិងផល មានព្រះនិព្វានជាអារម្មណ៍ ដូច្នេះ ទើបបានពោលតាមបរមត្ថភាសាថា ព្រះនិព្វានត្រូវបានដឹងដោយលោកុត្តរចិត្ត ។

បើពោលដោយបុគ្គលបញ្ញត្តិ បានដល់ព្រះអរិយបុគ្គលទាំងបួនពួកមានសោតាបន្នបុគ្គល, សកទាគាមិបុគ្គល, អនាគាមិបុគ្គល, ព្រះអរហន្ត, ព្រះអរិយបុគ្គលទាំងបួនពួកនេះ លោកបានយល់ពាល់ត្រូវព្រះនិព្វានដោយលោកុត្តរចិត្ត ឥតមានសេចក្តីសង្ស័យ ស្រពេចស្រពិលអ្វីទៀតឡើយ ។ ចំពោះព្រះអរហន្ត លោកបានបដិបត្តិកំចាត់បង់កិលេសអស់ពីខន្ធសន្តាន ឥតមានសេសសល់ទៀតទេ បានន័យថាការបដិបត្តិ កំចាត់បង់កិលេសទៀត ពុំមានសម្រាប់លោកទេ ចំណែកព្រះអរិយបុគ្គលបីពួកទៀតមានសោតា សកទាគា អនាគា លោកនៅមានការបំពេញកិច្ច ក្នុងការបដិបត្តិកំចាត់បង់កិលេស តាមលំដាប់ថ្នាក់គ្រប់គ្រាន់ រហូតបានសម្រេចជាព្រះអរហន្ត ជាអ្នកបានបញ្ចប់កិច្ចបដិបត្តិ ដោយបរិបូណ៌ ព្រោះកងកិលេសទាំងអស់លោកបានកំចាត់បង់អស់ហើយ ។

ព្រះអរិយបុគ្គល លោកបានយល់ស្គាល់ គោលដៅនៃជីវិតពិតប្រាកដ និងទីស្នាក់ចតរបស់ជីវិត ឥតមានវង្វេងទិសទៀតទេ និងបានបញ្ចប់នៃជីវិតអន្ទោលនេះទៀតហើយ ។ សូម្បីតែព្រះអរិយបុគ្គលពួកខ្លះមាន ព្រះសោតា, សកទាគា, អនាគាមីក្តី លោកនៅពុំទាន់បានបញ្ចប់ជាតិជាចុងក្រោយនេះ ដូចព្រះអរហន្តក៏ដោយ បានន័យថា

លោកនៅមានអន្ទោល កើតទៀតទៅតាមសភាពប្រភេទ នៃពួកអរិយបុគ្គលនោះ ដូចជាព្រះអរិយបុគ្គលថ្នាក់សោតា សកទាគា ការអន្ទោលពួកខ្លះ តែមួយជាតិទៀត ប្រាំពីរជាតិទៀត ឬចេញពីត្រកូល ទៅកាន់ត្រកូលមនុស្សទេវតាតែប៉ុណ្ណោះ ពុំបានធ្លាក់ទៅកាន់អបាយ ដូចបុថុជ្ជនទៀតទេ ។ ចំពោះព្រះអនាគា ក្នុងកាលដែលលោកបានសម្រេចអនាគាមិមគ្គ អនាគាមិផល ក្នុងជាតិជាមនុស្សនេះហើយ ដល់ពេលដែលលោកអស់ព្រះជន្មទៅ លោកត្រូវទៅកើតក្នុងសុទ្ធាវាសព្រហ្ម លោកបដិបត្តិដើម្បីបានសម្រេចមគ្គផល ជាព្រះអរហន្តបរិនិព្វានក្នុងទីនោះ ដោយពុំបានវិលត្រឡប់មកកាន់មនុស្សលោកនេះទៀតទេ ដូច្នេះជីវិតរបស់ព្រះអរិយបុគ្គល ទោះបីជាស្ថិតនៅក្នុងថ្នាក់ណាក៏ដោយ លោកមានកំណត់គោលដៅជីវិតរបស់លោកគឺព្រះនិព្វានជាបរិយោសាន ឥតមានស្រពេចស្រពិលសោះឡើយ ។

ចំពោះព្រះអរហន្ត លោកបានបញ្ចប់កិច្ច ក្នុងការលះកិលេសចប់អស់ហើយ ឈ្មោះថាលោកបាននិព្វានហើយ ពាក្យថានិព្វានត្រង់ចំណុចនេះ បានន័យថាសូន្យ ដែលស្មើនឹងពាក្យថាគ្មាន គឺឥតមានកងកិលេស ជាពូជជាបច្ច័យឱ្យសាងកម្មតទៅទៀត កាលបើកម្មឥតមានហើយ វិបាកគឺផលក៏មិនមាន ភាពអន្ទោល សេចក្តីខ្វល់ខ្វាយចង្អៀតចង្អល់ កង្វល់ទុក្ខសោក ខាងផ្លូវចិត្តក៏ឥតមាន ជីវិតរបស់លោកប្រព្រឹត្តទៅដោយភាពក្សេមសន្តិ ។ ទោះបីជាលោកបានទទួលវិបាកជាឥដ្ឋារម្មណ៍ ឬជាអនិដ្ឋារម្មណ៍ គឺអារម្មណ៍ដែលល្អ ធ្វើឱ្យពេញចិត្ត អារម្មណ៍មិនល្អធ្វើឱ្យមិនពេញចិត្តក្នុងបច្ចុប្បន្ន ដែលជាផលរបស់កម្ម កំណត់ពីអតីតជាតិនៅពុំអស់នៅឡើយ ដូចជាការឃើញរូប ឮ

សម្លេង ធំក្លិន ដឹងរសជាតិ ពាល់ត្រូវសម្ផស្ស ដឹងធម្មារម្មណ៍ តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ដូចជាបុថុជ្ជនយ៉ាងនេះក៏ដោយ តែព្រះទ័យរបស់លោក ឥតមានកម្រើកញាប់ញ័រ ប៉ោងផតទៅតាមអារម្មណ៍នោះៗ ទៀតទេ ព្រោះលោកមានចិត្ត ជាអព្យាកតៈ មិនសោមនស្ស មិនទោមនស្ស ចំពោះអារម្មណ៍នោះៗ ទៀតទេ ។ លោកមានជីវិតរស់នៅ ទោះបីជាលោកអាស្រ័យនៅក្នុងទីកន្លែងណា ឬទៅកាន់ទីស្ថានណាៗ ជាទីខ្ពស់ទាបមិនរាបស្មើក្តី ប្រកបដោយភាពច្របូកច្របល់ខ្វល់ខ្វាយដូចម្តេចក្តី តែព្រះទ័យរបស់លោកស្មើជានិច្ចដោយភាពស្ងប់ស្ងាត់ ។ ត្រង់ចំណុចនេះទើបឈ្មោះថា ព្រះអរិយផ្ទាក់ព្រះអរហន្ត លោកបានសម្រេចព្រះនិព្វានទាំងនៅមានជីវិត ពុំមែនដូចការយល់ឆ្គល់ ដោយមានយោបល់ថានិព្វានលុះតែសូន្យសោះអស់ជីវិតឥតមានអ្វីសល់នៅ លែងមានកំណើតទៀត ឥតមានដឹងអ្វីទាំងអស់ ។ ប្រសិនណាជាព្រះនិព្វាន មានពំនោលតែម្យ៉ាងថា សូន្យសោះអស់អ្វីៗ ដោយគ្មានសញ្ញាការសម្គាល់ទេនោះ សូម្បីតែព្រះសម្មាសម្ពុទ្ធ ក៏ព្រះអង្គពុំអាចសម្តែង បង្ហាញបើកទ្វារនិព្វាន ឱ្យសត្វលោកបានយល់ស្គាល់ ពាល់ត្រូវព្រះនិព្វាន ទាំងបានស្ពាបនាឱ្យព្រះអរិយជាសាវករបស់ព្រះអង្គ បានស្គាល់យល់ពាល់ត្រូវនិព្វាន មានគោលដៅនៃជីវិតពិតប្រាកដ អស់សេចក្តីសង្ស័យ នឹងបានជាជំនួយប្រកាសសម្តែងពីនិព្វាន មានជាសក្ខីកម្មជាអនេក ។

ដូច្នេះព្រះនិព្វានដែលថា មាននៅចំពោះមុខ ហើយដែលសាវក សាវិកា អាចយល់ ពាល់ត្រូវបាន គឺសំដៅត្រង់កាអស់ទៅនៃកងកិលេសទាំងពួង មានអវិជ្ជា តណ្ហា ឧបាទាន កម្ម ឥតមានដក់ជិត

ស្ថិតនៅក្នុងចិត្តទៀតទេ ។ ដូចសំណួរ ឧទយមាណព សិស្សពាវរីព្រាហ្មណ៍ បានទូលសួរព្រះដ៏មានព្រះភាគ យ៉ាងនេះថា ៖ **បពិត្រព្រះគោតមដ៏ចម្រើន ដែលថាព្រះនិព្វាននោះ តើព្រោះការលះអ្វីបាន?** ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ៖ ដែលលោកពោលថា ព្រះនិព្វាននោះ (ព្រោះការលះតណ្ហាបាន) ត្រង់ចំណុចនេះអាចបញ្ជាក់បានថា កាលបើតណ្ហារីងស្ងួតហួតហែង អស់ពីចិត្តសត្វលោកដរាបណា ក៏ឈ្មោះថានិព្វាន រមែងមាននៅក្នុងសត្វលោកដរាបនោះ ដូចជាសាវកសាវិកា ជាព្រះខីណាស្រពរបស់ព្រះអង្គ ដែលបាននិព្វាន មានកិលេសស្ងប់រម្ងាប់ចាកចិត្តអស់ហើយ បានន័យថា មានចិត្តរួចផុតស្រឡះចាកកិលេស ដែលជាជ័រធ្វើឱ្យជាប់ជំពាក់ក្នុងលោក គឺលោកភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត លោកទាំងប្រាំមួយនេះបានធ្វើឱ្យបុថុជ្ជនមានការជាប់ជំពាក់ស្អិត គ្មានសត្វណាមួយអាចរើឱ្យផុតរួចបាន ក្រៅពីព្រះអរហន្ត លោកបានសម្រេចនិព្វាន សូន្យចាកកិលេសហើយតែប៉ុណ្ណោះ ទោះបីជាលោកមានជីវិតគង់នៅ លោកតែងមានសភាពសុខស្ងប់ ខាងផ្លូវចិត្ត ពុំមានសោកសៅក្តៅក្រហាយ ឬរីករាយជាប់ចិត្តនឹងលោកខាងក្នុងឬលោកខាងក្រៅទៀតទេ ។ ក៏ប៉ុន្តែចំពោះខាងផ្លូវកាយវិញ លោកនៅមានការចាស់ ឈឺ រោគាពាធបៀតបៀន ឱ្យមានសេចក្តីទុក្ខលំបាក ដោយអំណាចបញ្ចខន្ធពុំទាន់រលត់ លុះដល់លោកអស់ព្រះជន្មពេលណា ឈ្មោះថាលោកបានរំលត់ខន្ធបរិនិព្វានអស់ជាតិកំណើត លែងវិលត្រឡប់មកកើតក្នុងសង្សារវដ្តនេះទៀតហើយៗ ។ បានន័យថា លោកបានបំពេញសេចក្តីព្យាយាម ចម្លងនាវាជីវិតនេះ ឱ្យបានដល់ត្រើយខាងនាយ

មានគោលដៅ ទីចតស្នាក់ពិតប្រាកដ ព្រមទាំងបានបញ្ចប់ភាពអន្ទោលព្រមទាំងសេចក្ដីខ្វះខាត ស្រេកឃ្លាន មាន ក្រ ជាទាសករនៃតណ្ហា ជាពូជ ជាប្រភពនៃទុក្ខទោស ឱ្យអស់ និងបានទទួលនូវសន្តិបទ គឺភាពស្ងប់ជាលក្ខណៈតែប៉ុណ្ណោះ ។

*ទ្វារទាំង ៦ នាំព្រួយភ័យទុក្ខ ខន្ធ ៥ នាំមុខជាប់គុកវដ្ដៈ*
*ចិត្តល្អអាក្រក់កើតគ្រប់ខណៈ បង្វិលច្រវាក់វដ្ដសង្សារ ។*
*ស្គាល់ចិត្តចេតសិករូបបរមត្ថ បុគ្គលកំចាត់កាត់អញអត្តា*
*តក់ៗ តូចតិចច្បិចយកខ្លឹមសារ ចិត្តដៅប្រាថ្នាឆ្ពោះព្រះនិព្វាន ៕*

ដោយឧបាសក **ហ៊ិម ឆាន់**

# អត្ថន័យបន្ថែម

ដំណើរជីវិតដូចបានសរសេររៀបរាប់មកដោយសង្ខេប ស្តាប់ទៅហាក់បីដូចជាងាយស្រួល សម្រាប់ជីវិតដែលកំពុងត្រាច់ចរ ព្រោះខាងដើមនៃផ្លូវនិងចុងបញ្ចប់នៃផ្លូវ ហាក់បីដូចជាមានគម្លាតមិនឆ្ងាយពីគ្នាទេ ។ ពិតមែនហើយអ្វីៗ បើគ្រាន់តែស្តាប់ឮ មិនប្រាកដឱ្យដូចជាការមើលឃើញផ្ទាល់ ឬការពាល់ត្រូវពិត ព្រោះការត្រឹមតែបានស្តាប់ដំណើររឿងរ៉ាវដែលគេបានបរិយាយអធិប្បាយ ក៏បានត្រឹមតែការស្រមើស្រមៃ តាមពាក្យសម្តីអត្ថន័យដែលគេពោលស្តីតែប៉ុណ្ណោះ ។ អ្វីដែលជាគុណទោសខុសត្រូវ បានទៅជាប្រយោជន៍ឬឥតប្រយោជន៍ ត្រូវពឹងទៅលើបញ្ញាស្មារតី ក្នុងការចេះស្រាវជ្រាវរាវរក ហេតុផលពិតយកមកពិនិត្យត្រិះរិះពិចារណាឱ្យយល់ច្បាស់ ចូលចិត្តពិតប្រាកដដោយខ្លួនឯង ។

ព្រះសាស្តាសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ត្រាស់ប្រាប់អំពីសង្សារវដ្ត គឺខាងដើមរបស់សត្វទាំងឡាយ គ្មានអ្នកណាអាចកំណត់ដឹងបាន ព្រោះមានអវិជ្ជាជារនាំង មានតណ្ហាជាចំណង ទើបធ្វើឱ្យសត្វលោកត្រាច់ទៅមិនប្រាកដឡើយ ។ ន័យក្នុងព្រះពុទ្ធដីកានេះ ចង់បញ្ជាក់ប្រាប់ថា គ្រប់តែសត្វលោកដែលត្រាច់រង្គាត់ក្នុងសង្សារវដ្តដ៏សែនវែងឆ្ងាយនេះ ព្រោះមានអវិជ្ជាជាបច្ច័យ, អវិជ្ជាប្រែថាការមិនដឹង បានដល់ការមិនដឹងសេចក្តីទុក្ខ មិនដឹង មិនស្គាល់ មិនយល់ ខន្ធជាអតីត ខន្ធជា

អនាគតព្រមទាំងខន្ធដែលជាអតីតអនាគត មិនដឹងសមុប្បាទធម៌ ។

អវិជ្ជាគឺការមិនដឹងនូវសេចក្តីទុក្ខនេះហើយ ទើបជាប្រភពនាំឱ្យកើតសេចក្តីទុក្ខ ជាហេតុនាំឱ្យសត្វលោកវង្វេងធន់ទ្រាំទទួលយកសេចក្តីទុក្ខ ទាំងងងឹតងងល់ដូចជាសត្វដង្កូវដែលកើតពីលាមកក្នុងបង្គន់ បានដាក់ខ្លួនពួនសម្ងំរស់ បរិភោគលាមកជាអាហារ ទាំងបានសម្គាល់ស្មានថា គ្មានទីស្ថានណាឱ្យប្រសើរស្មើទីស្ថានរបស់ខ្លួន ។ យ៉ាងណាមិញ សត្វលោកដែលមានអវិជ្ជាជាគ្រឿងប្រក់បាំង ជារនាំងជាកំពែង ក៏រមែងឥតបានស្គាល់យល់អំពីសេចក្តីទុក្ខ ជាហេតុនាំឱ្យកើតសេចក្តីទុក្ខ គឺតណ្ហា ដែលចាំប្រលោមលួងលោម ឱ្យចិត្តវង្វេងគ្រប់ពេលវេលានោះឡើយ ។

ក្នុងបដិច្ចសមុប្បាទធម៌ ព្រះអង្គបានសម្តែងបញ្ជាក់ប្រាប់ហើយថា អវិជ្ជាជាមេ ជាប្រភពខាងដើម នាំឱ្យកើតចេតនាកម្ម គឺអភិសង្ខារ និងធម៌ដទៃផ្សេងៗ ទៀត មានតណ្ហាជាដើម ការមិនដឹងនូវសេចក្តីទុក្ខ និងហេតុនាំឱ្យកើតសេចក្តីទុក្ខ ព្រោះតែមានរនាំងបាំងជញ្ជាំងហ៊ុមព័ទ្ធ ដំបូលប្រក់ជិតឥតមានពន្លឺ ឆ្លុះបញ្ចាំងឱ្យឃើញផ្លូវដើម្បីត្រាច់ចរទៅរកគោលដៅ ប្រាកដពិតសម្រាប់ជីវិត ក៏ព្រោះតែមានអវិជ្ជាជាបច្ច័យ ជាហេតុ ជាប្រភពខាងដើមនេះឯង ។

តណ្ហា គឺជាចំណង ជាខ្សែចងរួបរឹតសត្វឱ្យរើខ្លួនងាកចេញពីភពងងឹតមិនបាន ទាំងជាមេប្រលោមលួងលោមចិត្ត ឱ្យស្និទ្ធស្នេហ៍ចំពោះអារម្មណ៍ក្នុងលោកផង ជាពណ៌សម្រាប់លាបជីវិត រចនាលោក

នេះឱ្យស្រស់ត្រកាលផងធ្វើឱ្យសត្វលោកត្រេកត្រអាល ស្រើបស្រាល សប្បាយភ្លេចស្មារតី ប្រមាទក្នុងជីវិតឥតបានគិតនឹកភ្នកចរកផ្លូវចេញ សោះឡើយ ។

អជិតមាណព សិស្សពាវរីយព្រាហ្មណ៍ បានទូលសួរព្រះដ៏មានព្រះភាគយ៉ាងនេះថា ៖ **បពិត្រព្រះអង្គដ៏ចម្រើន សត្វលោកមានអ្វីជាគ្រឿងបាំង? សត្វលោកងងឹតមិនភ្លឺស្វាងព្រោះធម៌អ្វី? សូមព្រះអង្គមេត្តាត្រាស់ប្រាប់ ធម៌អ្វីជាគ្រឿងលាបលោក? អ្វីជាភ័យធំរបស់សត្វលោក?** ។ ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់មានព្រះតម្រាស់ទៅកាន់អជិតមាណពវិញ យ៉ាងនេះថា ៖ **ម្នាលអជិតមាណព សត្វលោកមានអវិជ្ជាជាគ្រឿងបាំង, សត្វលោកមិនភ្លឺស្វាង ព្រោះសេចក្តីប្រាថ្នាទាំងឡាយ និងសេចក្តីប្រមាទ តថាគតពោលថា តណ្ហាជាគ្រឿងលាបលោក ទុក្ខជាភ័យធំរបស់សត្វលោក** ។

ជាធម្មតា វិចិត្រករមុននឹងគេគូសវាស ឱ្យចេញជារូបគំនូរអ្វីមួយ គេតែងមានគ្រឿងសម្ភារៈព្រមទាំងពណ៌ផ្សេងៗ សម្រាប់វិចិត្រតាក់តែងរូបគំនូររបស់គេ ឱ្យមានសម្រស់ស្រស់បំព្រង ទាក់ទាញភ្នែកអ្នកផងទាំងពួងឱ្យគេគយគន់ យ៉ាងណាមិញ អវិជ្ជាទុកជាគ្រឿងព័ទ្ធឡោមបាំងមិនឱ្យសត្វលោករកច្រកចេញ ឬមើលមិនឃើញគោលដៅរកផ្លូវដើម្បីចេញទៅ ឱ្យស្ថិតនៅងប់ងល់ងងឹតសូន្យសុងក្នុងរង្វង់កំពែងឡោមព័ទ្ធ ។ ចំណែកឯតណ្ហាទុកដូចជាភ្លើងពណ៌ បញ្ចេញពន្លឺខៀវ លឿង ក្រហម ស បំភ្លឺឆ្លុះបញ្ចាំងភាពអន្ធការ ឱ្យបានភ្លឺមួយដងមួយកាល ធ្វើឱ្យសត្វលោកត្រេកត្រអាលភ្លូកភ្លេចស្មារតី ព្រោះតែ

រស្មីនៃភ្លើងពណ៌ ត្រូវនាំគ្នាទ្រាំរស់កសាងកេរ្តិ៍ឈ្មោះកិត្តិយស ស័ក្តិ អំណាច វណ្ណៈ អវណ្ណៈ ដាក់ទំនាបលើកកម្ពស់ ឈ្លោះប្រកែកកាប់សម្លាប់ដោយភាពងងឹតវង្វេង លែងមានការខ្មាសអៀន ប្រព្រឹត្តបទល្មើសខុសក្រមក្រឹត្យ វិន័យច្បាប់គ្រប់បែបយ៉ាង ដាក់ខ្លួនសាងកម្ម ជាទាសករនៃអវិជ្ជាតណ្ហា ទាំងភាពវង្វេង លែងស្គាល់គុណទោស ខុសត្រូវអ្វីទាំងអស់ ទ្រាំរស់ស៊ូស្លាប់ទៅតាមយថាកម្ម ទាំងឥតបានយល់ស្គាល់គោលដៅរបស់ជីវិតឱ្យបានពិតប្រាកដ ។

សត្វលោករស់នៅក្នុងភាពងងឹត ឥតពន្លឺរមែងមិនដឹងយល់អ្វីជាសេចក្តីពិតបាន ។ សត្វលោករស់នៅក្នុងភាពល្ងង់លោម ក្លែងបន្លំបោកប្រាស់ ច្បាស់ជាវង្វេងលែងស្គាល់ យល់ហេតុផលពិត ។ កាលបើសត្វលោកងងឹត ឥតបានយល់ពីគុណទោសខុសឆ្គងហ្មងមោះ រមែងធ្លាក់ចូលក្នុងជ្រោះនៃសេចក្តីប្រមាទធ្វេសប្រហែស ក្នុងដំណើរជីវិត ទាំងឥតបានស្គាល់យល់ដឹង អំពីអ្វីដែលជាភ័យធំរបស់ជីវិត ពិតពោលគឺសេចក្តីទុក្ខ ។ កាលបើពុំបានយល់ចូលចិត្តអំពីសេចក្តីទុក្ខដូច្នេះ តើនឹងមានចិត្តនឿយណាយ រកឧបាយចេញចាកពីសេចក្តីទុក្ខ ដូចម្តេចបាន? ទើបដាក់កាយប្រាណរស់តាមលំអាននៃការកើត ចាស់ ឈឺស្លាប់ សុខ ទុក្ខ សើច យំ ស្រឡាញ់ ស្អប់ វិលចុះត្រឡប់វិញ នៅក្នុងរង្វង់កង់សង្សារចក្រនេះ ដោយឥតមានទិសដៅផ្លូវចេញទៅបាន ។

ព្រះបរមសាស្តាចារ្យសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ត្រាស់សម្តែងប្រាប់ អំពីជីវិតនៃសត្វលោកទាំងឡាយ ត្រូវត្រាច់ចរតាមផ្លូវឆ្ងាយនេះមានសភាពយឺតៗ ជាអនេកជាតិ ពុំអាចរាប់បានប្រមាណត្រូវ ព្រោះតែ

ផ្លូវដែលត្រាច់ទៅនោះ ជាផ្លូវលំបាកដោយមានទឹកភក់ផុងផង ដោយសត្វលោកខ្លួនឯងនេះ ទទួលភារៈអម្រែកពុនស្ពាយ ជាទម្ងន់ទាំងកាយចិត្តផង ទាំងធ្វើដំណើរទៅទាំងភាពវង្វេងងងឹតងងុល ឥតស្គាល់ទិសដៅដែលត្រូវទៅនោះផង ទើបធ្វើឱ្យសត្វលោកមានដំណើរយឺតយូរក្នុងសង្សារវដ្តនេះ ។ អ្វីជាភារៈជាទម្ងន់? បានដល់តណ្ហា មានះ ទិដ្ឋិដែលមានអវិជ្ជាជាប្រភព ជាបុព្វភាគ ទើបធ្វើឱ្យសង្សារវដ្តនេះវែងឆ្ងាយ ធ្វើឱ្យសត្វលោកមានដំណើរយឺតយូរ ក្នុងការត្រាច់ចរទាំងត្រដរខំរែក ពុន យួរ ស្ពាយ ព្រមដាក់ចិត្តកាយទទួលយកអម្រែកទម្ងន់នោះដោយភាពធន់ទ្រាំត្រាច់ចរទៅតាមផ្លូវ ដែលពោរពេញដោយភាពលំបាក និងឧបសគ្គនានាជាអនេកប្បការ ។ ន័យនេះយ៉ាងណា ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់ត្រាស់ថា ៖ មានះទុកដូចជាទម្ងន់ដ៏ធ្ងន់ព្រោះការប្រកាន់រើសអើងរឹងត្អឹង ធ្វើឱ្យប្រឹងតម្កើងលើកកម្ពស់ខ្លួនដោយស័ក្តិយស អំណាច តំណែងនាទី ទ្រព្យសម្បត្តិ ចំណេះវិជ្ជា ឋានៈវណ្ណៈ ជាតិត្រកូល ទាំងភាពវង្វេងលែងគោរពកោតក្រែង គេឯងដែលនៅជុំវិញខ្លួន ព្រោះការប្រកាន់លើអ្វីៗ ដែលខ្លួនមានប្រសើរលើសគេការប្រកាន់លើកកម្ពស់ថាខ្លួនប្រសើរជាងគេក្តី ស្មើនឹងគេក្តី អន់ជាងគេក្តី ទាំងនេះស្ថិតនៅក្នុងភាពមានះ ព្រោះជាហេតុធ្វើឱ្យវង្វេងភ្លាំងភ្លេចស្មារតី យប់ថ្ងៃឥតមានចិត្តព្រមទទួលស្តាប់អ្នកដទៃ ឥតឱ្យតម្លៃទៅលើគុណធម៌ សេចក្តីល្អរបស់អ្នកដទៃ ក្រៅតែអំពីចិត្តគិតថា មានតែខ្លួនឯងប៉ុណ្ណោះ (ក្រៅតែពីអញក៏មានតែអញ) នេះហើយដែលហៅថាជាទម្ងន់ ទំនួល អម្រែក សម្ពាយ ដែលពុំងាយលះដាក់បាន ។

សត្វលោករស់នៅក្នុងភពងងឹត ឥតពន្លឺ រមែងឥតបានដឹង

យល់ស្គាល់ពីអ្វី ដែលជាសេចក្តីពិត ។ សត្វលោករស់នៅក្នុងភាពល្ងង់លោម ក្លែងបន្លំ បោកប្រាស់ ប្រាកដជាវង្វេងលែងដឹងយល់ស្គាល់ អ្វីជាគុណទោសខុសត្រូវ រមែងធ្លាក់ចុះក្នុងភាពប្រមាទ ធ្វេសប្រហែសក្នុងដំណើរជីវិត ទាំងឥតបានស្គាល់ពីអ្វី ជាភ័យធំសម្រាប់ជីវិតនេះ គឺជាសេចក្តីទុក្ខ ។ កាលបើឥតបានយល់ស្គាល់ពីសេចក្តីទុក្ខ ហេតុដែលនាំឱ្យកើតសេចក្តីទុក្ខដូច្នោះហើយ តើនឹងមានចិត្តនឿយណាយរកឧបាយចេញចាកពីសេចក្តីទុក្ខដូចម្តេចបាន ម៉្លោះហើយទើបប្រថុយប្រថាន ដាក់ចិត្តកាយប្រាណរស់តាមលំអាននៃការកើត ចាស់ ឈឺស្លាប់ សុខ ទុក្ខ សើច យំ ស្រឡាញ់ ស្អប់ វិលចុះត្រឡប់ឡើងនៅក្នុងរង្វង់កង់នៃសង្សារចក្រនេះទាំងគ្មានទិសដៅ ។

មានះជាហេតុធ្វើឱ្យភ្លាំងភ្លេចស្មារតី វង្វេងឥតព្រមទទួលត្រាប់ស្តាប់តាម មតិយោបល់របស់អ្នកដទៃ ដែលជាគុណជាសេចក្តីល្អ ដូចជាសញ្ជ័យបរិព្វាជក ជាគ្រូរបស់ព្រះសារីបុត្រនិងព្រះមោគ្គល្លាន ។ សុខចិត្តដាក់កាយទទួលយកទម្ងន់ពុនរែក ត្រាច់ចរទៅតាមផ្លូវ ដែលពោរពេញដោយទឹកភក់ បានដល់តណ្ហាគឺសេចក្តីប្រាថ្នា ចំណង់អង្គធម៌ គឺលោភៈ ជាអន្ទាក់ផង ជាចំណងផុងភក់ ជាភ្លើងពណ៌ធ្វើឱ្យសត្វទទួលយករែកពុន ទៅទាំងទុរន់ទុរាយឺតយូរស៊ូទ្រាំព្រោះតណ្ហានេះឯងដែលកើបបញ្ចូលប្រមូលទម្ងន់គ្រប់យ៉ាងមិនចេះគ្រប់ធួនល្មមទាំងបានបោកបញ្ឆោត ល្ងង់លោម ឱ្យទទួលព្រមគ្រប់អ្វីទាំងអស់ ឱ្យត្រាច់ចរទៅតាមផ្លូវ ពោរពេញដោយទឹកភក់ ត្រដរទៅដោយភាពធន់ទ្រាំ ឥតបានដឹងគោលដៅ ដោយភាពវង្វេងងងឹត បានដល់ទិដ្ឋិ គឺការយល់ឃើញខុស ងងឹតឥតពន្លឺ ។ ពាក្យថាទិដ្ឋិនេះ ព្រះពុទ្ធបរមគ្រូ ព្រះ

អង្គបានត្រាស់ថាជាបបញ្ចធម៌ ធ្វើឱ្យមានដំណើរយឺតយូរក្នុងសង្សារវដ្ត ព្រោះការយល់ឃើញខុស ប្រកាន់ខុសពីហេតុផលពិត ទាំងនាំឱ្យប្រកាន់ជាប់ស្អិតទៅតាមគំហើញនោះៗ ពុំងាយលះចេញបាន ប្រៀបដូចជាជ័រស្អិត បើជិតជាប់ត្រង់កន្លែងណាហើយ ក៏ពុំងាយនិងទាញចេញមកវិញបានឡើយ ដ្បិតថាកាលបើយល់ចូលចិត្តខុស រមែងប្រកាន់ខុស ជឿចូលចិត្តខុស នាំឱ្យគ្រប់ទង្វើនៃការពោលស្តីខុស ជាហេតុឱ្យបានទទួលខុសជាផល ។

កុំថាឡើយចំពោះសម័យបច្ចុប្បន្ននេះ តាំងតែពីសម័យកាលដែលព្រះអង្គគង់ធរមាននៅឡើយ សូម្បីតែព្រះអង្គទ្រង់មានព្រះមេត្តាមហាករុណាទិគុណ បានប្រោសប្រទានសម្តែងព្រះធម៌ទេសនា បើកបង្ហាញពីសភាវៈពិតដោយសំអាងទៅលើហេតុផលពិត ក៏នៅតែពុំអាចញ៉ាំងចិត្តសត្វលោកទាំងអស់ឱ្យបានយល់ចូលចិត្ត ដល់អត្ថន័យព្រះធម៌បានគ្រប់ស្មើគ្នានោះទេ មិនតែប៉ុណ្ណោះសោត មានពួកសត្វខ្លះមានចិត្តប្រទូស្ត ដាក់កំហុសចោ្កលទោសចំពោះព្រះអង្គវិញ ដោយប្រការផ្សេងៗ ទៀតផង ។

ទិដ្ឋិនេះមានច្រើនប្រការណាស់ ទាំងដក់ជិតស្ថិតជាប់នៅក្នុងចិត្តបុថុជ្ជជនយើងគ្រប់រូប ដែលគ្មានអ្នកណាម្នាក់អាចលះបាន ។ ចុះបើមានសំណួរសួរថា បុគ្គលភាគច្រើនបានស្តាប់ធម៌ព្រះអង្គហើយជ្រាបយល់ចូលចិត្តសេចក្តី ទៅតាមហេតុផលនៃព្រះធម៌នោះៗ ទាំងមានជំនឿទៅតាមសភាវធម៌ ដែលព្រះអង្គទ្រង់ត្រាស់សម្តែងដោយពិត ដូច្នេះហើយ តើនៅមានមិច្ឆាទិដ្ឋិទៀតឬ? ចម្លើយគង់នៅមានមិច្ឆាទិដ្ឋិទៀតមិនអស់ទេ ព្រោះបណ្តាមិច្ឆាទិដ្ឋិទាំងអស់រួមចូលក្នុង

សក្កាយទិដ្ឋិ ការប្រកាន់ជាប់ស្អិត ចិត្តគិតថាជាអញ ជាឯង ជាសត្វ ជាបុគ្គល ជាយើង ជាគេ ដែលជាបញ្ញត្តិពុំងាយដកបាននោះទេ (សក្កាយទិដ្ឋិ) ការប្រកាន់ថាជាខ្លួនប្រាណនេះហើយ មិនខុសអំពីជ័រស្អិតជិតប្រឡាក់ជាប់ក្នុងចិត្ត មិនងាយប្រឡេះបេះដកចេញឱ្យបានងាយៗនោះទេ និងជាមេបង្កើតឱ្យមានមិច្ឆាទិដ្ឋិដទៃៗ ទៀត កើតបន្តរដឹកជាប់គ្នាមិនដាច់ ទាំងនេះតើមែនឬទេ ពិតឬមិនពិត សូមគិតពិចារណាបន្តិចទៅ!... មិច្ឆាទិដ្ឋិនេះជាភាពអន្ធការ ធ្វើឱ្យងងឹតឥតពន្លឺ ឬទុកដូចជាបុគ្គលមានភ្នែកខ្វាក់ ពុំអាចមើលអ្វីឃើញ ពុំនោះសោតទេ ទុកដូចជាអ្នកវង្វេងទិស ពុំអាចកំណត់យល់ស្គាល់ គោលដៅណាឱ្យប្រាកដបាន ។

ការត្រាច់ចរតាមផ្លូវទៅរកគោលដៅមួយ ជាផ្លូវពោរពេញដោយទឹកភក់ ស្លុះផុងរអិល ទ្រេតមុខទ្រេតក្រោយ ជាហេតុធ្វើឱ្យដំណើរទៅមុខមិនលឿន បន្ថែមទាំងមានបន្ទុក អម្រែក ទំនួលសំពាយ ទម្ងន់ពីលើក្បាល លើស្មាទៀតផងនោះ តើនឹងមានការលំបាកដល់កម្រិតណា មិនតែប៉ុណ្ណោះថែមទាំងវង្វេងទិស ទៅទាំងងងឹតងងុលទៀតនោះ តើនឹងបានដល់គោលដៅដោយរបៀបណា? ។

សត្វលោកដែលត្រាច់ទៅតាមផ្លូវ ពុំទាន់បានស្គាល់គោលដៅកំណត់ផ្លូវពិតប្រាកដមិនបាន ទើបដាក់ចិត្តប្រថុយប្រាណទៅតាមលំអាននៃតណ្ហា ដែលពោរពេញទៅដោយសំណើមនៃទឹកភក់ ទម្ងន់គ្រប់បែបយ៉ាងនៃមានះសម្លឹងទៅទិសណា ឃើញតែភាពងងឹតគឺមិច្ឆាទិដ្ឋិ ។ តណ្ហា មានះ ទិដ្ឋិ នៅមានដរាបណា ដំណើរយឺតយូរឈ្មោះថានៅមានដរាបនោះ ដូច្នេះសង្សារវដ្តក៏នៅវែងឆ្ងាយដរាបនោះដែរ

ជ្រោះនៃជាតិ ជរា ព្យាធិ មរណៈ រមែងនៅមានសម្រាប់សត្វលោកក៏ដូច្នោះដែរ ។

ដើម្បីធ្វើដំណើរឱ្យបានឆាប់ ត្រូវព្យាយាមរៀនកំណត់ ឈោងចាប់យកគោលដៅឱ្យបានពិតប្រាកដ និងបានត្រាច់តាមផ្លូវមួយបានត្រឹមត្រូវ តាមការកំណត់ទុក គឺជាមាគ៌ាដែលព្រះសាស្ដាសម្មាសម្ពុទ្ធជាព្រះបរមគ្រូនៃយើងព្រះអង្គបានត្រាស់បង្ហាញទុកហើយ ដោយព្រះអង្គបានបំភ្លឺប្រាប់សត្វលោក ឱ្យបានយល់ស្គាល់អំពីភាពវែងឆ្ងាយនៃសង្សារវដ្ដ អំពីរនាំង ចំណង បាំងសត្វលោកឱ្យជាប់ងងឹតវង្វេង មិនអាចចេញពីសេចក្ដីទុក្ខបាន ។ ដូច្នេះក្នុងការដើរតាមផ្លូវជាការចាំបាច់ណាស់ ត្រូវស្គាល់ផ្លូវ ស្គាល់គោលដៅដែលត្រូវទៅ ប្រាថ្នាដើម្បីចេញចាកទុក្ខ ត្រូវមានចិត្តនឿយណាយក្នុងសេចក្ដីទុក្ខនោះៗ ។

**ផ្សាយមេត្តា**

*បទពាក្យប្រាំបួន*

សូមសព្វសត្វ ផុតវិបត្តិ ក្នុងលោកា
បានសុខា ចិន្ដាស្ងប់ បញ្ឈប់ពៀរ
ចិត្តឥច្ឆា ផ្ដាប់និន្ទា ឈ្នានីសគ្នា
ដោយធម្មា ជាឱសថ ផុតព្រួយភ័យ ។

ដោយ **ម៉ិញ សាវ៉ាន**

# ធម្មទេសន៍ ៤ យ៉ាង



រៀបរៀងដោយ

ខ្ញុំព្រះករុណា ខ្ញុំបាទ **មិញ សាវ៉ាន**

ព.ស. ២៥៥៦ - គ.ស. ២០១២

**សម្រាប់ចែកជាធម្មទាន**

# គោលដៅរបស់ជីវិតពិត

ទីមួយ ដែលថាកំណត់គោលដៅពិតប្រាកដសម្រាប់ជីវិតនោះ គឺសំដៅយកព្រះនិព្វាន ដែលសម្តែងទុកក្នុងព្រះពុទ្ធសាសនា គឺព្រះអរិយបុគ្គល ចាប់តាំងពីថ្នាក់សោតាបន្នឡើងទៅ ។ លោកបានពាល់ត្រូវ យល់ស្គាល់ព្រះនិព្វានបានប្រចក្សច្បាស់ដោយខ្លួនឯង លែងមានសេចក្តីសង្ស័យទៀតហើយ ព្រោះបានដឹងថា និព្វានជាភាពបញ្ចប់ការអន្ទោលរបស់ជីវិត និងជាគោលដៅមួយជាទីបញ្ចប់នៃផ្លូវ គឺសង្សារវដ្តជាផល ដែលត្រូវបានដល់សព្វសត្វណា ដែលមានការនឿយណាយនឹងភាពដដែលៗ ក្នុងសង្សារវដ្តនេះ បានព្យាយាមសន្សំបារមីរហូតបានចាស់ក្លា សម្រេចគោលដៅជីវិតពិតប្រាកដ ។

ទីពីរ ត្រូវព្យាយាម រៀនយល់សម្គាល់ផ្លូវ ដែលត្រូវត្រាច់ទៅរកគោលដៅនោះ បានដល់អរិយមគ្គ ប្រកបដោយអង្គប្រាំបីប្រការ ដែលមានសម្មាទិដ្ឋិជាខាងដើម មានសម្មាសមាធិជាបរិយោសាន ដែលហៅថាអរិយមគ្គ ព្រោះជាផ្លូវដ៏ប្រសើរ ជាដំណើររបស់ព្រះអរិយបុគ្គលគ្រប់រូប បានយល់អរិយសច្ចធម៌ទាំងបួន និងបានពាល់ព្រះនិព្វានជាត្រើយនៃជាតិ ។ អរិយមគ្គទាំងប្រាំបីប្រការនេះ អាចហៅថាជា មជ្ឈិមាបដិបទាវិញក៏បាន ប្រែថាការបដិបត្តិជាកណ្តាល ដែលនៅចន្លោះនៃផ្លូវអមទាំងពីរប្រការ គឺកាមសុខល្លិកានុយោគ និងអត្តកិលមថានុយោគ ។

កាមសុខល្លិកានុយោគបានដល់ការប្រតិបត្តិ ដែលនៅច្របូក

ច្របល់ដោយកាម នៅជាប់ជំពាក់ដោយកាមគុណ, មានកាមគុណជាចំណង ជាតម្រាំរបស់ចិត្តពុំអាចសម្រេចគុណធម៌ ឬថាពុំអាចធ្វើឱ្យដល់ទីបំផុតទុក្ខបាន ។ ប្រៀបដូចបុគ្គលត្រូវការភ្លើង យកឈើស្រស់ឬឈើដែលនៅសើមដោយទឹក មកសង្កតគ្នា ពិតជាពុំអាចចេញភ្លើងបានទេ។

អត្តកិលមថានុយោគ ការបដិបត្តិខុសទិសដៅ បានដល់ការបដិបត្តិដែលតឹងគ្រាតពេក នាំឱ្យលំបាកកាយចិត្ត ខាតគុណប្រយោជន៍ បាត់បង់កាលវេលា ដូចជាខ្សែពិណដែលរឹតតឹងពេក នាំឱ្យដាច់ខ្សែប្រើការមិនកើត ។ យ៉ាងណាមិញ ផ្លូវអមទាំងពីរប្រការនេះព្រះពុទ្ធជាព្រះបរមគ្រូនៃយើង ព្រះអង្គធ្លាប់បានសាកល្បងពិសោធរួចមកហើយ ឃើញថាជាផ្លូវអម នាំឱ្យខាតបង់កាលវេលា ជាដំណើរប្រព្រឹត្ត មិនបានជាប្រយោជន៍ ។ ក្នុងធម្មចក្កប្បវត្តនសូត្រ ព្រះអង្គទ្រង់ត្រាស់ចំពោះបញ្ចវគ្គិយភិក្ខុថា ជា **ហីនោ** គឺជាធម៌ថោកទាប, **គម្មោ** ជាធម៌អ្នកស្រុក, **បុថុជ្ជនិកោ** ជាធម៌បុថុជ្ជន, **អនរិយោ** មិនមែនជាធម៌របស់ព្រះអរិយៈ, **អនត្ថសញ្ហិតោ** ប្រព្រឹត្តទៅមិនដើម្បីជាប្រយោជន៍ ដូច្នេះទើបចាត់ថាជាផ្លូវត្រូវតែលះចោលចេញ បំពេញប្រតិបត្តិគឺមាគ៌ាដ៏ប្រសើរ បានដល់អរិយមគ្គប្រកបដោយអង្គប្រាំបីប្រការ ដែលអង្គព្រះសាស្តាបានមានព្រះដំណើររួចមកហើយ ព្រមទាំងបានសម្តែងប្រកាសទុកជាសំណាមគំនូសឱ្យដល់សត្វលោក ធ្វើដំណើរតាមបានដល់គោលដៅសមតាមសេចក្តីប្រាថ្នា និងឧបនិស្ស័យរៀងៗ ខ្លួន ។

ទីបី ត្រូវព្យាយាមលះ ដាក់អម្រែក សម្ពាយ ពុន ទំនួលដែលជាទម្ងន់នោះចេញ ទើបមានសម្រាលក្នុងការធ្វើដំណើរ ។ ភាពជាបុថុជ្ជន

រម៉ែងពេញចិត្ត ក្នុងការកើបបញ្ចូលប្រមូលទម្ងន់ តាមចំណូលចំណង់ របស់តណ្ហា រហូតដល់បំប៉ោងបំប៉ន លើកតម្កើងខ្លួនមើលងាយអ្នកដទៃ ដោយភាពវង្វេងភ្លេចស្មារតី ។ ដូច្នេះត្រូវលះបង់ទម្ងន់មានះនេះ ដោយការបន្ទន់ចិត្តបង្កើនបញ្ញា ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញ សេចក្ដីទុក្ខទោស ដែលកើតចេញអំពីមានះនេះ រហូតដល់មានចិត្តសង្វេគនឿយណាយធុញទ្រាន់ព្យាយាមលះដាក់អម្រែកទម្ងន់នោះពិតៗ ដូចជាព្រះបរមសាស្ដានៃយើង កាលព្រះអង្គគង់នៅជាព្រះបរមពោធិសត្វ ដែលមានសម្ដែងក្នុងបិដកលេខ ៦២, តេមិយជាតក ទំព័រខាងដើម ខ្ញុំព្រះករុណា ខ្ញុំបាទ សូមលើកយកមកសរសេរ បញ្ជាក់ដោយសង្ខេបដូចតទៅនេះ ៖

ក្រោយពីព្រះតេមិយ បានចេញសាងផ្នួសជាតាបសនៅក្នុងព្រៃ ព្រះបិតានាមកាសិកៈ បានកេណ្ឌពលសេនាទាហាន មានទាំងស្រីស្នំបរិវារ សំអិតសំអាងកាយដោយគ្រឿងអលង្ការ ប្រាថ្នាលួងលោមព្រះរាជបុត្រឱ្យត្រឡប់មកជាភេទឃរាវាស បរិភោគកាមគុណវិញ ដោយបានពោលវាចាទៅកូនយ៉ាងនេះថា ៖ នែ៎កូន! បិតានឹងឱ្យពលសេះ ពលដំរី ពលទាហានរាជបល្ល័ង្ក ស្រីរបាំ ដែលប៉ិនប្រសប់ខាងការលួងលោម ឱ្យបានសប្បាយរីករាយក្នុងកាមារម្មណ៍, បិតានឹងលើកយករាជកញ្ញា ពីរាជត្រកូលដទៃ ដែលមានរូបឆោមលោមពណ៌ល្អវិចិត្រ ឱ្យជាមហេសីដល់កូន សូមឱ្យកូនបានបង្កើតបុត្រឱ្យបានច្រើនជាមួយរាជកញ្ញាទាំងនោះ ហើយចាំមកបួសជាខាងក្រោយ ព្រោះពេលនេះកូននៅក្មេងវ័យ ប្រយោជន៍អ្វីកូនមកនៅក្នុងព្រៃតែម្នាក់ឯង

ដូច្នេះ, សូមឱ្យបានវិលត្រឡប់ទៅគ្រងរាជ្យសម្បត្តិវិញ និងបានជាព្រះរាជានៃយើងគ្រប់គ្នា ។

ព្រះបរមពោធិសត្វ បានពោលទៅកាន់បិតាវិញថា ៖ បពិត្រព្រះមាតាព្រះបិតា ប្រយោជន៍អ្វីដល់ទ្រព្យសម្បត្តិ ព្រោះទ្រព្យសម្បត្តិក៏គង់តែនឹងអស់ទៅ, ប្រយោជន៍អ្វីដល់ភរិយា ពីព្រោះភរិយាក៏គង់តែស្លាប់, ប្រយោជន៍អ្វីដល់បុត្រ, ដល់រាជបល្ល័ង្ក ព្រោះរបស់ទាំងអស់នោះ ក៏គង់តែនឹងព្រាត់ប្រាសវិនាសបាត់បង់ទៅក្នុងពេលណាមួយ ។ ក្នុងលោកសន្និវាសនេះ តើនៅមានការសើចសប្បាយ ក្អាកក្អាយរីករាយអ្វីទៀត អាត្មាដឹងច្បាស់ណាស់ថា មច្ចុរាជពុំបានធ្វេសប្រហែសចំពោះអាត្មាឡើយ អាត្មាកំពុងត្រូវជរារួបរឹតផង មច្ចុរាជបៀតបៀនផង តើឱ្យមានការសប្បាយរីករាយ ត្រេកអរចំពោះបុត្រភរិយា ទ្រព្យសម្បត្តិ នោះដូចម្តេចកើត អាត្មារួចផុតចាកពីចំណងហើយ ។

ផ្លែឈើទាំងឡាយ ដែលទុំហើយរមែងមានភ័យ អំពីការជ្រុះអស់កាលជានិច្ច ។ យ៉ាងណាមិញ ពួកជនច្រើននាក់ ដែលគេតែងបានឃើញនៅពេលព្រឹក តែគេមិនអាចបានឃើញក្នុងពេលល្ងាចវិញ, ពួកជនច្រើននាក់ ដែលគេតែងបានឃើញក្នុងពេលល្ងាច តែគេពុំអាចបានឃើញក្នុងវេលាព្រឹកវិញ ។ ឯការព្យាយាមបំពេញបុណ្យ បុគ្គលត្រូវធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងអាចដឹងបានថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថា ការតទល់របស់យើងចំពោះមច្ចុរាជដែលមានសេនាដ៏ច្រើននោះ ពុំមានសោះឡើយ ។

សេចក្ដីសង្ខេបនៃប្រវត្តិរបស់ព្រះបរមពោធិសត្វ ក៏អាចបញ្ជាក់បានថា ការធ្វើដំណើរទៅមុខបានលឿន ក៏ត្រូវតែព្យាយាមលះដាក់ទម្ងន់ សម្រាលខ្លួនឱ្យបានស្រាល ទើបអាចធ្វើដំណើរបានងាយស្រួលឆាប់រហ័សដល់គោលដៅដោយពុំមានភាពវង្វេង ។ ក្រោយពេលដែលព្រះអង្គបានត្រាស់ដឹង និងបានលើកយកព្រះធម៌មកសម្ដែងប្រោសដល់សព្វសត្វទាំងឡាយ ទោះបីជាការសម្ដែងព្រះធម៌មានជាអនេកប្រការ ទៅតាមចរិតឧបនិស្ស័យ របស់សត្វលោកតែរៀងៗ ខ្លួន ។ យ៉ាងណាក៏ដោយ តែចំពោះបំណងមានតែម្យ៉ាង គឺឱ្យសត្វលោកបានធ្វើដំណើរឆ្ពោះទៅកាន់គោលដៅមួយ ដែលឱ្យឈ្មោះថា ជាការបញ្ចប់នៃជីវិតអន្ទោល ស្មើដូចគ្នាតែប៉ុណ្ណោះ ក្នុងសុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត លេខ ៤១ ទំព័រ ៤៥៣ យោធាជីវវគ្គ, ព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ត្រាស់សម្ដែងថា ៖ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈ អ្នករស់នៅដោយអំណាចទាហាន ប្រកបដោយអង្គបីគឺ ៖

**១- គឺជាអ្នកបាញ់បានឆ្ងាយ ;**

**២- ជាអ្នកបាញ់មិនខុស ;**

**៣- ជាអ្នកទម្លាយគំនរធំៗ បាន ។**


មិញ សាវ៉ាន
ចំណងដៃឆ្នាំថ្មី
ក្រុងម៉ុងរ៉េអាល - កេបិក - កាណាដា
ព.ស. ២៥៥៧ - គ.ស. ២០១៤
សម្រាប់ចែកជាធម្មទាន

# យោធាជីវៈបីប្រការ

**ទីមួយ**បាញ់បានឆ្ងាយ ឬអាចពោលថាសម្លឹងបានឆ្ងាយ ធម្មតាទាហានត្រូវជាអ្នកមានភ្នែកភ្លឺ ព្រមទាំងកាំភ្លើងដែលជាគ្រឿងយុទ្ធោបករណ៍ ។ ត្រូវបាញ់បានឆ្ងាយទៅរកទីតាំងរបស់ខ្មាំងសត្រូវ ទាំងបានកំណត់គោលដៅឱ្យបានពិតប្រាកដ ដោយស្មារតីរឹងប៉ឹងក្លាហាន ទាំងមិនស្រពិចស្រពិល ។ សេចក្តីនេះ ជាន័យត្រង់ទៅតាមកិច្ចនាទីរបស់ទាហាន តែបើសម្តែងតាមន័យព្រះធម៌ ជាព្រះពុទ្ធដីកាព្រះអង្គទ្រង់ត្រាស់ថា ៖ **ការសម្លឹងបានឆ្ងាយ ឬការបាញ់បានឆ្ងាយ គឺសម្លឹងត្រង់ចំ ឬបាញ់ត្រង់ចំអង្គសតិប្បដ្ឋានទាំងបួនប្រការមាន កាយានុបស្សនាសតិប្បដ្ឋាន, វេទនានុបស្សនាសតិប្បដ្ឋាន, ចិត្តានុបស្សនាសតិប្បដ្ឋាន, ធម្មានុបស្សនាសតិប្បដ្ឋាន** ។ សតិប្បដ្ឋាន បានដល់ទីតាំងរបស់សតិ ឬថាការលើកសតិឡើងរលឹកពិចារណា អង្គធម៌ទាំងបួនប្រការ មានកាយ វេទនា ចិត្ត ធម៌ ទាំងបួនប្រការនេះ ឱ្យឃើញបានថា គ្រាន់តែជាសភាវធម៌ពិតៗ ពុំមែនជាសត្វ ជាបុគ្គល ជាខ្លួនប្រាណជាយើង ជាគេ មានការកើតឡើងហើយក៏រលត់ទៅវិញ តាមបច្ច័យជាធម្មតានៃធម៌នោះៗ ។ ដូចជាការពិចារណាកាយ ឱ្យឃើញប្រច័ក្សច្បាស់ថា គ្រាន់តែជាការប្រជុំចុះនៃអាការៈទាំង ៣២ ប្រការតែប៉ុណ្ណោះ ដែលជាសហជាតិបច្ច័យនៃមហាភូតរូប គឺគ្រាន់តែជាផ្នែកនៃរូប ពិចារណាវេទនា គឺការសោយអារម្មណ៍ ជាសុខ ជាទុក្ខ ជាសោមនស្ស ជាទោមនស្ស ជាឧបេក្ខាក្តី ក៏គ្រាន់តែជាវេទនាចេតសិក មានការកើត

និងការរលត់រាល់ៗ ខណៈជាមួយចិត្ត ពិចារណាចិត្តធម៌ជាកុសល ជាអកុសល គឺគ្រប់ខណៈចិត្តក្តី ធម៌ក្តី សុទ្ធតែមានកិរិយាកើតឡើង និងត្រូវរលត់ទៅវិញគ្រប់ៗ ខណៈស្មើដូចគ្នា ជាធម្មតាទៅតាមហេតុបច្ច័យ ពុំមែនជាសត្វ ជាបុគ្គល ជាខ្លួនប្រាណ ហួងហែងហាមប្រាមពុំបានសោះឡើយ ។

ការពិចារណាដើម្បីឱ្យរលឹកដឹង នៅកាយ វេទនា ចិត្ត ធម៌ ដើម្បីដកចិត្តពីការប្រកាន់ ហួងហែងអំពីសភាវៈធម៌នោះៗ ។ ព្រោះអំណាចនៃឧបាទានខន្ធ ធ្វើឱ្យមានការប្រកាន់ជាប់ស្អិត ចំពោះកាយ វេទនា ចិត្ត ធម៌ ឱ្យទៅជាសត្វ បុគ្គល ខ្លួនប្រាណ រហូតដល់វង្វេងភ្លេចស្មារតីពុំអាចទទួលយល់ស្គាល់ ទៅតាមហេតុផលពិតបាន ។ ដូច្នេះការពិចារណាតាមអង្គនៃសតិប្បដ្ឋានក្តី ការដែលព្រះពុទ្ធជាម្ចាស់ ព្រះអង្គបានត្រាស់សម្តែង ពន្យល់លើកបង្ហាញអំពីព្រះបរមត្ថធម៌ គឺចិត្ត ចេតសិក រូប ទាំងនេះក៏ជាសង្ខតធម៌ គឺជាសង្ខតបច្ច័យ មានសភាពកើតឡើង និងរលត់ទៅរាល់ៗ ខណៈ ជាប្រក្រតីធម្មតាទៅតាមរលឹកដឹងទាន់របស់សតិ ដូចរលឹកពិចារណាដឹងនូវសភាពរបស់កាយ ក៏ចាត់ចូលក្នុងរូបបរមត្ថ ការរលឹកពិចារណាដឹងទាន់នូវវេទនាចាត់ចូលក្នុងវេទនា ជាចេតសិកបរមត្ថការរលឹកពិចារណាដឹងទាន់នូវចិត្ត ចាត់ចូលក្នុងចិត្តបរមត្ថ ។ ការរលឹកពិចារណាដឹងទាន់នូវធម៌ ក៏ចាត់ចូលក្នុងបរមត្ថ ឬថាក្នុងធម៌ជាកុសល ឬអកុសល ឬជាអព្យាកតៈ ។ បញ្ជាក់សេចក្តីមក ដើម្បីបង្ហាញមាគ៌ាដែលត្រូវត្រាច់ចរ ទៅកាន់គោលដៅមួយ ធ្វើការចេញចាកសេចក្តីទុក្ខតែប៉ុណ្ណោះ ។

**ទីពីរ** បាញ់មិនខុស បាញ់ត្រង់ តម្រង់ទៅរកគោលដៅណា ត្រូវចំទៅតាមគោលដៅនោះៗ តាមចិត្តដែលប្រាថ្នា តែបើជាពំនោលតាមព្រះពុទ្ធដីកា បានដល់ការរលឹកត្រង់ចំ ត្រូវតាមអរិយសច្ចទាំងបួនប្រការមាន **ទុក្ខសច្ចៈ** សេចក្ដីទុក្ខទាំង ១២ កង ១, **សមុទយៈ** បានដល់តណ្ហា ជាហេតុនាំឱ្យកើតសេចកក្ដីទុក្ខ ១, **និរោធ** បានដល់ទីរំលត់សេចក្ដីទុក្ខ ១ នឹងបានយល់ដឹងពី**មាគ៌ាបដិបទា** ជាផ្លូវប្រតិបត្តិដើម្បីមានដំណើរទៅកាន់ទីរំលត់សេចក្ដីទុក្ខ គឺព្រះនិព្វានមួយ ។ អរិយសច្ចទាំងបួនប្រការនេះ ជាសភាវធម៌ពិតរបស់ព្រះអរិយបុគ្គលគ្រប់រូបដែលលោកបានប្រតិបត្តិតាមអង្គអរិយមគ្គទាំងប្រាំបីប្រការ តាមលំដាប់ហើយ នៅទីបំផុតបានយល់ស្គាល់ពិតប្រាកដ ក្នុងចិត្តនូវអរិយសច្ចទាំងបួនប្រការនេះ ដោយកិច្ចទាំងបួនមាន **បរិញ្ញាកិច្ច** គឺការកំណត់ឃើញសេចក្ដីទុក្ខទាំងពួង មានការនឿយណាយធុញទ្រាន់ ។ **បហានកិច្ច** ព្យាយាមលះកំចាត់បង់តណ្ហា ដែលជាហេតុ ជាមេ ជាប្រភព បង្កបង្កើតសេចក្ដីទុក្ខទាំងពួងនោះ ។ **សច្ឆិកិរិយាកិច្ច** ធ្វើឱ្យជាក់ច្បាស់ ឬឃើញច្បាស់ ទីរំលត់នៃសេចក្ដីទុក្ខនោះៗ ដោយពិតប្រាកដច្បាស់លាស់ ។ **ភាវេតព្វកិច្ច** ការព្យាយាមចំរើន ការបតិបត្តិ ទៅតាមអង្គមគ្គ ដែលជាដំណើរចេញចាកសេចក្ដីទុក្ខ ឆ្ពោះទៅកាន់ព្រះនិព្វានដោយបញ្ញាដ៏ប្រពៃ ។

**ទីបី**អាចទម្លាយគំនរធំរបស់ខ្មាំងបាន គឺអាចទម្លាយទីតាំង ជំរំបច្ចាមិត្តបាន រហូតធ្វើឱ្យខ្មាំងសត្រូវឈរជើងមិននឹង វិនាសខ្ចាត់ខ្ចាយអន្តរាយអស់ឥតមានសេសសល់ ។ យ៉ាងណាមិញ គំនរធំក្នុងទីនេះបានដល់អវិជ្ជា ការមិនដឹង ភាពបិទបាំងធ្វើឱ្យងងឹតអង្គធម៌ បានដល់

មោហៈភាពវង្វេង អវិជ្ជានៅមានដរាបណា សត្វាពុំអាចកំណត់ដឹង សេចក្តីទុក្ខបាន ហេតុដែលនាំឱ្យកើតសេចក្តីទុក្ខ ទីរំលត់សេចក្តីទុក្ខ និងផ្លូវដែលត្រូវប្រតិបត្តិ ដើម្បីឆ្ពោះទៅរកទីរំលត់សេចក្តីទុក្ខបាន ។ ដូច្នេះ ការទម្លាយគំនរធំគឺអវិជ្ជានោះ ត្រូវទម្លាយដោយវិបស្សនាវិជ្ជា អង្គធម៌បានដល់បញ្ញា គឺការពិចារណា ឃើញនូវកាយ វេទនា ចិត្ត ធម៌ គ្រាន់តែជារូបធម៌ និងនាមធម៌តែប៉ុណ្ណោះ ។ រូបធម៌នាមធម៌នេះ ជាសង្ខតបច្ច័យ សភាវធម៌ណាអាស្រ័យហេតុ សភាវធម៌នោះ សុទ្ធតែត្រូវធ្លាក់ចុះក្នុងត្រៃលក្ខណ៍ធម៌ គឺអនិច្ចំ ភាពមិនទៀង, ទុក្ខំ ភាពជាទុក្ខ, អនត្តា ភាពមិនមែនជារបស់ខ្លួន ព្រោះមិនអាចស្ថិតក្រោមអំណាចរបស់ចិត្ត ។ អ្វីណាមិនទៀង អ្វីនោះឯងជាទុក្ខ, អ្វីណាជាទុក្ខ អ្វីនោះឯងជាអនត្តា នេះជាសភាវធម៌ដែលមានស្មើទូទៅ សម្រាប់ជីវិតអន្ទោលនៃសព្វសត្វក្នុងត្រៃភពនេះ ដូច្នេះកាលបើវិបស្សនា បញ្ញាចាស់ក្លាហើយជាលំដាប់ៗ អាចបានជាពន្លឺឆ្លុះបញ្ចាំង កម្ចាត់ភាពងងឹតឱ្យអស់ទៅ ឬថាជាអាវុធអាចកាច់បំបាក់ ដំបូលប្រក់បាំង រនាំងកំពែងអវិជ្ជា បន្សល់ទុកបានពន្លឺឆ្លុះបញ្ចាំងគោលដៅអាចត្រាច់ទៅត្រង់ចំ មិនយឺតយូរទៀតឡើយ ។ មានតែបញ្ញានេះហើយ ទើបអាចទម្លាយគំនរអវិជ្ជាបាន ។ នៅក្នុងអរិយមគ្គប្រកបដោយអង្គប្រាំបីប្រការ មានសម្មាទិដ្ឋិការយល់ឃើញត្រូវ, សម្មាសង្កប្បៈ ការត្រិះរិះត្រូវ ទាំងពីរប្រការនេះ ចាត់ថាជាបញ្ញា ជាអង្គធម៌ខាងដើម និងអាចឱ្យធម៌អង្គមគ្គដទៃទៀត កើតបន្តហៅថាសម្មាមគ្គ ជាកម្លាំងអាចប្រហារកងកិលេសឱ្យអស់ទៅ ជាសមុច្ឆេទបាន កាលបើកិលេស ភាពកករល្អក់អស់ហើយភាពថ្លា ភាពភ្លឺស្វាងក៏ប្រាកដឡើង អាចឆ្លុះបញ្ចាំងគោលដៅ

របស់ជីវិត ពិតប្រាកដដោយគ្មានភាពសង្ស័យ ស្រពិចស្រពិលទៀតឡើយ ។ ដូចជាជីវិតរបស់ព្រះអរិយបុគ្គលទាំងឡាយ សូម្បីតែព្រះអរិយបុគ្គលពួកខ្លះ លោកនៅមានជីវិតអន្ទោល តែគោលដៅជីវិតរបស់លោក មានជាក់ច្បាស់ប្រាកដ មិនយឺតយូរ មិនវង្វេងខុសទិសដូចជីវិតបុថុជ្ជនយើងទៀតឡើយ ។

ការសរសេររៀបរាប់របស់ខ្ញុំព្រះករុណាខ្ញុំបាទបន្ថែមទៀតនេះ គឺចង់បញ្ជាក់ឱ្យកាន់តែច្បាស់ អំពីគោលដៅនិងទីពឹងរបស់ជីវិត ព្រមទាំងមាគ៌ាជាគោលប្រតិបត្តិដែលព្រះដ៏មានព្រះភាគ ជាព្រះបរមគ្រូនៃយើងព្រះអង្គទ្រង់បានត្រាស់សម្តែងទុកប្រកបដោយ ព្រះមហាករុណាទិគុណ ទុកឱ្យសត្វក្នុងសង្សារវដ្តនេះ សត្វណាដែលមាននិស្ស័យខ្ពស់ មានកិលេសស្រាលស្តើង មានគោលបំណងប៉ងប្រាថ្នាចេញចាកពីវដ្តទុក្ខ ឆ្ពោះទៅកាន់គោលដៅមួយក្នុងការបញ្ចប់នៅភាពអន្ទោលដដែលៗ នោះ ។ ព្រះធម្មទេសនារបស់ព្រះអង្គមានច្រើនជាអនេកបរិយាយ ក៏ពិតមែនតែចំពោះគោលដៅ ឬពុទ្ធបំណងមានតែម្យ៉ាង គឺការរលាស់ចោលសេចក្តីទុក្ខ ប្រៀបដូចប្រភេទរបស់អាហារមានច្រើនប្រការ ក៏ដើម្បីតម្រូវទៅតាមចំណង់ចំណូលរបស់អ្នកបរិភោគតែប៉ុណ្ណោះ ។ តែចំពោះគុណភាព ឬសារជាតិរបស់អាហារ ក៏គឺដើម្បីកំចាត់នៅសេចក្តីស្រេកឃ្លាននិងបានទ្រទ្រង់នៅសរីរាង្គកាយនេះ ឱ្យចំរើនទៅបានតាមអាយុកាលតែម្យ៉ាងប៉ុណ្ណោះ ។ ត្រង់ចំណុចនេះឯងដែលយើងជាពុទ្ធសាសនិកជន ត្រូវព្យាយាមសិក្សាដឹងយល់ចូលចិត្ត ដោយពុំចាំបាច់លើកយកគោលការណ៍ ធម៌លោកគ្រូអាចារ្យនេះ អាចារ្យនោះ មកវិភាគឱ្យឈឺក្បាល ដោយការយល់ឃើញ

ខុសចាកព្រះពុទ្ធដីកានោះទេ គឺគ្រាន់តែយល់ថាព្រះធម៌ ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្ដែង គឺជាច្បាប់ធម្មជាតិ ព្រះធម៌ក៏គឺជីវិត, ជីវិតក៏គឺជាធម៌ ដូច្នេះការសម្ដែងព្រះធម៌របស់ព្រះអង្គគឺសម្ដែង បើកបង្ហាញប្រាប់អំពីហេតុផល ច្បាប់របស់ធម្មជាតិនិងដំណោះស្រាយដែលមានជុំវិញ សម្រាប់ជីវិតអន្ទោលដោយពុំបានឱ្យពុទ្ធសាសនិកប្រកាន់មាំឬជាប់ចិត្ត ចំពោះព្រះរូបកាយ ឬព្រះពុទ្ធដីកាដែលព្រះអង្គសម្ដែងនោះទេ ពុទ្ធបំណងក្នុងការសម្ដែង គឺឱ្យសត្វលោកបានស្ដាប់បានយល់ចូលចិត្តចេញចាកពីការប្រកាន់ ដែលជាប្រភពនៃសេចក្ដីទុក្ខនោះឯង ដូចបានពោលរៀបរាប់មកហើយ ដែលជាសំណេរមាននៅក្នុងសៀវភៅនេះ ដូច្នេះសូមលោកអ្នកអានយល់បានត្រឹមតែពុទ្ធបំណង របស់ព្រះពុទ្ធបរមគ្រូនៃយើង គឺជាការស្រេច ដោយពុំចាំបាច់យកចិត្តគិតគូរទើសទាស់ ចំពោះលោកអាចារ្យខ្លះដែលគាត់លើកយកធម៌ មកពោលអួតអាង ថាជាធម៌របស់គាត់ ដោយឡែកផ្សេងពីធម៌របស់ព្រះពុទ្ធ ឬបុគ្គលពួកខ្លះ ប្រាប់គេឯងថាខ្លួនជាព្រះ សម្រេចបានយ៉ាងនេះយ៉ាងនោះ បុគ្គលប្រភេទនោះឈ្មោះថា ជាអ្នកឆ្ងាយចាកពីអរិយវង្ស ដែលមិនចាំបាច់ឱ្យយើងត្រូវការយកចិត្តទុកដាក់ ចំពោះបុគ្គលប្រភេទនោះ នាំឱ្យខ្វល់ចិត្ត បាត់បង់ពេលវេលានោះទេ ។



# សាកល្បងសន្ទនាគ្នា

មានពំនោលច្រើនណាស់ បានបញ្ចេញមកជាសំណួរខ្លះ, ជាចម្លល់ខ្លះ, ជាការផ្ចញ់ផ្ចាល់ខ្លះ, ជាការវិភាគដើម្បីឱ្យមានចំណេះដឹងខ្លះ ដោយការដាក់ទោសទៅលើព្រះពុទ្ធសាសនាជាព្រះពុទ្ធដីកា ។ ដូចជាមានសំណួរយ៉ាងនេះថា ៖ ព្រះពុទ្ធសាសនាបរិយាយដោយច្រើនតែពាក្យថាបាបបុណ្យ គុណទោស អតីត អនាគត ដូចជាសំណេរក្នុងសៀវភៅ ដែលកំពុងតែអាននេះក៏ដែរ គឺពោលតែអំពីគោលដៅនៃការបញ្ចប់របស់ជីវិត ស្លាប់ទៅហើយបីដូចជា បញ្ចប់ការត្រេកត្រអាលសប្បាយរីករាយ នៅក្នុងលោកដ៏ស្រស់ត្រកាលនេះ ដែលជាហេតុធ្វើឱ្យអ្នកអាន រៀន ស្ដាប់ មានការធុញទ្រាន់ រអាចិត្តទៅវិញ និងមានពំនោលច្រើនណាស់ ដែលពោលសង្កត់អំពីកម្ម ថាជាធម្មជាតិតាក់តែង វិចិត្ររចនាជីវិតសព្វសត្វក្នុងសកលពិភពនេះ ឱ្យទាបខ្ពស់ខុសដោយឡែកពីគ្នា សត្វលោកមានកម្មជាកំណើត មានកម្មជាមរតកជាផៅពង្ស មានកម្មជាទីពំនឹងអាស្រ័យ ។ល។និង។ល។ ពំនោលអំពីកម្មដូច្នេះឯង ទើបធ្វើឱ្យលោកអ្នកមួយចំនួន លោកយល់មិនដល់ឆ្ងល់មិនអស់ បានលើកយកជាសំណួរយ៉ាងនេះថា បើជាយ៉ាងនោះ សត្វលោកមានតែរស់នៅទៅតាមយថាកម្ម បណ្ដោយទៅតាមចំណែកនៃកម្ម ចាត់ចែងតាក់តែងកំណត់សំណាងព្រេងវាសនា ឱ្យតែម្យ៉ាងទៅឬ? ដោយពុំបាច់មានចំណែកណាមួយ មកផ្លាស់ប្ដូរអំណាចកម្លាំងរបស់កម្មបានទេឬ? ។ ត្រង់ចំណុចនេះបើពុំធ្លាប់បានប្រើគំនិតគិត

ពិចារណាទេនោះ ក៏គង់មានការទញ់ទាល់ ក្នុងការបរិយាយពន្យល់ខ្លះជាមិនខាន ព្រោះការស្តាប់របស់យើងមកជាយ៉ាងនោះ រហូតដល់ស៊ាំត្រចៀកទៅហើយ ក៏ប៉ុន្តែបើយើងជាអ្នកធ្លាប់បានស្តាប់ បានរៀនពិចារណារឿយៗ ទៅតាមព្រះពុទ្ធដីកា ក៏អាចកំណត់យល់ និងមានដំណោះស្រាយពន្យល់គ្នាបានខ្លះ ទៅតាមហេតុផលនៃកម្មនោះៗ ។

ប្រសិនបើសំណួរសួរថា តើយើងពុំអាចកែប្រែកម្មបានទេឬ? ចម្លើយថាបាន... ព្រោះហេតុអ្វី? ព្រោះសត្វជាអ្នកសាងកម្ម, នេះជាភាសាឬថាជាវោហារ ការពោលទៅតាមបែបបញ្ញត្តិ ដើម្បីឱ្យងាយស្តាប់ ។ បើដូច្នេះមិនបានឈ្មោះថា ជាអ្នកពោលបង្អាច់ព្រះពុទ្ធដីកាទេឬ? ព្រោះព្រះអង្គត្រាស់ថា សត្វលោកស្ថិតនៅក្រោមអំណាចនៃកម្ម ។ ពិតមែនហើយបើយើងស្តាប់ភ្លាមទៅ ក៏ហាក់បីដូចជាយើង ពោលផ្ទុយខុសអំពីព្រះពុទ្ធដីកា ឬថាសទ្ធម្មប្បដិរូបដូច្នេះវិញក៏បាន ប៉ុន្តែបើយើងពិចារណាបន្តិចទៀត គឺស្តាប់ត្រង់ចំណុចណាហើយកុំឱ្យចេះតែជាប់ទៅលើចំណុចនៃពាក្យនោះតែម្យ៉ាង ត្រូវព្យាយាមពិចារណាឱ្យយល់ដល់ជម្រៅអត្ថន័យ ព្រោះព្រះពុទ្ធដីកាតែមួយពាក្យៗ ដែលប្រសូតចេញពីព្រះឱស្ឋរបស់ព្រះអង្គ មានន័យច្រើនប្រការណាស់ ដែលសត្វនៅជាភាពបុថុជ្ជន ពុំអាចដឹងឆ្លុះយល់ឱ្យបានអស់នោះឡើយ ។ ដូចជាពាក្យថា សត្វលោកតែងប្រព្រឹត្តទៅតាមកម្ម ឋិតនៅក្រោមអំណាចនៃកម្ម ត្រង់ន័យនេះយើងនាំគ្នាស្តាប់រហូតដល់ទៅជាប់ប្រកាន់ ចូលចិត្តទៅតាមពាក្យនោះដូច្នោះ ឬក៏នៅតែមានការស្រពេចស្រពិល សង្ស័យក៏ពុំអាចយល់ចូលចិត្ត ចំពោះន័យនោះឱ្យដល់ជម្រៅបាន ។ ដូច្នេះសូមយើងសាកល្បង សន្ទនាគ្នាដើម្បីបង្កើត

ការយល់ដឹងរបស់យើង ឱ្យបានដល់ជម្រៅតទៅទៀត ។ ពាក្យថាកម្ម ប្រែថាការងារ ការប្រព្រឹត្តិធ្វើ កិរិយាប្រកបការងារទាំងពួង ដូចជាពាក្យថា ពាណិជ្ជកម្ម, កសិកម្ម, ឧស្សាហកម្ម, បសុកម្ម, វេជ្ជកម្ម, បុញ្ញកម្ម, បាបកម្ម, កុសលកម្ម, អកុសលកម្ម...។ល។ ដូច្នេះជាដើម ពាក្យថាកម្ម នេះមានសេចក្ដីអធិប្បាយទូលំទូលាយ ជាអនេកបរិយាយណាស់ តែក្នុងទីនេះដើម្បីកុំឱ្យវែងឆ្ងាយ យើងត្រឹមតែយល់ថា កម្មគឺជានាមឬកិរិយាស័ព្ទ សំដៅដល់កិរិយានៃការធ្វើ ដូច្នេះកម្មពុំមែនកើតឡើងដោយឯងៗ ដោយឥតមានអ្នកធ្វើនោះទេ ។ សត្វលោកជាអ្នកសាងកម្ម វិបាកគឺផលរបស់កម្មនេះ ទើបជាធម្មជាតិឬថាជាសភាវៈ តាក់តែងចាត់ចែង ភពជាតិកំណើត សត្វលោក យសស័ក្តិ ឋានៈតំណែង អំណាច នាទី សម្បត្តិទ្រព្យ ចំណេះដឹង របស់សត្វលោកឱ្យខ្ពស់ទាប សុខទុក្ខខុសដោយឡែកពីគ្នា ទៅតាមយថាកម្មរបស់សត្វលោករៀងៗខ្លួន ។

ព្រោះតែសត្វលោក ជាអ្នកសាងកម្មដូច្នេះហើយ ទើបអាចផ្លាស់ប្ដូរកែប្រែកម្មបាន ដូចជាជម្រុះចោលកម្មអាក្រក់ បំពេញកម្មល្អជំនួសវិញ ។ ត្រង់ចំណុចនេះឯង ដែលយើងអាចនាំគ្នានិយាយថា មនុស្សអាចសាងខ្លួនឱ្យទៅជាទេវតា ជាព្រហ្ម ជាព្រះពុទ្ធ ជាព្រះបច្ចេកពុទ្ធ ជាព្រះអរិយបុគ្គល ជាប្រាជ្ញបណ្ឌិត ជាពាល ជាសត្វនរក ប្រេត តិរច្ឆាន អសុរកាយបាន ក៏មកអំពីសត្វលោក ជាអ្នកសាងកម្មនេះឯង ។ ព្រោះដូច្នេះឯង ទើបចាត់ថាកម្ម សត្វលោកអាចផ្លាស់ប្ដូរកែប្រែបាន តើអាចយល់ចូលចិត្តបានខ្លះហើយឬនៅ? ។

ចុះអ្វីទៅដែលគេពុំអាចកែប្រែឬផ្លាស់ប្ដូរបាន?ព្រោះយើងធ្លាប់

ស្តាប់រហូតដល់ទៅជាប់ចិត្តថា សត្វលោកតែងប្រព្រឹត្តទៅតាមអំណាចនៃកម្ម មានកម្មចាត់ចែងផ្តល់កំណើត សុខទុក្ខព្រោះកម្ម ។ រឿងនេះវាដូច្នេះពិតមែនហើយ អ្វីដែលគេពុំអាចកែប្រែផ្លាស់ប្តូរបាននោះ **"ជាវិបាក គឺជាផលរបស់កម្ម"** ត្រង់ចំណុចនេះឯង ទាំងលោកអ្នកសម្តែងព្រមទាំងលោកអ្នកស្តាប់ ពុំសូវបានជាវែកញែកចែកឱ្យដាច់អំពីគ្នានោះទេ ទើបធ្វើឱ្យមានការងឿងឆ្ងល់ ច្របូកច្របល់ក្នុងចិត្ត មិនអស់មិនហើយ ចេះតែមានសំណួរ ចម្លើយពុំចេះចប់ ដូច្នេះត្រូវខំព្យាយាមត្រិះរិះពិចារណាជារឿយៗ ដើម្បីចម្រើនបណ្តុះការយល់ដឹងឱ្យបានដល់ជម្រៅនៃព្រះពុទ្ធដីកា ឱ្យចូលចិត្តច្បាស់ថា អ្វីជាបច្ច័យជាហេតុ អ្វីជាផលឱ្យបានច្បាស់ដូចជាពាក្យថាកម្ម និងវិបាកជាផលដ៏ឆ្អិនរបស់កម្មនេះជាដើម តើអាចស្តាប់បានយល់ចូលចិត្តដែរឬទេ? មើលទៅដូចជានៅរសេមរសាមពុំទាន់ច្បាស់ស្រឡះក្នុងចិត្តទេ បើដូច្នេះ យើងនឹងបានស្តាប់ការប្រៀបធៀប ដើម្បីការស្វែងយល់ឱ្យកាន់តែប្រសើរទៅទៀត ។ លោកអ្នកប្រាជ្ញតែងធ្វើឧបមាឧបមេយ្យយ៉ាងនេះថា **កម្មទុកដូចជាត្រា ឯវិបាកជាផលដ៏ឆ្អិនរបស់កម្មនោះ ទុកដូចជាស្នាមរបស់ត្រា** ដែលបានបោះជាប់ហើយនៅលើក្រដាស ។ កិច្ចការផងទាំងពួងដែលគេបានធ្វើកតិកាចុះខសន្យាគ្នា អំពីហេតុការណ៍អ្វីមួយ ឃើញថាចុះសម្រុងគ្នា អាចយកជាការ អាចសម្រេចចេញជាផល ទោះបីជាកាលវេលាជាបច្ចុប្បន្នចំពោះមុខក្តី ជាកាលវេលាទៅខាងមុខក្តី គឺជាកិច្ចចុះសម្រុងគ្នាហើយ ទើបគេប្រថាប់ត្រា ឬបោះត្រាទៅលើក្រដាសដែលជាកំណត់ហេតុនោះ ចាត់ជាកិច្ចសម្រេចផល អាចយកជាការណ៍បាន ដោយពុំអាចកែប្រែនៅអ្វីៗ ដែលបានព្រមព្រៀងគ្នាហើយ

ដោយសំអាងទៅលើស្នាមត្រានៅលើក្រដាស ជាកំណត់ហេតុនោះឯង ។

ន័យនេះយ៉ាងណា វិបាកដែលជាផលរបស់កម្មនេះឯង ដែលចាត់ចែងតាក់តែងសត្វលោក ឱ្យថ្លៃថ្នូរថោកទាបខ្ពង់ខ្ពស់ ខុសដោយឡែកពីគ្នា ហើយដែលគ្មានសត្វណាអាចកែប្រែផ្លាស់ប្តូរបាន ដូចជាស្នាមត្រាដែលជាប់នៅលើក្រដាសហើយដូច្នោះដែរ ។ ចំណែកឯកម្មទុកដូចជាត្ឋត្រា គឺគ្រាន់តែជាហេតុ ឬគ្រាន់តែជាពូជដែលអ្នកណាៗ ក៏អាចយកទៅសាបព្រោះបណ្តុះដាំបាន នៅទីកន្លែងណា លើដីប្រភេទណា តាមសេចក្តីប្រាថ្នាចំណង់ចំណូលចិត្ត របស់អ្នកបណ្តុះដាំផ្សាំសាបព្រោះនោះ ។ ព្រោះហេតុដូច្នោះហើយ ទើបចាត់ថាកម្មនេះ ទុកដូចជាត្ឋត្រា ប្រសិនបើគេចង់យកទៅទីណា ដាក់នៅត្រង់កន្លែងណា គេអាចដាក់បាន ប្តូរផ្លាស់បាន ។ ចំណែកស្នាមត្រាវាបានជាសំណាមដាមជិតជាប់នៅលើក្រដាសរួចទៅហើយ ដូច្នេះយើងអាចយល់ចូលចិត្តបាន ទៅតាមការឧបមាឧបមេយ្យយ៉ាងនេះ ។ កម្មយើងអាចជាអ្នកសាង យើងអាចរើសធ្វើបំពេញទៅតាមចំណូលចិត្តរបស់យើងបាន ដោយពុំបានពឹងផ្អែកទៅលើបុគ្គលណា ឬក៏ចាំបាច់អំពាវនាវស្រែកដង្ហោយបន់ស្រន់ អង្វរកររកវត្ថុស័ក្តិសិទ្ធិ ជាជំនួយនោះទេ យើងប្រាថ្នាចង់បានផលបែបណា ផ្លែផ្កាដូចម្តេច ក៏សម្រេចចិត្តរើសរកយកពូជបែបនោះ មកបណ្តុះដាំផ្សាំព្រោះទៅជាការស្រេច ។

សេចក្តីអធិប្បាយមកប៉ុណ្ណោះនេះ តើល្មមស្តាប់យល់ចូលចិត្តបានខ្លះដែរឬទេ? បានហើយ ចូលចិត្តដែរហើយចំពោះការសន្ទនាអធិប្បាយមកប៉ុណ្ណោះនេះ ដូចជាការបើកបង្ហាញ និងការបង្កើនសេចក្តី

ដឹង យល់ឱ្យបានកាន់តែប្រសើរឡើង នឹងបានព្យាយាមកម្ចាត់បង់នូវអ្វីដែលជាពូជអាក្រក់ កខ្វក់ មិនល្អចោលចេញ បំពេញជំនួសវិញនូវអ្វីដែលជាពូជល្អបន្ត តាមទ្វារកាយ វាចាចិត្ត ដើម្បីសេចក្តីសុខ សម្រាប់ខ្លួន គ្រួសារ សង្គមជាតិ សង្គមលោក ទៅតាមចេតនា ចិត្តជាកុសលទុកជាប្រយោជន៍ ទាំងក្នុងបច្ចុប្បន្ន បរលោក ជារៀងរហូតតទៅ ។ ព្រះពុទ្ធដីកាទោះផ្នែកណា ជាផ្នែកព្រះវិន័យក្តី ព្រះសូត្រក្តី ព្រះអភិធម្មក្តី សុទ្ធតែមានន័យគម្ភីរភាព (ភាពជ្រៅ, ជម្រៅ) ពុំមែនយើងអាចចូលចិត្តយល់សេចក្តីបានដោយងាយនោះទេ ដូចជាពាក្យថាកម្មនេះជាដើម ។ យើងជាពុទ្ធសាសនិក ពុទ្ធសាសនិកា ធ្លាប់បានស្តាប់ឡើងជ្រេញត្រចៀកទៅហើយ ចំណែកលោកអ្នកសម្តែងដដែលៗ អំពីពាក្យថាកម្មនេះ ក៏សឹកបបូរមាត់ដែរហើយ ចំណែកឯការយល់ដឹង ត្រូវពឹងលើបញ្ញាការត្រិះរិះពិចារណា របស់លោកអ្នកស្តាប់ តើបានដល់កម្រិតណាដែរតែប៉ុណ្ណោះ ព្រោះព្រះធម៌ដែលព្រះអង្គលើកយកមកសម្តែង គ្រប់តែព្រះធម៌គឺព្រះអង្គត្រាស់ដឹងដោយ (ព្រះពុទ្ធញ្ញាណ) គឺជាបញ្ញាប្រកបដោយពន្លឺ ពុំមែនចេះតែប្រកបការថាពោលស្តី ដោយខ្វះការយល់ដឹង ឬគ្រាន់តែជាការត្រិះរិះដៅស្មាននោះទេ ដូច្នេះគ្រប់ការសម្តែងព្រះធម៌របស់ព្រះអង្គ ប្រោសដល់សត្វលោក ប្រកបដោយព្រះហឫទ័យពោរពេញដោយព្រះមេត្តាមហាករុណាទិគុណ ការសម្តែងព្រះធម៌អ្វីដែលមិនប្រាកដច្បាស់ ដែលសត្វលោកដឹងមិនដល់ឆ្ងល់មិនអស់ ពុំអាចចាប់យកអត្ថន័យសេចក្តីបាននោះ ព្រះអង្គពុំបានត្រាស់សម្តែងទេ ពីព្រោះពុំមែនជាវិស័យរបស់បុគ្គលអ្នកស្តាប់ ។

ដូចជាពាក្យថា នរក ស្ឋគ៌ជាដើមនោះ នៅពេលដែលបាន

ត្រាស់ដឹងឡើងភ្លាម ព្រះអង្គពុំបានត្រាស់សម្តែងទេ លុះចំណោរកាល ជាខាងក្រោយមក ព្រះអង្គបានស្តាបនាសាវ័ករបស់ព្រះអង្គ ឱ្យបាន សម្រេចធម៌ជាន់ខ្ពស់ជាព្រះអរហន្ត ប្រកបព្រមដោយវិជ្ជានិងអភិញ្ញា មានការដឹងយល់ស្គាល់ឃើញ ពីស្ថាននរកសួគ៌ដូចព្រះអង្គដែរ ទើប ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីស្ថាននរកសួគ៌នោះ ដល់អ្នកមានចម្ងល់ ក្នុងការប្រាថ្នាសួរចំពោះព្រះអង្គ ។ ចំណែកនៃការសម្តែងអំពីបាប បុណ្យ គុណទោស ខុសត្រូវ កុសល អកុសល កម្មនេះ គឺទ្រង់ប្រោស ប្រទានសម្តែងអ្វីៗ ដែលមានពិតប្រាកដ នៅជុំវិញជីវិតនេះដែលល្មម ឱ្យសត្វលោកអាចពិចារណាដឹងយល់ សម្គាល់ចូលចិត្តបានខ្លះដោយ ខ្លួនឯង នឹងឱ្យបានយល់ដឹងក្នុងការវែកញែកចែកចេញ ហេតុនិងផល ឱ្យយល់ចូលចិត្ត កុំផ្ចិតយកជាប់ចិត្តតែត្រឹមពាក្យ ដូចជាយើងបាន ស្តាប់ជារឿយៗ នៅពាក្យថា បាបបុណ្យ គុណទោស សុចរិត ទុច្ចរិត កុសល អកុសល កម្មអាក្រក់ កម្មល្អ យុត្តិធម៌ អយុត្តិធម៌ ទាំងអស់នេះ ទុកជាហេតុ ជាបច្ច័យ ជាពូជជាដើម ។ ជាផលគឺ អ្វីជាផ្លែផ្កា ជារសជាតិ តែការស្តាប់របស់យើងនៅមានកម្រិតទើបពុំអាចវែកញែក ហេតុផល ឱ្យដាច់ចេញពីគ្នាបាន ។ ដូច្នេះហើយទើបព្រះអង្គទ្រង់ត្រាស់សម្តែង ពីបរមត្ថធម៌ឱ្យសត្វបានស្តាប់ ឱ្យសត្វបានចាប់យកអត្ថន័យ យល់ សេចក្តីកាន់តែច្បាស់រហូតវែកចេញ ហេតុ បច្ច័យ វិបាក ឱ្យបានយល់ ចូលចិត្ត កាន់តែពិតប្រាកដច្បាស់ឡើង ។ ការសរសេរនិងការសន្ទនា ដោយសង្ខេបអំពីពាក្យថាកម្មនេះ ក៏ដើម្បីបញ្ជាក់និងបានជាការឱ្យ កម្លាំងចិត្ត ព្រមទាំងបានដាស់តឿនស្មារតី ដល់គ្នានឹងគ្នា កុំឱ្យអាក់អន់ ស្រពន់ចិត្ត ដ្បិតតែយើងកើតមកចំលើត្រកូលតូចទាប ក្រីក្រ លំបាក

គោកយ៉ាក ខ្វះមុខ ខ្វះក្រោយ ពុំស្រណុកសុខសប្បាយដូចជាគេ ព្រោះឱ្យតែមានកាយសម្បទាគ្រប់គ្រាន់ មានស្មារតីបរិបូរណ៍ យើងអាចព្យាយាមប្តូរជាតិកំណើតរបស់យើង ដោយការប្តូរផ្លាស់លះបង់កម្មអាក្រក់ជាកម្មចាស់ បំពេញកម្មថ្មីជាកម្មល្អ បន្តជាតិកំណើតយើងឱ្យបានល្អទៅទៀតបាន ។

ដែលថាដាស់តឿនស្មារតីនោះ ចំពោះលោកអ្នកបានកើតមកក្នុងត្រកូលខ្ពង់ខ្ពស់ មានយសស័ក្តិទ្រព្យសម្បត្តិ ចំណេះដឹងតំណែងនាទីត្រកូលវណ្ណៈល្អប្រសើរ តែជាអ្នកវង្វេងស្រវឹង មានះ រឹងត្អឹងសម្លឹងប្រឹងមើលត្រឹមតែកាយខ្លួនសាងបាបកម្មលាមក ជាជនចង្រៀតសង្គមបំផ្លាញលោក នោះឈ្មោះថាជាអ្នកកំពុងតែប្តូរផ្លាស់បំផ្លាញកម្មល្អ ជាកម្មចាស់ដែលខ្លួនមាន ឱ្យវិនាសសូន្យសោះអស់ទៅ បន្សល់នៅតែភាពអាក្រក់វិបាកអកុសល ។ អកុសលវិបាកនេះឯងដែលផ្លាស់ប្តូរជាតិកំណើត ភពភូមិស្ថានឱ្យបានសេចក្តីទុក្ខជំនួសវិញ ។ នេះគឺជាសភាពធម្មតា ឬថាច្បាប់របស់កម្មនិងផលរបស់កម្ម ។ ដូចយើងបានសន្ទនាមកហើយថា អតីតកម្មដែលបានផលិតឱ្យចេញជាវិបាកហើយ យើងពុំអាចប្តូរផ្លាស់ ឬកែប្រែបាន តែចំពោះបច្ចុប្បន្នកម្មចំពោះមុខ យើងអាចប្តូរបាន អាចជ្រើសរើសរកយកតែកម្មល្អមកប្រតិបត្តិ កំចាត់បង់កម្មអាក្រក់ បង្កើតបានជាផលគឺកុសលវិបាក ជាពូជកំណើតល្អបន្តទៅសម្រាប់ជីវិត ។

ដែលថាសត្វលោក ធ្វើដំណើរតាមផ្លូវឆ្ងាយ តែងត្រូវការស្បៀងអាហារតែមួយតម្រូវការ សម្រាប់ផ្គត់ផ្គង់អត្តភាពរាងកាយនេះឱ្យមានថាមពលចលនាក្នុងការធ្វើដំណើរតាមដងផ្លូវបាននិងតម្រូវការ

ផ្សេងទៀត គឺអាហារខាងផ្លូវចិត្ត បានដល់ធម្មាហារ គឺបុណ្យកុសលកម្មល្អដែលផ្តល់វិបាកល្អកំដរផ្លូវចិត្ត ឱ្យប្រព្រឹត្តទៅក្នុងភាពជាសុខកាលបើសេចក្តីសុខតាមកាយចិត្តងាយស្រួលហើយ ការធ្វើដំណើរតាមដងផ្លូវរមែងបានស្រាលងាយឆាប់រហ័ស បានដល់គោលដៅតាមប្រាថ្នា ។ ដូច្នេះពំនោលពីកម្មផលក្នុងព្រះពុទ្ធសាសនា ជាការបញ្ជាក់អំពីហេតុផលឱ្យសត្វលោកបានយល់ចូលចិត្ត ពិតប្រាកដច្បាស់ សុខទុក្ខ ចម្រើនវិនាស រមែងកើតចេញបានអំពីចរិយាការប្រព្រឹត្តិខ្លួនឯងផ្ទាល់តែម្តង ពុំចាំបាច់ឱ្យខ្វល់ខ្វាយចង្អុល ដាក់ទោសកំហុសទៅឱ្យអ្នកនេះ អ្នកនោះច្រើនពេកទេ ។

ត្រង់សំណួរថា ហេតុអ្វីបានជាក្នុងព្រះពុទ្ធសាសនា ច្រើនពោលពីកាលវេលាជាអតីត អនាគត បច្ចុប្បន្ន តើដើម្បីជាប្រយោជន៍អ្វីដែរ? ថាកាលវេលាជាបច្ចុប្បន្នទៅ គេអាចបានឃើញផ្ទាល់ សម្គាល់ដឹងឮបានខ្លះ, ចំណែកអតីត អនាគត ជាកាលវេលាដែលគេពុំអាចដឹងដល់ យល់ឆ្ងល់បានដោយងាយៗ នោះទេ បើគេចូលចិត្តប្រើគំនិតគិតពីកាលវេលាជាអតីត អនាគតច្រើនដរាបណា ការស្មុគស្មាញចិត្តនិងការខ្វាយខ្វល់ចង្អៀតចង្អល់តាមផ្លូវចិត្ត ក៏រមែងមានច្រើនដរាបនោះដែរ តើពុំមែនដូច្នេះទេឬ?

ពិតមែនហើយអ្វីដែលគេដឹងមិនដល់ ឆ្ងល់មិនអស់ រមែងធ្វើឱ្យគេចូលចិត្តប្រើផ្នត់គំនិត គិតពិចារណារកដំណោះស្រាយ ដើម្បីបង្កើតការយល់ដឹងបំបាត់ចម្ងល់នោះ ។ ប៉ុន្តែបើនៅតែច្របូកច្របល់ខ្វាយខ្វល់ដល់គិតមិនចេញវិញនោះ ទាំងនេះនឹងបានធ្វើឱ្យមានស្មារតីភ្ញាក់រលឹកក្នុងចិត្ត ស្ងើចអស្ចារ្យ សរសើរលើកកម្ពស់ ដល់លោកអ្នកជា

ម្ចាស់ពំនោល គឺអង្គព្រះសាស្តាដែលព្រះអង្គទ្រង់បានលើកយកមកត្រាស់សម្តែង ប្រកបដោយន័យនឹងប្រាកដជាមានប្រយោជន៍ ដល់លោកអ្នក ដែលបានស្តាប់ចាប់យកអត្ថន័យ មកពិចារណាបង្កើតនៅបញ្ញាការយល់ដឹង រហូតដល់អស់ចម្ងល់ការសង្ស័យនោះទៅបាន ។

ទោះបីជាក្នុងព្រះពុទ្ធសាសនា បានសម្តែងអំពីកាលវេលាមានអតីតកាល អនាគតកាល បច្ចុប្បន្នកាលយ៉ាងណាក៏ដោយ តែរាល់ព្រះពុទ្ធដីកា ព្រះអង្គសម្តែងសង្កត់ធ្ងន់លើកាលវេលាជាបច្ចុប្បន្ន (ដូចក្នុងបិដកលេខ ២៨) ព្រះអង្គទ្រង់ត្រាស់ចំពោះភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនគប្បីស្រណោកស្រណោះអាឡោះអាល័យស្តាយចំពោះបញ្ចក្ខន្ធ ឬអ្វីៗ ដែលជាអតីតកាល ហើយក៏មិនគប្បីស្រណោកស្រណោះអាឡោះអាល័យ ប្រាថ្នាចំពោះបញ្ចក្ខន្ធ ឬអ្វីៗដែលជាអនាគតដែរ ពីព្រោះខន្ធណា ឬអ្វីណាដែលជាអតីតកាល ខន្ធនោះ អ្វីនោះ ក៏បានកន្លងហួសបាត់ទៅហើយ ចំណែកឯខន្ធណា អ្វីណាដែលជាអនាគត ខន្ធនោះ អ្វីនោះ ក៏នៅពុំទាន់មានមកដល់ ។ ម្យ៉ាងទៀតបុគ្គលឃើញច្បាស់នូវធម៌ជាបច្ចុប្បន្ន គឺឃើញច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាម និងមិនញាប់ញ័រដោយកងកិលេស គប្បីចម្រើនផលឈានសមាបត្តិដែលមានព្រះនិព្វានជាអារម្មណ៍ ឯការព្យាយាមជាគ្រឿងកម្ចាត់បង់កិលេស បុគ្គលគប្បីធ្វើក្នុងថ្ងៃនេះឯង តើអ្នកអាចដឹងថា សេចក្តីស្លាប់នឹងមានមកក្នុងថ្ងៃស្អែកបាន ព្រោះការតទល់របស់យើង ចំពោះមច្ចុដែលមានសេនាដ៏ច្រើននោះ ពុំបានសោះឡើយ ។ កាលបើយើងបានស្តាប់សេចក្តីសង្ខេបខ្លីមកប៉ុណ្ណោះ ក៏អាចបញ្ជាក់បានថា ជាព្រះពុទ្ធដីកា ដែលសង្កត់ធ្ងន់ទៅលើកាលវេលា

ជាបច្ចុប្បន្ន ក៏ប៉ុន្តែព្រះអង្គពុំបានកាត់ចោល អតីតកាលនិងអនាគតកាលនោះទេ ព្រោះហេតុនោះ បានជាព្រះអង្គទ្រង់បានសម្តែងរំលឹកជារឿយៗ ដែលមានក្នុងព្រះសូត្រផ្សេងៗ មានជាអនេកបរិយាយទាក់ទងអំពីប្រវត្តិមនុស្ស សត្វ ទេវតា ឥន្ទ្រ ព្រហ្មក្នុងជីវិតអន្ទោលសូម្បីតែជីវិតពិតរបស់ព្រះអង្គ កាលពុំទាន់បានសម្រេចសម្មាសម្ពោធិ-ញ្ញាណ ក៏ត្រូវស្ថិតនៅក្នុងសភាពបែបនេះដែរ ។ ដូច្នេះការត្រាស់សម្តែងអំពីកាលវេលា ជាអតីត អនាគតបច្ចុប្បន្ន ភាគច្រើនដោយមានភិក្ខុទាំងឡាយ ព្រមទាំងសមណព្រាហ្មណ៍ ទូលសួរចង់ដឹង អារាធនាព្រះអង្គឱ្យសម្តែង ទើបព្រះអង្គសម្តែងដើម្បីបំបាត់ចម្ងល់ សេចក្តីសង្ស័យនៃអ្នកទាំងឡាយនោះ ។

ពិតមែនហើយក្នុងសម័យដែលចម្រើនដោយសម្ភារៈនិយម ឬថាចម្រើនដោយវិទ្យាសាស្ត្រ បច្ចេកវិជ្ជាគ្រប់បែបយ៉ាងនេះ គេច្រើនមានពំនោលក្នុងផ្នត់គំនិត ចំពោះតែវេលាជាបច្ចុប្បន្នប៉ុណ្ណោះ គេពុំសូវបានប្រើផ្នត់គំនិត គិតពីអតីតកាលឬអនាគតកាលនោះទេ រហូតដល់បុគ្គលពួកខ្លះ ហ៊ានបដិសេធដោយគ្មានជំនឿលើហេតុផល ជាអតីត-កាល អនាគតកាលទៀតផង ។ គេមានផ្នត់គំនិតលើតែសមត្ថភាពបញ្ញាស្មារតី ចំណេះដឹង ដែលគេមានតែម្យ៉ាងប៉ុណ្ណោះ ទើបធ្វើឱ្យបុគ្គលខ្លះ បានក្លាយទៅជាមានះ ប្រកាន់លើកកម្ពស់ រហូតហ៊ានមើលងាយអ្នកដទៃ ភ្លាំងភ្លេចស្មារតី ដោយភាពវង្វេងងល់ងប់ ព្រោះតែលាភសក្ការៈ នាទីតំណែងយសស័ក្តិ សម្បត្តិបរិវារ ឥតព្រមទទួលស្តាប់គ្រាប់តាមមតិអ្នកដទៃ ដែលជាសេចក្តីល្អ ដើម្បីទុកពិចារណារចនាកែច្នៃចិត្តគំនិត កំហុសឆ្គងរបស់ខ្លួនអ្វីទៀតនោះទេ ព្រោះតែ

សម្អាងទៅលើសមត្ថភាព បញ្ញាស្មារតីចំណេះដឹងរបស់គេតែម្យ៉ាង រហូតដល់ទាត់ចោលកម្មផល បាបបុណ្យគុណទោស ទាំងកាលវេលាជាអតីត អនាគតទៀតផង ។ ទាំងនេះតើអាចចាត់ថា ជាទង្វើខុសទាំងស្រុងដែរឬទេ? មិនខុសទាំងស្រុងទេ ត្រូវដែរជាបយោគសម្បត្តិ គឺផលដែលបានសម្រេចអំពីកិច្ចការ ព្រោះសេចក្តីព្យាយាមក្នុងកាលវេលាជាបច្ចុប្បន្ន ។ និយាយយ៉ាងនេះកុំអាលទាន់បានចិត្តពេក ត្រូវយល់ចូលចិត្តតទៅទៀតថា ការដែលបានសម្រេចជោគជ័យ សមតាមបំណងប៉ងប្រាថ្នារបស់ខ្លួននោះ ពុំមែនមានកត្តាតែក្នុងកាលវេលាជាបច្ចុប្បន្នប៉ុណ្ណោះទេ គឺត្រូវអាស្រ័យកត្តាដែលមានមកក្នុងកាលវេលាដែលជាអតីតផងដែរ ពុំមែនទេឬ? ដូចបុគ្គលពួកខ្លះគេក៏មានសេចក្តីព្យាយាមប្រឹងប្រែងតស៊ូ អស់ពីកម្លាំងកាយចិត្ត សមត្ថភាពដែរ តែក៏ពុំអាចបានសម្រេច ឬក៏បានសម្រេចខ្លះដែរ តែពុំអាចសមស្របទៅតាមគោលបំណងប៉ងប្រាថ្នារបស់ខ្លួន ។ បើយើងបានឃើញ និងបានពិចារណា តាមហេតុការណ៍ដូចពោលថាមកនេះ យើងនឹងបានបន្ធូរបន្ថយការលើកតម្លៃ បំប៉ោងមានះខ្លួនឱ្យបានថយចុះ ជំនួសមកវិញនូវភាពអាណិតអាសូរជាក់ជាពុំខាន ។

ដើម្បីឱ្យបានយល់ដល់ជម្រៅ កាន់តែចូលចិត្តច្បាស់តទៅទៀត សូមយើងនាំគ្នាស្តាប់ ព្រមទាំងពិចារណា ទៅតាមព្រះពុទ្ធដីកាដែលព្រះអង្គទ្រង់ត្រាស់សម្តែងអំពីសម្បត្តិបួនប្រការ ជាផលដែលកើតចេញបាន អំពីបុណ្យដែលបានបំពេញតម្កល់ទុកហើយអំពីអតីតជាតិ (**បុព្វេកតបុញ្ញតា**) :

**ទី ១. គតិសម្បត្តិ :** ដល់ព្រមដោយដំណើរនៃការកើត ជា

កំណើត មនុស្ស ទេវតា ព្រហ្ម ទៅតាមសភាពនៃកុសល ដែលបានសន្សំកសាងទុកហើយពីអតីតកាល ជាកាមាវចរកុសលខ្លះ ជាមហគ្គតកុសលខ្លះ នេះយើងពុំបាននិយាយដល់លោកុត្តរកុសលទេ ។

**ទី ២. ឧបធិសម្បត្តិ** : បើបានកំណើតជាមនុស្ស រមែងមានកាយសម្បទាបរិបូណ៌ មានស្មារតីល្អ មិនពិកលពិការ ។

**ទី ៣. កាលសម្បត្តិ** : ដល់ព្រមដោយកាលសម័យល្អ គឺកើតមកត្រូវកាលសម័យ ដែលប្រទេសជាតិមាតុភូមិសំបូណ៌សប្បាយ មានសន្តិភាព ស្ថេរភាពគ្រប់ស្ថាប័ន មានវត្តអារាមសាលារៀនមន្ទីរពេទ្យ ប្រជានុរាស្ត្របានសិក្សាសូត្ររៀន គោរពបដិបត្តិតាមសិក្ខាវិន័យ រស់នៅប្រកបមុខរបរបានសុខដុមរមនា ។

**ទី ៤. បយោគសម្បត្តិ** : ដូចខ្ញុំព្រះករុណា ខ្ញុំបាទ បានសរសេររៀបរាប់មកហើយ ទាំងនេះដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ថា កាលវេលាជាអតីត អនាគត បច្ចុប្បន្ន រមែងមានប្រទាក់គ្នាជារដឹកមិនដាច់ ។ បច្ចុប្បន្នអាចឱ្យបានសម្រេចផលដោយល្អបាន ដោយការព្យាយាមផង ដោយបច្ច័យនៃបុណ្យពីអតីតផងដែរ ចំណែកសេចក្តីល្អក្នុងបច្ចុប្បន្នក៏ជាបច្ច័យជាពូជល្អ សម្រាប់អនាគតកាលដូចគ្នា ។

យើងតែងនាំគ្នាពោលថា ការងារសម្រេចដោយព្យាយាមប្រាកដជាត្រឹមត្រូវតាមចំណែកមួយ សូម្បីព្រះពុទ្ធជាម្ចាស់ព្រះអង្គត្រាស់ដឹងឡើងក្នុងលោក ក៏ព្រោះតែសេចក្តីព្យាយាម ព្រះធម៌ទេសនារបស់ព្រះអង្គ ក៏សង្កត់ធ្ងន់ដោយសេចក្តីព្យាយាម ពុំមែនឱ្យខ្ជិលច្រអូសដេកចាំព្រេងវាសនាទេ ។ តែព្រះអង្គបានបង្រៀនឱ្យសត្វលោកបើកចិត្តឱ្យទូលាយ ដើម្បីសេចក្តីយល់ដឹងនិងឱ្យចេះមានបញ្ញា

ស្មារតីថ្លឹងថ្លែង កុំចេះតែអាងទៅលើសមត្ថភាពខ្លួនឯងតែម្យ៉ាង រហូតដល់ឡើងចាងតិះដៀលមើលងាយអ្នកដទៃ ដោយខ្វះក្ដីមេត្តាទៅវិញ ដោយសម្លឹងឃើញថាអ្នកដទៃដែលក្រីក្រថោកទាប ទន់អន់ជាងខ្លួន ក៏ព្រោះតែជាមនុស្សខ្ជិលច្រអូស ខ្វះសេចក្ដីព្យាយាម ទាំងនេះពិតជាមិនខុសទេ ក៏ប៉ុន្តែពុំមែនត្រូវទាំងអស់នោះដែរ ។

យើងពុំចាំបាច់លើកយក អតីតកាលដែលយើងដឹងពុំដល់ឆ្ងល់មកនិយាយនោះទេ ហើយក៏មិនបាច់លើកយកពួកជនទម្រុនខ្ជិលច្រអូសមកនិយាយដែរ យើងលើកយកពួកជនដែលមានសេចក្ដីព្យាយាម មកពោលស្ដីដូចគ្នាដើម្បីជាការពិចារណា យើងនឹងអាចយល់បានថា នៅក្នុងលោកនេះ ឬថានៅក្នុងប្រទេសនីមួយៗ ទោះបីជាប្រទេសដែលបានអភិវឌ្ឍន៍ហើយ ឬកំពុងតែអភិវឌ្ឍន៍ក្ដី ក្នុងចំណោមប្រទេសនោះៗ មានអ្នកព្យាយាមអង់អាចក្លាហាន មានបញ្ញាប្រកបការងារបានជោគជ័យសម្រេចជាលោកសេដ្ឋី កវី អ្នកប្រាជ្ញបានប៉ុន្មាននាក់ អាចរាប់បានថាមានប្រមាណតិច ។ ដូច្នេះការព្យាយាមប្រឹងប្រែង ដើម្បីឱ្យបានទៅជាសេដ្ឋី ឬជាមនុស្សអស្ចារ្យ ឃើញថាមិនច្រើនទេ ក៏ប៉ុន្តែក្នុងចំណោមនៃអ្នកអសមត្ថភាព ភាគច្រើនទាំងនោះក៏មានខ្លះដែរ ជាអ្នកដែលធ្លាប់រៀនរួមថ្នាក់ជាមួយលោកសេដ្ឋីនោះ មានទាំងអ្នកជំនួយការ សមាគម ប្រកបកិច្ចការសព្វសារពើជាមួយ ទាំងសុទ្ធសឹងតែជាអ្នកប្រាថ្នា ចង់បាន ចង់មានតំណែងឋានៈជាអ្នកអស្ចារ្យ ជាលោកសេដ្ឋីតែក៏គ្មានវាសនា ទាំងនេះព្រោះហេតុអ្វី? ត្រង់ចំណុចនេះយើងសង្កេតឃើញចំពោះការព្យាយាម ក្លាហាន បញ្ញាការយល់ដឹង ប្រហាក់ប្រហែលគ្នា មកដាក់ជាបទវិភាគ នឹងបានពិចារណា

ត្រឡប់ឡើងវិញ អំពីកាលវេលាដែលជាអតីត បច្ចុប្បន្ន អនាគតដែលមានទំនាក់ទំនងរដឹកជាប់គ្នាមិនដាច់ ដើម្បីកុំឱ្យយើងភ្លេចខ្លួន ភ្លេចស្មារតី ថាខ្លាំងដោយសមត្ថភាពខ្លួនឯងតែម្យ៉ាង រហូតទាត់ចោល កម្មចាស់ កម្មថ្មីដោយគ្មានការពិចារណានោះ ។ ដូច្នេះការរៀនយល់ ឱ្យស្គាល់ពីកាលវេលា ជាហេតុបង្កើនស្មារតីយើង ហើយចេះមានក្តីសង្វេគ ឱ្យមានមេត្តាក្នុងការបន្ទាបខ្លួន សម្របខ្លួនចូលក្នុងសង្គម និងចេះរំលែកចែកអ្វីដែលខ្លួនមាន ជួយដល់សង្គមទៀតផង ព្រមទាំងជាអ្នកចេះឱ្យតម្លៃទៅលើការងារ និងតម្លៃគុណធម៌ ដោយភាពជាអ្នកមិនភ្លាំងភ្លេចស្មារតី ដោយយល់ច្បាស់ថា កាលវេលាតែងប្រទាក់ជាប់គ្នាមិនដាច់ និងមានបច្ច័យតាក់តែងបង្កើតរបស់មួយ ឱ្យជាតំណទៅរបស់មួយ អំពីរបស់នេះ ទៅរករបស់នោះ ដោយពុំអាចហាមប្រាមឃាត់ឃាំងរាំងរាបានសោះឡើយ ទាំងដែលគេអាចទំនាយទៅក្នុងកាលអនាគតកាលបាន ក៏ព្រោះគេយល់អំពីហេតុក្នុងកាលជាបច្ចុប្បន្នកាលនេះឯង ប្រសិនណាបើកាលទាំងបីពុំបានវិវដ្តជាប់តគ្នាទេនោះ គេក៏ពុំអាចសាងអ្វីៗ ក្នុងកាលជាបច្ចុប្បន្ន តភ្ជាប់ទៅអនាគតបានទេ ដូចជាការសិក្សាមុខវិជ្ជាផ្សេងៗ តាំងតែពីថ្នាក់បឋម មធ្យម ឧត្តម មុខវិជ្ជាដែលបានសិក្សាដល់ថ្នាក់ឧត្តម, ជាកាលវេលាដែលបានសិក្សាកន្លងអស់ទៅហើយក្នុងរយៈតៗមក និងជាហេតុជាបច្ច័យជួយឧបត្ថម្ភ ដល់ការសិក្សាក្នុងមុខវិជ្ជាផ្សេងៗ ទៀតបាន តាមលំដាប់ឆ្នាំជាបន្តបន្ទាប់ទៅទៀតបាន ដោយមានសញ្ញា ការកំណត់កត់សម្គាល់ ចងចាំតភ្ជាប់គ្នាមិនដាច់ អំពីកាលវេលាដែលកន្លងទៅហើយនោះឯង ។ ចំណែកឯការកសាងបារមីធម៌ក៏ដូច្នោះដែរ ឱ្យបានទៅជាព្រះពុទ្ធ ព្រះបច្ចេក

ពុទ្ធ ព្រះអរហន្តជាសាវ័ក សាវិការបស់ព្រះពុទ្ធនោះក៏ដូច្នោះដែរ ប្រសិនបើកាលវេលាពុំមានការទំនាក់ទំនង ចង តដើម្បីជាបច្ច័យក្នុងការភ្ជាប់ដល់គ្នានោះទេ អ្វីៗ ក៏ពុំអាចសម្រេចចេញផលបានឡើយ ហើយក៏ពុំអាចសម្រេចទៅដល់គោលដៅមួយ តាមសេចក្ដីប្រាថ្នានោះទេ ដូចជាការសាងបារមី ដើម្បីឱ្យបានត្រាស់ជាព្រះពុទ្ធ ក៏មានកាលកំណត់ជាអនេកប្បការ ។

ការរៀបរាប់អំពីកាលវេលាទាំងបីប្រការនេះ ដើម្បីជាស់តឿនស្មារតីដល់លោកអ្នកដែលមានជោគជ័យ លើភ័ព្វវាសនាការងារ វិជ្ជា តំណែងនាទីអំណាច ដែលអាចនិយាយពោលស្ដីថា បានដោយភាពក្លាហាន ឱ្យអ្នកដទៃបានស្ដាប់ចាប់ជាអារម្មណ៍ បែរជាច្រឡំភ្លេចស្មារតីឱ្យតម្លៃទៅលើសមត្ថភាព សេចក្ដីអង់អាចក្លាហានរបស់ខ្លួនតែម្យ៉ាងទាំងជាហេតុឱ្យលើកកម្ពស់តម្កើងខ្លួន មើលងាយអ្នកដទៃ ជាហេតុឱ្យអស់តម្លៃខ្លួនទៅវិញ និងជាហេតុឱ្យភ្លេចគិតដល់ពាក្យបុរាណ បានពោលទុកមួយឃ្លាយ៉ាងនេះថា **"ខ្ពស់កប់ពពក គង់ធ្លាក់មកជ្រកអាចម៍ជន្លេនបាន"** ។ ពាក្យពេចន៍នេះ គឺជាសភាពពិតដែលគេអាចទទួលយល់ស្គាល់បានថា អ្វីៗនៅក្នុងលោកិយនេះមិនទៀង តែងមានចលនាប្រែប្រួលទៅ ពីសភាពមួយទៅកាន់សភាពមួយ ដោយពុំអាចប្រកែកបាន ឬការពារបាន ពីមានទៅក្រ ពីក្រទៅមាន សុខទុក្ខសើចយំ ធំតូចអាក្រក់ល្អសខ្មៅ នេះគឺជាច្បាប់ធម្មជាតិ ឥតមានគម្លាតពីកាលវេលាដែលជាបញ្ញត្តិនោះសោះឡើយ ។ ចុះបើដូច្នោះមែនគេពុំអាចកែប្រែច្បាប់ធម្មជាតិបាន តើត្រូវធ្វើដូចម្ដេចវិញ? ចម្លើយគឺត្រូវព្យាយាមទទួលស្គាល់យល់ព្រម ទៅតាមហេតុការណ៍ដែលមានប្រាកដចំពោះ

មុខ ដូចជាក្នុងសម័យកាលដែលកំពុងលោតផ្លោះបោះជំហានប្រដេញតាមការចម្រើនលូតលាស់ដុះដាល តាមសម្ភារៈនិយមនេះ យើងអាចបញ្ជាក់បាន ដូចជាមាស ពេជ្រ សំណ ស្ពាន់ រ៉ែ ដែក ប្រេង កើតចេញពីដីទៅតាមសភាពធម្មជាតិនោះៗ និងត្រូវអាស្រ័យកាលវេលាជាយូរអង្វែងណាស់ ទើបកើតឡើងបាន ហើយវត្ថុដូចពោលមកនេះ ទោះបីជាសម័យវិទ្យាសាស្ត្រចម្រើនដល់កម្រិតណា ក៏ពុំមានសមត្ថភាពអាចបង្កើតវត្ថុធាតុដើមទាំងនោះបានដែរ ។ ទាំងនេះក៏អាចបញ្ជាក់បានថាជាការហួសសមត្ថភាព បញ្ញាស្មារតី ភាពក្លាហាន ដែលពុំអាចធ្វើឱ្យសម្រេចបានក្នុងចំណែកខ្លះ ប៉ុន្តែអ្វីដែលគេអាចធ្វើទៅបានក៏មានដែរ ដូចជាគេអាចកែច្នៃវត្ថុធាតុដើមទាំងនោះឱ្យបានទៅជាសម្ភារៈសម្រាប់បម្រើតម្រូវការរបស់មនុស្សលោកឱ្យបានសប្បាយរីករាយងាយស្រួល និងអាចបំផ្លាញមនុស្សលោកឱ្យដល់នូវការវិយោគសោកសៅ និងរលាយវិនាសអស់ទៅវិញក៏បានដែរ ។

ការពោលរៀបរាប់មកនេះ ក៏ដើម្បីបញ្ជាក់ឱ្យយល់ចូលចិត្ត ពីច្បាប់ធម្មជាតិដែលមានមក ហើយក៏ប្រព្រឹត្តទៅតាមសភាពដើម ដែលយើងពុំអាចកែប្រែឱ្យដូចបំណងចិត្តបាន ដូចជាចាស់ ឈឺ ស្លាប់ ការស្រេកឃ្លាន សុខ ទុក្ខដែលមានជាធម្មតា ។ ដូច្នេះទើបមានព្រះសាស្ដាសម្មាសម្ពុទ្ធ ព្រះអង្គបានឈ្វេងរៀនយល់អំពីច្បាប់ធម្មជាតិ រហូតបានយល់ដឹងពិតច្បាស់អំពីច្បាប់ធម្មជាតិ ដោយ**ពុទ្ធញ្ញាណ**គឺការត្រាស់ដឹង ព្រះអង្គទ្រង់បានលើកយកច្បាប់ធម្មជាតិ មកត្រាស់សម្ដែងថ្លែងដល់សត្វលោកនេះ កុំឱ្យដើរបញ្ច្រាសពីច្បាប់ធម្មជាតិ គឺព្រះអង្គទ្រង់ត្រាស់សម្ដែង បង្រៀនសត្វលោកឱ្យចេះដឹង ទទួលស្គាល់ យល់ព្រមចេះ

ព្យាយាមខំប្រឹងកែច្នៃសម្របខ្លួន ទៅតាមច្បាប់ធម្មជាតិនោះ ដូចជា ជាតិ ចាស់ ឈឺ ស្លាប់ មានសេចក្តីស្រេកឃ្លាន សុខទុក្ខ មាន នេះគឺជា សេចក្តីពិត ដែលមានប្រចាំជីវិតក្នុងកាលជាបច្ចុប្បន្ន ដូច្នេះព្រះពុទ្ធ ដីការបស់ព្រះអង្គ ទោះបីជាបែងចែកកាលវេលាជាបីកាល មានទាំង អតីត អនាគត បច្ចុប្បន្នក៏ពិតមែន តែព្រះអង្គបានសម្តែងសង្កត់ធ្ងន់ ទៅក្នុងបច្ចុប្បន្នកាល ដូចបានអធិប្បាយមកហើយ ព្រោះគ្រប់ចលនា របស់ជីវិតដែលថាត្រាច់ចរតាមផ្លូវឆ្ងាយនោះ ទោះបីជាជីវិតស្ថិតនៅ ក្នុងប្រភេទណាក៏ដោយ គឺកើតមកហើយ ក៏ត្រូវចាស់ឈឺស្លាប់ទៅវិញ ក្នុងមួយជាតិៗ ឬក្នុងមួយអត្តភាពនោះៗ ដដែលៗ ស្មើដូចគ្នា ។ រីឯ សេចក្តីស្លាប់នេះ ពុំមែនបានន័យថា បញ្ចប់ជាតិកំណើតតែត្រឹម ប៉ុណ្ណោះទេ គឺស្លាប់ហើយត្រូវតែកើតជាតិកំណើតថ្មីទៀត ត្រូវចាស់ ឈឺ ស្លាប់ ស្រេកឃ្លាន សុខទុក្ខ តាមយថាកម្មជាប្រចាំ នេះគឺជាក្រសែ វដ្ដ: ដែលហៅថាផ្លូវឆ្ងាយនេះឯង ។ ដូច្នេះទើបធ្វើឱ្យជីវិតនេះ ត្រូវតស៊ូ ព្យាយាមប្រណាំងប្រជែង ចំពោះបញ្ហារហូតដល់ភ្លេចគិតអំពីសេចក្តី ស្លាប់ ដែលមានមកជាមួយជីវិតនេះ ។ ពិតមែនហើយ ជីវិតអាចបំភ្លេច សេចក្តីស្លាប់បាន តែសេចក្តីស្លាប់ ពុំដែលបានបំភ្លេចជីវិតសូម្បីតែមួយ ខណៈនៃខ្យល់ដង្ហើមចេញចូលនោះទេ ដូច្នេះហើយទើបពំនោលក្នុង ព្រះពុទ្ធសាសនាបានបង្រៀនឱ្យយើង មានលំនឹងក្នុងជីវិតតាំងតែពី កកើតមក ជារៀងរហូតដល់ការត្រឡប់ទៅវិញ ជាចុងបញ្ចប់របស់ជីវិត មួយជាតិៗ គឺសេចក្តីស្លាប់ ដោយការរៀនរស់និងចេះរៀនស្លាប់ផង ។

# អវសានគថា

## (ការរៀនយល់នឹងអំពីការកើតនិងស្លាប់)

ចិត្តអាក្រក់ អកុសលចិត្ត, ចិត្តល្អជាកុសលចិត្ត របស់បុគ្គលគ្រប់ៗ រូប ឬជាអំពើល្អនិងអាក្រក់ដែលបុគ្គលបានធ្វើ តែងតែមានជានិច្ចនៅក្នុងចិត្តរបស់បុគ្គលម្នាក់ៗ ជានិច្ចជាកាល ។ នៅពេលដែលបុគ្គលចាប់កំណើតមានជីវិតភ្លាម សេចក្តីស្លាប់ក៏កើតមានព្រមជាមួយគ្នា ដល់បុគ្គលគ្រប់រូបជាប្រាកដ ។ នៅពេលធ្វើមរណកាលទៅ បុគ្គលគ្រប់រូបតែងតែបន្សល់ទុកដោយពុំអាចយកទៅជាមួយបាន នូវទ្រព្យសម្បត្តិទាំងអស់ដែលខ្លួនមាន សូម្បីបុគ្គលជាទីស្រឡាញ់របស់ខ្លួន ដោយត្រូវតែចាកចេញពីលោកនេះ ឆ្ពោះទៅចាប់ជាតិក្នុងភពមួយទៀតសម្រាប់អនាគតជាតិរៀងៗ ខ្លួន ។ ដូច្នេះកិច្ចសំខាន់មួយដែលយើងត្រូវតែយល់ដឹង នៅការផ្លាស់ប្តូរខណៈចិត្តភ្លាមៗ នៅពេលដ៏ខ្លី មុនពេលធ្វើមរណកាល ពេលមុនដាច់ខ្យល់ស្លាប់ ហើយនឹងថានៅពេលនោះ តើបុគ្គលម្នាក់ៗ ធ្វើយ៉ាងដូចម្តេច? ដើម្បីប្រឈមចំពោះសេចក្តីស្លាប់ដែលនឹងមកដល់ ។

# គុណមាតាបិតា



រៀបរៀងដោយ

ឧបាសក មិញ សាវ៉ាន

សម្រាប់ចែកជាធម្មទាន

# ហេតុបួនយ៉ាងនៃមរណៈ

ហេតុបួនយ៉ាងនៃមរណៈគឺ ៖

**១. ការស្លាប់ដោយផុតកំណត់របស់អាយុកាល (អាយុក្ខ-យមរណៈ)**

**២. ការស្លាប់ដោយអស់កម្លាំងកម្ម (កម្មក្ខយមរណៈ)**

**៣. ការស្លាប់ដោយហេតុទី ១ និងទី ២ រួមគ្នា (ឧភយក្ខ-យមរណៈ)**

**៤. ការស្លាប់ដោយកម្មដទៃចូលមកកាត់បង់ (ឧបច្ឆេទកម្មុនា)**

ការប្រៀបប្រដូចដែលអាចងាយយល់បានដោយស្រួល គឺការគេប្រៀបសេចក្តីស្លាប់ទៅនឹងការរលត់ របស់ភ្លើងនៃចង្កៀងប្រេងកាត ហេតុដែលនាំឱ្យភ្លើងចង្កៀងរលត់មាន :

**១. ចង្កៀងអស់ប្រេង;**

**២. ចង្កៀងនោះអស់ប្រឆេះ;**

៣. ហេតុទាំងពីរកើតឡើងព្រមៗ គ្នា ក្នុងពេលតែមួយជាមួយគ្នា;

៤. ហេតុកើតពីខាងក្រៅដូចជា ខ្យល់បក់ឱ្យរលត់ ឬមានគេផ្លុំឱ្យរលត់ ។

# សេចក្តីពន្យល់អំពីហេតុនៃសេចក្តីស្លាប់ទាំងបួនយ៉ាង

## ១. មរណភាពដោយការផុតកំណត់អាយុកាល

អាយុកាលនៃសត្វមានជីវិតនៅក្នុងភពទាំងអស់ខុសៗ គ្នា ក្នុងភពមនុស្សយើងនេះ អាយុកាលមានរយៈកាលខុសគ្នា ទៅតាមសម័យកាលរបស់ផែនដី ប្រសិនបើមនុស្សជាតិវិវឌ្ឍន៍ថយក្រោយដោយការប្រព្រឹត្តិអំពើអាក្រក់ មនុស្សអាចរស់នៅបានយ៉ាងខ្លីចំនួន ១០០ ឆ្នាំ ប្រសិនបើមនុស្សជាតិ វិវឌ្ឍន៍ទៅមុខដោយនាំគ្នា សាងអំពើល្អឱ្យបានច្រើនទាំងអស់គ្នានោះ មនុស្សអាចរស់បានរហូតអាយុកប្បដែលមានរយៈពេលច្រើនអសង្ខេយ្យឆ្នាំដែលមិនអាចរាប់បាន ។

នៅសម័យពុទ្ធកាល គេបាននិយាយថា អាយុកាលរបស់មនុស្សមានប្រមាណ ១០០ ឆ្នាំ, បច្ចុប្បន្ននេះអាយុកាលរបស់មនុស្សទូទៅបាន ៧៥ ឆ្នាំ ។ មនុស្សដែលមានប្រភេទបុណ្យជាសាមញ្ញ មិនអាចរស់បានលើសពី ៧៥ ឆ្នាំឡើយ លើកលែងតែអ្នកចាប់បដិសន្ធិដោយកម្លាំងកុសលកម្មយ៉ាងខ្លាំងទើបអាចរស់បានលើសពី ៧៥ ឆ្នាំ ។ អាយុកាលវែងលើសពីធម្មតារបស់បុគ្គលខ្លះៗ អាចមានទៅតាមកម្មល្អពីអតីតជាតិរបស់គេម្នាក់ៗ ។

កាលពីសម័យព្រះពុទ្ធសមណគោតម, ព្រះមហាកស្សបៈ ព្រះអានន្ទ និងព្រះនាងវិសាខា ដែលបានបរិច្ចាគទានដោយសាងសង់វត្តអារាម អ្នកទាំងនោះមានអាយុវែងរហូតដល់ ១២០ ឆ្នាំ ។ ព្រះមហាថេរបាគូឡា មានព្រះជន្មរហូតដល់ ១៦០ ឆ្នាំ ។ ព្រះអង្គទាំងនោះ

មានកម្មពីអតីតជាតិយ៉ាងប្រពៃអស្ចារ្យ គួរជាទីគោរព បុគ្គលសាមញ្ញទូទៅដែលពុំមានកុសលកម្មពីអតីតជាតិដូចព្រះអង្គទាំងនោះ មិនអាចរស់នៅលើសពី ៧៥ ឆ្នាំឡើយ ។ មរណភាពដូចបានអធិប្បាយមកនេះមានឈ្មោះថា ស្លាប់ដោយការអស់ឬផុតកំណត់អាយុកាល ដែលប្រៀបដូចជាការអស់ប្រេងរបស់ចង្កៀងប្រេងកាត ទោះបីជាប្រឆេះចង្កៀងនៅមានទៀត ក៏ពុំអាចបញ្ចេញពន្លឺបានទៀតឡើយ ។

## ២. មរណកាលដោយការអស់កម្លាំងកម្ម (កុសលកម្ម)

កម្លាំងកម្មទាំងឡាយដែលកំណត់ជីវិតបុគ្គលនីមួយ ៗ និងទ្រទ្រង់ជីវិតបុគ្គលនោះតាំងពីចាប់កំណើតក្នុងផ្ទៃមាតា រហូតដល់កម្លាំងកម្មនោះអស់ទៅ មានកុសលកម្មច្រើនប្រភេទទៀតដែលទ្រទ្រង់បុគ្គលនីមួយ ៗ ហើយនៅពេលដែលកម្មនោះអស់ទៅ បុគ្គលនោះនឹងស្លាប់ បើទោះណាជាអាយុកាលរបស់បុគ្គលនោះ មិនទាន់ផុតកំណត់ក៏ដោយ គឺមានន័យថាកម្លាំងកម្មដែលទ្រទ្រង់បុគ្គលនោះរលត់ក្នុងពេលដែលបុគ្គលនោះមានអាយុ ៥០ ឆ្នាំ បុគ្គលនោះពុំអាចរស់បានរហូតដល់ ៧៥ ឆ្នាំ ដែលជាកំណត់អាយុកាលរបស់មនុស្សទូទៅឡើយ ។ នេះប្រៀបបាននឹងចង្កៀងដែលរលត់ទៅ ដោយអស់ប្រឆេះបើ ទោះបីជាមានប្រេងកាតសល់នៅក្នុងចង្កៀងនៅឡើយ ។

## ៣. មរណភាពបណ្តាលមកពីហេតុទី ១ និងទី ២ កើតព្រមគ្នា

មានបុគ្គលខ្លះ ទទួលមរណភាពដោយការផុតកំណត់អាយុកប្ប និងអស់កម្លាំងបុណ្យក្នុងពេលជាមួយគ្នា គឺប្រៀបដូចភ្លើងចង្កៀងដែលរលត់ទៅនៅពេលដែលចង្កៀងនោះអស់ប្រឆេះនិងអស់

ប្រេងព្រមជាមួយគ្នា មរណកាលបែបនេះ ហៅថាកាលមរណៈ ។

**៤. ឧបច្ឆេទកកម្មមរណៈ**

ឧបច្ឆេទកកម្មមរណៈ បានន័យថាស្លាប់មុនការផុតកំណត់អាយុកាល ឬមុនអស់កម្លាំងកម្ម ។ បុគ្គលខ្លះមានវាសនា និងអាចរស់រហូតដល់ផុតអាយុកាល ឬអស់កម្លាំងកម្មរបស់ខ្លួន ប៉ុន្តែអកុសលកម្មដែលខ្លួនបានធ្វើពីអតីតជាតិមកឱ្យផល អកុសលកម្មនោះ បណ្តាលឱ្យបុគ្គលនោះ ទទួលឧបច្ឆេទកកម្មមរណៈ ។ មរណភាពបែបនេះប្រៀបបាននឹងភ្លើងចង្កៀង ដែលរលត់ដោយខ្យល់បក់ ឬដោយមានគេផ្លុំពន្លត់ តែនៅពេលនោះប្រេង និងប្រឆេះចង្កៀងនៅមាននៅឡើយ ។ មរណភាពបែបនេះ កើតដោយសារកម្លាំងអកុសលកម្ម មកឱ្យផលកាត់មុខ អាយុកាលនិងកម្លាំងកម្មនៃបុគ្គលនោះ ។

ព្រះមហាមោគ្គល្លាន កាលនៅពីអតីតជាតិមួយរបស់លោក បានធ្វើឃាតមាតាបិតាលោក បាបកម្មនោះបានតាមឱ្យផល ដោយលោកត្រូវចោរ ៥០០ នាក់ សម្លាប់លោកមុនពេលបរិនិព្វាន ។ ព្រះបាទពិម្ពិសារ ក្នុងអតីតជាតិរបស់ព្រះអង្គ បានពាក់ស្បែកជើងដើរក្នុងព្រះវិហារ ដោយអំណាចនៃកម្មនោះ ព្រះអង្គត្រូវចូលទីវង្គតដោយសារមុខរបួសនៅជើង ព្រោះតែព្រះរាជបុត្ររបស់ព្រះអង្គជាអ្នកធ្វើឱ្យរបួស ។

បាបកម្មធ្ងន់ខ្លះអាចឱ្យផលភ្លាម ៗ, **ទុសី** ចោលដុំថ្មត្រូវសីសៈ (ក្បាល) របស់សាវ័កព្រះពុទ្ធព្រះនាមកស្សបៈ, **នន្ទយក្ស** បានវាយសីសៈព្រះសារីបុត្រ, ព្រះពោធិសត្វ កាលកើតជា ខន្តិវាទិតាបស ត្រូវ

ព្រះបាទ**កលាប៉ុ** ធ្វើឃាតនៅពេលដែលលោកកំពុងប្រតិបត្តិក្នុងឧទ្យាន ។ ទុសី, នន្ទយក្ស, ព្រះបាទកលាប៉ុ ត្រូវព្រះធរណីស្រូបទាំងរស់ ដោយសារបាបកម្ម ដែលអ្នកទាំងនោះបានសាងហើយធ្ងន់ពេកបានឱ្យផលក្នុងបច្ចុប្បន្ន ដោយពុំចាំបាច់ដល់ជាតិក្រោយឡើយ ។

បុគ្គលដែលជេរប្រមាថ ឬធ្វើឱ្យអាមាសមុខដល់មាតាបិតា ឬចាស់ព្រឹទ្ធាចារ្យ នឹងត្រូវទទួលទោសពីបាបកម្មរបស់ខ្លួន ត្រូវស្លាប់មុនកំណត់អាយុកាល ។ មរណកាលនេះ ហៅថាស្លាប់ដោយអកុសលកម្មចូលមកផ្តាច់ផ្តិល ឬអកុសលកម្មមរណៈ ។

## ករណីយដទៃផ្សេងៗ ទៀតនៃឧបច្ឆេទកកម្មមរណៈ

គ្រប់ពេលវេលាទាំងអស់ បុគ្គលគ្រប់រូបតែងតែស្ថិតនៅក្រោមកម្លាំងអកុសលកម្ម ដែលមានកម្លាំងខ្សោយផ្សេងៗ ទៀតដែលខ្លួនបានប្រព្រឹត្តពីអតីតជាតិផ្សេងៗ រៀងៗ ខ្លួនអកុសលកម្មនេះតែឯកឯងមិនអាចមានកម្លាំង រហូតដល់បណ្តាលឱ្យបុគ្គលម្នាក់ៗ ស្លាប់បានឡើយ ។ ប៉ុន្តែនៅពេលដែលបុគ្គលណាម្នាក់គ្មានបញ្ញា គ្មានការយល់ដឹង ពីការថែរក្សារូបកាយខ្លួនឯង មិនយកចិត្តទុកដាក់ពីសុខភាព និងការរស់នៅប្រចាំថ្ងៃរបស់ខ្លួន កម្លាំងនៃអកុសលកម្មរបស់បុគ្គលនោះ អាចឆ្លៀតឱកាសឱ្យផល ដោយនាំមកគ្រោះថ្នាក់ដល់បុគ្គលនោះ រហូតបណ្តាលឱ្យដល់ស្លាប់ក៏មាន ។

ការធ្វេសប្រហែសក្នុងការរស់នៅ ប្រចាំថ្ងៃរបស់បុគ្គលនោះនិងអាចជាហេតុឱ្យអកុសលកម្ម របស់បុគ្គលពីអតីតជាតិ តាមឱ្យផលក៏មាន ។

ប្រសិនបើកាលពីអតីតជាតិ បុគ្គលណាមួយបានប្រព្រឹត្តអំពើបាបកម្ម ដល់អ្នកដទៃដូចជា ៖ ធ្វើទារុណកម្ម ឬធ្វើទុក្ខបុកម្នេញគេដោយវាយដំ បង្អត់អាហារ ចាប់គេជ្រមុជក្នុងទឹក ដុតគេជាដើម... បុគ្គលដែលបានប្រព្រឹត្តបាបកម្មទាំងនោះ នឹងទទួលផលនៅបច្ចុប្បន្នជាតិនេះ ដោយមានជំងឺរ៉ាំរ៉ៃប្រចាំកាយ ដូចជាជំងឺហឺត ជំងឺឃ្លង់ ជំងឺខ្សោយអស់កម្លាំងជាដើម បុគ្គលនេះនឹងរងទុក្ខវេទនាអស់មួយជីវិតរបស់ខ្លួន ហើយនៅទីបំផុតត្រូវស្លាប់ដោយរោគរ៉ាំរ៉ៃនោះឯង ។

អ្នកប្រាជ្ញបណ្ឌិតចាស់បុរាណតែងពោលថា ៖ ជីវិតបានសុខសាន្តដោយសារការមើលឃើញគិតទុកជាមុន និងគួបរួមផ្សំជាមួយគតិបណ្ឌិត ។ គ្រោះថ្នាក់អាចកើតឡើងបានដោយសារគ្រាន់តែជំពប់ជើងដួលក៏មាន ឬត្រឹមតែលេបចូលមួយម៉ាត់ចំពោះអាហារមិនល្អ ។ ភាពភ្លីភ្លើល្ងង់ខ្លៅ ដោយដើរចូលទៅក្នុងរូងខ្លា ច្បាស់ជាទទួលគ្រោះថ្នាក់មិនខានឡើយ បើទោះណាអ្នកនោះមានសំណាងល្អយ៉ាងណាក៏ដោយ ក៏សំណាងនោះ ពុំអាចជួយឱ្យផុតពីគ្រោះថ្នាក់បានឡើយ ។ សូមកុំលោតចូលទៅក្នុងភ្នក់ភ្លើង ដោយទុកចិត្តថា លោកអ្នកជាអ្នកមានកុសលកម្មមួយនឹងជួយលោកអ្នកមិនឱ្យរលាកភ្លើងបាន។

សរុបសេចក្តីមក ក្នុងចំណោមមរណភាពទាំងបួនយ៉ាងដូចបានអធិប្បាយខាងលើ មរណភាពទី ៤ កើតមានភាគច្រើនក្នុងបច្ចុប្បន្នកាលយើងនេះ ដោយហេតុថា បុគ្គលជាច្រើនមិនសូវយកចិត្តទុកដាក់ពីការរស់នៅរបស់ខ្លួន ។ ប្រសិនបើជាអស់លោកអ្នកប្រាថ្នារស់នៅឱ្យបានដល់ផុតអាយុកាល ត្រូវតែរក្សាជីវិតរបស់អស់លោកអ្នកដោយមានការយកចិត្តទុកដាក់អំពីការថែទាំសុខភាពឱ្យបានជាប្រចាំ។

# សារៈសំខាន់នៅនាទីចុងក្រោយ

ប្រហែលកន្លះម៉ោងមុនពេលដាច់ខ្យល់ស្លាប់ បុគ្គលគ្រប់រូបត្រូវការកុសលជវនចិត្តមុនមរណៈភាពមកដល់ ប្រសិនបើបុគ្គលអាចរក្សាកុសលចិត្ត រហូតដល់ដង្ហើមចុងក្រោយរបស់ខ្លួនបាន បុគ្គលនោះនឹងចាប់បដិសន្ធិក្នុងសុគតិភព ។

ប៉ុន្តែបើបុគ្គលនោះប្រកបដោយអកុសលជវនចិត្ត បុគ្គលនោះនឹងចាប់បដិសន្ធិក្នុងអបាយភូមិ ក្នុងទុគ្គតិភព ។ គេអាចប្រៀបធៀបបាននឹងការប្រណាំងសេះ គឺនៅជុំចុងក្រោយដែលសំខាន់ជាងគេសម្រាប់ការប្រណាំង ។ ការមានសតិនៅពេលចុងក្រោយ មុនចូលមរណភាព ជាការមានសារៈសំខាន់ជាងគេបង្អស់សម្រាប់បុគ្គលនីមួយៗ ការទទួលការកើតទៅរកល្អឬអាក្រក់របស់ចិត្តយើងម្នាក់ៗទៅតាមវត្ថុរបស់ចិត្តហៅថា អារម្មណ៍ ។

## អារម្មណ៍បីយ៉ាង

មុននឹងដាច់ខ្យល់ស្លាប់ បុគ្គលម្នាក់ៗ នឹងឃើញនៅក្នុងចិត្តគឺវត្ថុណាមួយក្នុងចំណោមវត្ថុទាំងបីហៅថា ៖

**១. កម្ម ;**

**២. កម្មនិមិត្ត ;**

**៣. គតិនិមិត្ត ។**

**១. កម្ម :** ក្នុងទីនេះកម្មមានន័យថា ការគិតទៅដល់អំពើល្អ ឬអាក្រក់ដែលបុគ្គលបានធ្វើកន្លងមកហើយ ។

**២. កម្មនិមិត្ត :** បង្ហាញឱ្យឃើញនូវឧបករណ៍ ដែលប្រើប្រាស់ក្នុងការធ្វើអំពើល្អ ឬអំពើបាបមនុស្សនោះៗ ។

**៣. គតិនិមិត្ត :** គឺការឃើញនៅភព ដែលបុគ្គលត្រូវទៅចាប់បដិសន្ធិ ឬចាប់កំណើត ។

## តើកម្មនិមិត្តកើតយ៉ាងដូចម្ដេច?

បុគ្គលដែលបានសម្លាប់គេ នឹងឃើញអាវុធដែលខ្លួនបានប្រើប្រាស់ ដូចជាដាវ កាំបិត ព្រួញ ដំបង ...។ល។ អ្នករកស៊ីសម្លាប់សត្វនិយាយថា ឃើញរូបឆ្អឹងគោ ត្រង់ត្រគាកយ៉ាងធំ ។ អ្នកដែលបានប្រព្រឹត្តទុច្ចរិត ដូចជាលួចប្លន់ ក្បត់ប្ដីប្រពន្ធជាដើម នឹងឃើញរូបភាពនៃការដែលខ្លួនបានប្រព្រឹត្ត អំពើអកុសលទាំងនោះ ។

អ្នកដែលបានប្រព្រឹត្តអំពើជាកុសល ដូចជាបានកសាងវត្ត ឬព្រះវិហារ មុននឹងដាច់ខ្យល់ស្លាប់ នឹងឃើញរូបព្រះវិហារនិងវត្ត ឬនឹងឃើញរបស់ដែលគេបានបរិច្ចាគ ក្នុងការឧបត្ថម្ភ ឬបូជា ដូចជាស្បង់ចីពរ បាត្រ ទៀនធូប ផ្កាជាដើម ។

អ្នកដែលរក្សាសីល ឬប្រតិបត្តិសមាធិ វិបស្សនា នឹងឃើញគ្រាប់អង្កាំ សម្លៀកបំពាក់ស្អាត កន្លែងសមាធិ ឬវិបស្សនាជាដើម ។

## តើអារម្មណ៍នៃគតិនិមិត្តធ្វើឱ្យឃើញដូចម្ដេច?

នៅពេលមរណភាពនឹងជិតមកដល់ មានសញ្ញាឱ្យដល់ដឹងជាមុន ដែលបង្ហាញពិភព ដែលបុគ្គលនឹងទៅចាប់បដិសន្ធិ ។ ចំពោះបុគ្គលដែលនឹងទៅចាប់បដិសន្ធិ ក្នុងស្ថានសួគ៌នឹងឃើញទេវតាប្រាសាទ សួនច្បារ នៅស្ថានសួគ៌ជាដើម ។ អ្នកដែលទៅចាប់បដិសន្ធិក្នុងស្ថាននរក នៅពេលនោះនឹងឃើញឆ្កែខ្មៅ ភ្លើងក្នុងស្ថាននរក និងពួកនរកជាដើម ។ អ្នកដែលទៅចាប់បដិសន្ធិជាប្រេត ខ្មោចបិសាចដែលអត់ឃ្លាន នឹងឃើញព្រៃធំ ឬភ្នំនិងជ្រលងជ្រោះ ដែលជាកន្លែងពពួកប្រេតរស់នៅ ។

## តើត្រូវធ្វើដូចម្តេច ដើម្បីឱ្យអារម្មណ៍កើតឡើង?

ចំពោះបុគ្គលដែលមានសុខភាព ចុះអន់ថយបន្តិចម្តងៗ យើងដឹងថានឹងទទួលមរណភាពតាមកម្មរបស់ខ្លួន អាចារ្យ មិត្តភក្តិ ឬញាតិមិត្ត អាចជួយឱ្យបុគ្គលដែលនឹងចូលមរណភាពនោះ ឃើញអារម្មណ៍ល្អបាន នៅពេលដែលដឹងពិតប្រាកដថា អ្នកជំងឺពុំអាចជាសះស្បើយបាន ហើយនិងចូលមរណកាលនៅពេលដ៏ខ្លីខាងមុខ ត្រូវសម្អាតទីកន្លែងដែលបុគ្គលនោះស្នាក់នៅ ឱ្យបានស្អាតជាទីបំផុត ហើយរកផ្កាស្រស់ៗ មកតាំងបូជាថ្វាយព្រះ ពេញមួយយប់ទល់ភ្លឺ បន្ទប់ដែលបុគ្គលស្នាក់នៅត្រូវបំភ្លឺឱ្យមានពន្លឺភ្លឺច្បាស់ ។ គេត្រូវប្រាប់បុគ្គលដែលត្រូវចូលមរណកាលនោះ ឱ្យមើលតែទៅភ្លើងទៀន និងផ្កាដែលយើងបានបូជាថ្វាយព្រះជំនួស និងសូមឱ្យបុគ្គលនោះតាំងចិត្ត សប្បាយនឹងអំពើជាកុសល (បុណ្យ) ដែលបុគ្គលនោះបានធ្វើហើយ ត្រូវសូត្របរិត្តសាស្ត្រា នៅពេលដែលអាចដឹងថាបុគ្គលនោះ នៅមានវិញ្ញាណអាច

ស្ដាប់បាន ។

ចំពោះបុគ្គលដែលនឹងចូលមរណភាព ត្រូវតែមានការតាំងចិត្ត ជាប់ជាមួយអំពើជាកុសល ដែលបានធ្វើចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រមទាំងស្ដាប់ព្រះធម៌ និងស្រូបនៅក្លិនផ្កាក្រអូបស្រស់ៗ ជាច្រើនថ្ងៃមុនចូលមរណភាព ។ អាចារ្យ មិត្តភក្តិ ញាតិ ត្រូវជួយបុគ្គលដែលនឹងចូលមរណភាព ឱ្យឃើញអារម្មណ៍ល្អនៅពេលដែលបុគ្គលនោះ នៅមានស្មារតីអាចទទួលអារម្មណ៍បាន ។

## អតីត អនាគត បច្ចុប្បន្ន

(បទពាក្យប្រាំបី)

អតីតកន្លងទុកដូចយល់សប្តិ ពុំអាចត្រឡប់ដូចដើមវិញបាន
អនាគតខាងមុខទុកដូចការស្មាន អ្វីដៅឃើញបានជាបច្ចុប្បន្ន ។
មាគ៌ាជីវិតគិតទុកឱ្យហើយ កុំប្រមាទឡើយនាំគ្រោះអាសន្ន
កាលកន្លងទៅឥតនៅបង្អង់ កុំឱ្យស្រោកស្រេន់សាងបុណ្យកុសល ៕

ដោយឧបាសក **ម៉ិញ សាវ៉ាន**



# ទស្សនៈដែលត្រឹមត្រូវ

កត្តាចម្បងដែលនាំឱ្យរូបនិងនាម មានជាតិកំណើតជាថ្មី គឺ អវិជ្ជា តណ្ហា កម្ម ។ ការដែលយល់ថារូប និងនាមអាចផ្លាស់ប្តូរជីវិតមួយ ទៅជីវិតមួយទៀតនោះ រួចហើយនាមនិងរូបនោះក៏រលត់ទៅវិញ ដោយឯកឯងក្នុងរយៈពេលដ៏ខ្លី និងការដែលយល់ថាមានព្រលឹង ឬ អាត្ម័ននោះជាការយល់ខុស ការយល់ត្រូវនោះការកកើតឡើងនៃនាម និងរូប គឺជាផលរបស់អវិជ្ជា តណ្ហា កម្ម ពីជាតិមុន ។ ដូចជាគេអុជទៀនមួយដើម ហើយយកទៀនទីពីរមកអុជបន្ត ភ្លើងរបស់ទៀនទីពីរ ពុំមែនជាភ្លើងរបស់ទៀនទីមួយនោះទេ ប៉ុន្តែភ្លើងទៀនទីពីរ មានទំនាក់ទំនងជាមួយគ្នានឹងភ្លើងទៀនទីមួយ ។ បើនិយាយថាភ្លើងទៀនទីពីរពុំមែនទំនាក់ទំនងនិងភ្លើងទៀនទីមួយក៏ពុំមែនដែរ ។ សូមចាំឱ្យច្បាស់ថា ជីវិតក្នុងបច្ចុប្បន្នជាតិ ដែលមានរូបធាតុ និងនាមធាតុ អាចប្រព្រឹត្តទៅបានល្អ ក៏ដោយសារកម្មពីអតីតជាតិ ជាកុសលកម្មដែរ ដូចយើងបានសន្ទនាគ្នា អំពីកម្មផលរបស់កម្ម ពីខាងដើមខ្លះមកហើយដែរ ។

ការដែលយើងជួបប្រទះនូវបច្ចុប្បន្ននេះ កើតមានឡើងអំពីហេតុពីរយ៉ាងគឺ :

**១. កម្ម (អំពើ) ដែលបានធ្វើអំពីអតីតជាតិ រួមនឹង**

**២. ការចេះដឹង និងការព្យាយាមប្រឹងប្រែងរបស់បុគ្គលម្នាក់ៗ ក្នុងបច្ចុប្បន្នជាតិ ។**


ភ័យបីប្រការ
ដោយ
មិញ សាវ៉ាន
គេហដ្ឋាន អភិរក្សមរតកព្រះពុទ្ធសាសនាខ្មែរ
ក្រុងម៉ុងរអាល - កេប៊ិក - កាណាដា
ព.ស. ២៥៥៩ - គ.ស. ២០១៦

# មតិបញ្ចប់

សរុបសេចក្តីមក សេចក្តីស្លាប់ពុំមែនបានន័យថា គឺជាចុងបញ្ចប់សម្រាប់ជីវិតរបស់សត្វលោកទេ ផ្ទុយទៅវិញគឺជាការចាប់ផ្តើមនៃជីវិតថ្មីមួយទៀតរបស់សត្វលោកគ្រប់រូបៗ ។ គឺជាការមានសារៈសំខាន់ខុសគ្នាឆ្ងាយណាស់ រវាងការប្រសើរក្នុងការចាប់បដិសន្ធិ និងការប្រសើរក្នុងការស្លាប់ ការដែលឱ្យមានសតិនៅពេលស្លាប់ ពុំមែនជាការងាយស្រួលដូចដែលយើងម្នាក់ៗ គិតទេ ។

ទី ១. បុគ្គលត្រូវស្លាប់ដោយមានការឈឺចុកចាប់ យ៉ាងតិចតួចបំផុត ឬដែលមានជំងឺដែលស្រាលៗ ;

ទី ២. ត្រូវឱ្យមានញាតិមិត្តបងប្អូន ដែលល្អនៅក្បែរគ្រែអ្នកស្លាប់ ជាការបានផលប្រសើរទៀតនោះ បុគ្គលខ្លួនឯងត្រូវរៀបចំជាមុន ដោយមិនរង់ចាំដល់នាទីចុងក្រោយឡើយ ។

ដូច្នេះបុគ្គលម្នាក់ៗ ត្រូវតែរស់នៅ ប្រកបដោយសីលធម៌ល្អ ហើយត្រូវរៀនរលឹកដល់សេចក្តីស្លាប់ដែលមានចំពោះជីវិត ទាំងចេះដាក់ចិត្តដាក់កាយ ទទួលយល់យកតាមសេចក្តីពិត និងព្រមរៀបចំជីវិតសម្រាប់ថ្ងៃមរណភាពរបស់ខ្លួន ដើម្បីបានបដិសន្ធិថ្មី (កំណើតថ្មីល្អគ្រប់ៗ ជាតិ) គឺសុគតិភព ។ ការអន្ទោលក្នុងសង្សារវដ្ត ដែលជាផ្លូវឆ្ងាយម្នាក់ឯង ទោះបីជាយើងមានឈ្មោះថា ជាអ្នកស្ថិតនៅលើផ្លូវត្រូវត្រាច់ចរ ក៏យើងត្រូវមានស្មារតីជានិច្ច មិនភ្លាំងភ្លេចក្នុងការសន្សំស្បៀង ទុកល្មមក្នុងការបំពេញតម្រូវការ ដែលបានចែងទុកនៅក្នុង

ព្រះពុទ្ធសាសនា និងជាព្រះពុទ្ធដីកាដែលបានសម្តែងបង្ហាញសត្វលោក ដោយព្រះទ័យប្រកបដោយ ព្រះមហាករុណាទិគុណ អំពីគោលដៅរបស់ជីវិតនេះ និងជាចុងបញ្ចប់នៃវដ្ដ: គឺព្រះនិព្វានជាបរិយោសាន ។

**ការយល់ដឹងអំពីការកើតនិងការស្លាប់នេះ...**

ជាអត្ថបទបានបកប្រែចេញពីសៀវភៅ ផ្សាយនៅតាមវិប-សាយ ព្រមទាំងបានកែសម្រួល ដោយព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណា** ព្រះគ្រូចៅអធិការវត្តខ្មែរកាណាដា ទីក្រុងម៉ុងរេអាល ខេត្តកេបិក ប្រទេសកាណាដា និងមានការឧបត្ថម្ភ ដោយចិត្តប្រកបដោយសទ្ធាជ្រះថ្លារបស់ ៖ ឧបាសិកា តែ ធឹងលាភ, ឧបាសិកា តែ ចិន្តា, ឧបាសក តែ គឹមហុក, ឧបាសក លឹម កុក និងឧបាសិកា យ៉ុង ឡៀង ។

បានបោះពុម្ពផ្សាយចែកជូនជាធម្មទាន មានសន្លឹកក្រដាសត្រឹមតែបីសន្លឹកប៉ុណ្ណោះ ។ ខ្ញុំព្រះករុណា ខ្ញុំបាទ បានទទួលយកមកអាន, អានហើយអានទៀត ឃើញថាមានន័យខ្លឹមសារល្អ សម្រាប់ការពិចារណា សិក្សារៀនអាន ឱ្យបានជាទម្លាប់របស់ចិត្ត និងការដឹងយល់មុនចុងបញ្ចប់ក្នុងដំណើរជីវិតនេះ ។

ខ្ញុំព្រះករុណា ខ្ញុំបាទ បានរក្សាអត្ថបទនេះទុក ប្រហែលជាជាង ១០ ឆ្នាំមកហើយ ដោយបានតាំងចិត្តថា ក្នុងពេលណាមួយ ខ្ញុំព្រះករុណា ខ្ញុំបាទនឹងបានចម្លងបញ្ចូលអត្ថបទនេះរួមចូលជាមួយសំណេរជាអត្ថបទរបស់ខ្ញុំ បង្កើតបានជាសៀវភៅមួយច្បាប់ រក្សាទុកបានយឺន

យូរ ព្រោះប្រសិនបើមានត្រឹមតែក្រដាសបីសន្លឹកប៉ុណ្ណោះ លោកអ្នកអានហើយច្រើនតែបោះបង់ចោល ដោយពុំបានយល់ដឹង នឹងឱ្យតម្លៃដល់គុណប្រយោជន៍នៃព្រះធម៌ប៉ុន្មានសន្លឹកនោះទេ ។

ជាបរិយោសាននៃកថានេះ ខ្ញុំព្រះករុណា ខ្ញុំបាទ យើងខ្ញុំទាំងអស់គ្នា សូមលើកយកផលានិសង្ស ដែលកើតចេញបានពីការព្យាយាម រចនាឱ្យបានកើតជាសៀវភៅនេះឡើង, សូមព្រះករុណា ព្រះគុណម្ចាស់ លោកអ្នកអានទាំងឡាយ ព្រមទាំងសព្វសត្វក្នុងសង្សារវដ្តនេះ បានប្រកបដោយសេចក្តីសុខក្សេម បរិបូណ៌ដោយប្រាជ្ញាស្មារតី មានជោគជ័យសម្រេចគ្រប់ភារកិច្ច ក្នុងដំណើរជីវិតនេះទាំងក្នុងបច្ចុប្បន្ន បរលោក រហូតដល់ទីបំផុតនៃជាតិ កុំបីឃ្លៀងឃ្លាតជាបការៈដទៃឡើយ ។

សូមអនុមោទនា! សូមអនុមោទនា! សូមអនុមោទនា!

សរសេរចប់ ថ្ងៃសុក្រ ១ រោច ខែពិសាខ ឆ្នាំថោះបញ្ចស័ក
ព.ស. ២៥៦៧ត្រូវនឹងថ្ងៃទី ៥ ខែឧសភា គ.ស. ២០២៣




ត្រូវតែណោះដីខ្មែរ

សួនកំណាព្យ  កម្រងប្រវត្តិសាស្ត្រ

ដោយ **ទាន សាវ៉ាន**

កែសម្រួល ដោយ **សឹម សារឿន**

រៀបរៀង ជាសៀវភៅ

ដោយ **ចាន់ ដារី**

**ម៉ុងរេអាល់ កាណាដា**

គ,ស, ២០០៣  ព,ស, ២៥៤៧

# សមាសភាពចូលរួម

០១- ព្រះគ្រូ **ធឹង ធីម ចន្ទត្ថេរ** ព្រះចៅអធិការវត្ត **ធម្មិការាម**

០២- ព្រះគ្រូ **ស៊ុម ប៊ុនធឿម សុវណ្ណត្ថេរោ** ព្រះចៅអធិការវត្ត **ពុទ្ធសុទ្ធារាម**

០៣- ព្រះភិក្ខុ **តិក្ខវីរិយោ ឃឿន សំណាង** វត្ត**ខ្មែរកោណាដា**

០៤- ព្រះភិក្ខុ **ឥន្ទញ្ញាណោ ហ៊ីម គិមសត់** វត្ត**នន្ទសិរិគន្ធារាម** បន្ទាយមានជ័យ

០៥- ព្រះភិក្ខុ **សរ ស៊ុនថិត្យ** ពុទ្ធញ្ញាណោ **វត្តធម្មិការាម**

០៦- ឧបាសក **ហ៊ុម ឆាន់**

០៧- ឧបាសក **វ៉ាត តិរក្ស**

០៨- កញ្ញា **ហួរ ស៊ុនហ៊ាប**

០៩- កញ្ញា **វ៉ាត វារីយ៉ា**





# នានាជីវិត

## កម្រងកំណាព្យ

រៀបរៀងដោយ :

ខ្ញុំព្រះករុណា ខ្ញុំបាទ

# ម៉ិញ សាវ៉ាន

ព.ស. ២៥៤៩ គ.ស. ២០០៥

# ឯកសារពិគ្រោះ

- បិតកលេខ ៥៦ ទំព័រ ១៧៨
- បិតកលេខ ៥៤ ទំព័រ ២២២
- បិតកលេខ ៦២ ទំព័រ ១៧
- បិតកលេខ ៦៨ ទំព័រ ១៥
- បិតកលេខ ៤១ ទំព័រ ៤៥៤
- វចនានុក្រមខ្មែរ ព្រះសុមេធាធិបតី ជួន ណាត ជោតញ្ញាណោ
- អត្ថបទផ្សាយចេញពីវត្ត ខ្មែរកាណាដា ព្រះតេជព្រះគុណ បណ្ឌិត **ហុក សាវណ្ណា**

## បណ្ដាំពូជ

(បទពាក្យប្រាំពីរ)

**កុំ**ដាំពូជស្មៅប្រាថ្នាបានស្រូវ **កុំ**ដាំពូជខ្មៅប្រាថ្នាផលស
**កុំ**ដាំអាក្រក់ប្រាថ្នាផលល្អ **កុំ**ដាំពូជក្រប្រាថ្នាចង់មាន ។
**កុំ**ដាំពូជល្ងង់ប្រាថ្នាចង់ចេះ **កុំ**ធ្វេសប្រហែសនាំឱ្យភ្លេចប្រាណ
**កុំ**ចង់តែបានបាត់ក្ដីខ្មាសអៀន **កុំ**ខ្ជិលមិនរៀនឥតមានវិជ្ជា ៕

# មាគ៌ាជីវិត ស៊ូ!ស៊ូ!

(បទពាក្យប្រាំពីរ)

ទោះបីដួលដេកលើផែនដី ត្រូវតែឃ្មាតខ្មីក្រោកវិញណា៎
ឈានជើងទៅមុខគ្រប់វេលា ត្រេចតាមមាគ៌ាអង្គប្រាំបី ។
ចេញចាកពីទ្រុងនៃវដ្ដៈ កាត់ស្រាយអន្ទាក់មារប្រល័យ
ចំណងរួបរឹតក្នុងភពបី មច្ចុរាជយប់ថ្ងៃតាមប្រហារ ។
រត់ចេញពីគុកឥតជញ្ជាំង មោហ៏អវិជ្ជាបាំងឱ្យអន្ធការ
ឆ្ពោះព្រះនិព្វានបានសុខា នេះជាមាគ៌ានៃជីវិត ៕

# រៀនធម៌កំដរចិត្ត

(បទពាក្យប្រាំបី)

រៀនធម៌កំដរចិត្តពិតប្រពៃ សាងបុណ្យយប់ថ្ងៃកំដរជីវិត
ធ្វើការងារល្អកំដរកាយពិត ជៀសចាកផឹកពិតឃើញពន្លឺ ។
បរិភោគអាហារបំបាត់ការឃ្លាន មានថ្នាំទុកបានបំបាត់រោគឈឺ
ត្រចៀកនៅល្អភ្នែកក៏នៅភ្លឺ ព្យាយាមមើលឮអ្វីដែលជាគុណ ៕



សូមពុទ្ធបរិស័ទដែលមានសទ្ធាជ្រះថ្លា ចូលរួមក្នុងការបោះពុម្ពនៃសៀវភៅ « មាគ៌ាជីវិត » និងទ្រទ្រង់ « គេហដ្ឋាន អភិរក្សមរតកព្រះពុទ្ធសាសនា » យើងខ្ញុំនេះ បានប្រកបតែនឹងសិរីសួស្តី ជោគជតារាសីជ័យមង្គលវិបុលសុខ និងបានប្រកបតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមសព្វសត្តនិករ អនុមោទនាត្រេកអរ ទទួលយក នូវចំណែកបុណ្យកុសលដែលយើងខ្ញុំបានសាងសន្សំ ទទួលយកនូវចំណែកសន្តិភាពក្នុងចិត្តរបស់យើងខ្ញុំ ទទួលយកនូវចំណែកនៃព្រះធម៌របស់យើងខ្ញុំ ។

សូមសព្វសត្តនិករ បានរួចរំដោះចាកផុតទុក្ខទាំងពួង ។

សូមអនុមោទនា !

សូមអនុមោទនាបុណ្យ !

សូមអនុមោទនាធម្មទាន !

# សន្តិភាព

(បទពាក្យប្រាំបួន)

សន្តិភាព ចូលជ្រួតជ្រាប គ្រប់វេលា
ក្នុងចិន្តា ជាតិខេមរា ទាំងប្រុសស្រី
មានករុណា ចងបាច់គ្នា ទោះយប់ថ្ងៃ
ក្នុងស្មារតី ការពារជាតិ មាតុភូមិ ។
ចេះបែងចែក រំលែកផល ឱ្យដល់គ្នា
ដោយមេត្តា ចិន្តាគិត ប្រយោជន៍រួម
រស់ក្នុងនាម មានគំនិត ចិត្តចេះល្មម
ជ័យសុខព្រម កើតមានរួម គ្រប់អង្គា ។
សូមសព្វសត្វ ផុតវិបត្តិ ក្នុងលោកា
បានសុខា ចិន្តាស្ងប់ បញ្ចប់ពៀរ
ចិត្តឥច្ឆា ការនិន្ទា ឈ្មានីសគ្នា
ដោយធម្មា ជាឱសថ ផុតព្រួយភ័យ ៕

ដោយឧបាសក **ម៉ិញ សាវ៉ាន**

# នាមសប្បុរសជន

ចូលរួមបោះពុម្ពសៀវភៅ «**មាគ៌ាជីវិត**» ជាធម្មទាន

. ព្រះភិក្ខុ **ធឹង ធីម** ( **ចន្ទត្ថេរ** ) ........................................ ៧៥០ ដុល្លារ

. ព្រះភិក្ខុ **សរ ស៊ុនធិត្យ** ........................................................ ២០០ ដុល្លារ

. ព្រះគ្រូសត្ថាមុនី **ស៊ុម បញ្ញា** (Rhode Island)........................... ១០០ ដុល្លារ

. ព្រះមហា **ឃឿន សំណាង** .................................................. ៥០ ដុល្លារ

. ព្រះភិក្ខុ **ប៉ាវ សែន**............................................................. ១៦០ ដុល្លារ

. ឧបាសក **ម៉ិញ សាវ៉ាន** និងឧបាសិកា **សិម ចាន់ធូរ៉ា**............ ១២០០ ដុល្លារ

. ឧបាសក **ស្រី សារិន** និងឧបាសិកា **ភូ អេងលី** ........................ ៤៥០ ដុល្លារ

. ឧបាសក **ឡេង ឡូច** និងឧបាសិកា **ហោ ហ៊ីន** ......................... ៤០០ ដុល្លារ

. អ្នកស្រី **គង់ សំបាន** ( **សារិន** )............................................. ៣៤០ ដុល្លារ

. ឧបាសិកា **សយ គុំ** និងឧបាសក **យុត រៀង** ............................ ៣២០ ដុល្លារ

. ឧបាសក **ថុង ហេងប៉េង** និងឧបាសិកា **យ៉ិក ហួផន** ............. ៣២០ ដុល្លារ

. លោក **ម៉ា គិមសេង** ព្រមទាំងកូនចៅ ................................... ៣០០ ដុល្លារ

. លោក **សិម រតនា** និងអ្នកស្រី Véronique ............................. ៣០០ ដុល្លារ

. លោក **ស៊ុយ សុជាតិ** និងអ្នកស្រី **ប៉ូច សេងហ៊ន** .................. ៣០០ ដុល្លារ

(ឧទ្ទិសកុសលជូន យុវនារី **ស៊ុយ សុនិភា** និងកុមារា **ស៊ុយ មុនីវណ្ណា**)

. ឧបាសិកា **ឆាង រ៉ែម** និងឧបាសិកា **ហ៊ុន ហឿប**........................ ២៩០ ដុល្លារ

. ឧបាសក **នុន ស៊ែប** និងឧបាសិកា **នុន ណាន់ថា** .................... ២៩០ ដុល្លារ

. អ្នកស្រី **ម៉ែន សារឿន**( ឧ.ឡេង អម/ឧ.អ៊ា នៅ )............... ២៥០ ដុល្លារ

. លោក **មាឃ ចន្ទកញ្ញា** និងអ្នកស្រី **មាឃ អេឡេន**.......... ២៣០ ដុល្លារ

. ឧបាសក **វ៉ាត តិរក្ស** និងឧបាសិកា **មៀច វណ្ណា**.................. ២០០ ដុល្លារ

. លោក **ស៊ូ សុគន្ធនវ៉ា** និងអ្នកស្រី **អ៊ុន វិសាល** .................... ២០០ ដុល្លារ

. ឧបាសិកា **គឹង ឡេងឈី** និងកូនចៅ..................................... ២០០ ដុល្លារ

. លោក **គោគ ហុងសៃ** និងអ្នកស្រី **ហេង ហ្គេចអេង** .......... ២០០ ដុល្លារ

. ឧបាសក **កែ ម៉ុនហាន** និងឧបាសិកា **លី ឆេងលន់** ................ ២០០ ដុល្លារ

. លោក **ឃុយ រស្មី** និងក្រុមគ្រួសារ ......................................... ១៧០ ដុល្លារ

. អ្នកស្រី **ឱក សុធៈនុ** និងក្រុមគ្រួសារ .................................... ១៥០ ដុល្លារ

. ឧបាសិកា **ហោ ឈាងហេន** និងឧបាសិកា **ឱត្យ សុភី** និងបងប្អូនកូនចៅ

(ឧទ្ទិសកុសលជូន ព្រឹទ្ធាចារ្យ **ឱត្យ សំបូរ**) ................................ ១៥០ ដុល្លារ

. ឧបាសិកា **លី សុភី** និងកូនចៅ .................................................. ១៥០ ដុល្លារ

. ឧបាសិកា **សក់ សាន់នី**........................................................ ១១០ ដុល្លារ

. លោក **យី សំអាត** និងអ្នកស្រី **អ៊ុន យូអេង** ........................ ១០៥ ដុល្លារ

. ឧបាសក **ហ៊ិម ឆាន់** និងឧបាសិកា **សាមិត សូភ័ណ** .............. ១០០ ដុល្លារ

. លោក **បេ ប៉េងទ្រី** និងអ្នកស្រី **អ៊ុន យូអូន**.......................... ១០០ ដុល្លារ

. លោក **តៃ ប៉េងឈុន** និងអ្នកស្រី **ឃួន សំណាង**.................... ១០០ ដុល្លារ

. ឧបាសក **ចុង សំបូណ៌** និងឧបាសិកា **ចៅ គឿក** .................... ១០០ ដុល្លារ

. ឧបាសិកា **គី ស៊ានហុង** ព្រមទាំង កូន ចៅ .............................. ១០០ ដុល្លារ

. អ្នកស្រី **វ៉ន ឡុន** និងក្រុមគ្រួសារ.......................................... ១០០ ដុល្លារ

. អ្នកស្រី **មាស មារិន** ........................................................... ១០០ ដុល្លារ

. អ្នកស្រី **ឯក សុវណ្ណា** ......................................................... ១០០ ដុល្លារ

. អ្នកស្រី **លយ លក្ខិណា** និងលោក **មាស សេងនាង**............ ១០០ ដុល្លារ

. លោក **តៃ ហួត** និងគ្រួសារ ........................................ ១០០ ដុល្លារ
. ឧបាសក **អ៊ុំ ហ៊ាន** និងឧបាសិកា **ព្រហ្ម សែម** ........................ ១០០ ដុល្លារ
. ឧបាសក **កែវ សំ** និងឧបាសិកា **អូ វឿយ** ................................ ១០០ ដុល្លារ
. ឧបាសិកា **ស៊ីវ គីមសឺន** .................................................... ១០០ ដុល្លារ
. ឧបាសិកា **គុយ គី** ព្រមទាំងកូន ចៅ ........................................ ១០០ ដុល្លារ
. លោក **លឹង ឆៀបថុល** ហៅ **គុណា** និងក្រុមគ្រួសារ................ ១០០ ដុល្លារ
. ឧបាសក **ប៉ែន សារឿន** និងឧបាសិកា **ឡាំ ឈួម** .................... ១០០ ដុល្លារ
. ឧបាសិកា **លីម ហៃស៊ីម** ..................................................... ១០០ ដុល្លារ
. ឧបាសិកា **សិម សុខាម៉ា** ព្រមទាំងកូន ចៅ................................. ១០០ ដុល្លារ
. លោក **សិម សុមេរ៉ា** និងអ្នកស្រី **ជា ពិសី**............................ ១០០ ដុល្លារ
. ឧបាសិកា **ហ៊ុន ហៀង** ព្រមទាំងកូន ចៅ...................................... ៧០ ដុល្លារ
. ឧបាសក **អ៊ឹម កុសល** និងឧបាសិកា **តែ ធីងលាប**................. ៧០ ដុល្លារ
. លោក **យុន សាធុច** ........................................................ ៦០ ដុល្លារ
. ឧបាសក **តាន់ សុងហេង** និងឧបាសិកា **ឡោ សែនសុខន** ... ៥៥ ដុល្លារ
. លោក **ឈីវ ប៊ុនអ៊ី** និងអ្នកស្រី **លឹង គីមស៊ន**.................... ៥០ ដុល្លារ
. ឧបាសក **ឈឿក ឈុំ** ......................................................... ៥០ ដុល្លារ
. ឧបាសិកា **ឌៀប សុឡាវី** និងក្រុមគ្រួសារ ............................. ៥០ ដុល្លារ
. លោក **អ៊ុំង ជីឌី** និងអ្នកស្រី**ចូវ លីន**.................................. ៥០ ដុល្លារ
. ឧបាសិកា **ហេង គីម ទី**...................................................... ៥០ ដុល្លារ
. ឧបាសិកា **គីម សឿន**......................................................... ៥០ ដុល្លារ
. ឧបាសិកា **តាន់ ស៊ីវ ឡេង** ................................................ ៥០ ដុល្លារ
. ឧបាសិកា **យឹម ផាហៀក** ..................................................... ៥០ ដុល្លារ
. លោក **លី គឹម ហ៊ុយ** និងអ្នកស្រី **លី ស៊ីវហុង** ................... ៥០ ដុល្លារ
. អ្នកស្រី **តាន់ ចាន់ថា**.......................................................... ៥០ ដុល្លារ

. ឧបាសក **អ៊ុន សឿន** និងឧបាសិកា **អ៊ុន យូសេខ** កូនចៅ ........ ៥០ ដុល្លារ
. ឧបាសក **ស៊ីវ ហេខលី** និងឧបាសិកា **ជួន ចាន់ថុល** ............ ៥០ ដុល្លារ
. លោក **លឹម អាំងគី** និងអ្នកស្រី **សារឿន( ស )** .................... ៥០ ដុល្លារ
. ឧបាសិកា **នូ លឹម** និងកូនចៅ ................................................ ៥០ ដុល្លារ
. ឧបាសិកា **ហាង្ស វណ្ណារី** និងកូនចៅ ...................................... ៥០ ដុល្លារ
. កញ្ញ **វ៉ាត ថារីយ៉ា** .......................................................... ៥០ ដុល្លារ
. ឧបាសិកា **ហួត សៀក** ....................................................... ៥០ ដុល្លារ
. ឧបាសក **ចាន់ អឿន** និងឧបាសិកា **សឿ សុខុម**..................... ៤០ ដុល្លារ
. លោក **ទេព សំអាន** និងអ្នកស្រី **តិន សុខានី( ឌី )** ............... ៤០ ដុល្លារ
. ឧបាសិកា **ជឹង គីមសៀង** .................................................. ៤០ ដុល្លារ
. លោក **ទេព សំអាន** និងអ្នកស្រី **តិន សុខានី( ឌី )** ............... ៤០ ដុល្លារ
. ឧបាសិកា **សុន សារិន** ..................................................... ៣០ ដុល្លារ
. ឧបាសិកា **អូ វឿយ** និងកូនចៅ............................................ ៣០ ដុល្លារ
. ឧបាសិកា **អ៊ុក ស៊ីម** ....................................................... ៣០ ដុល្លារ
. ឧបាសក **ព្រហ្ម គិមស៊ាន**.................................................... ៣០ ដុល្លារ
. លោក **ចូវ ខាន់ឌួយ** និងគ្រួសារ ......................................... ៣០ ដុល្លារ
. ឧបាសក **អ៊ូ សុផុន** និងក្រុមគ្រួសារ........................................ ៣០ ដុល្លារ
. កុមារា **យី ចេស្តា** Carmelo Wong ..................................... ២៥ ដុល្លារ
. លោក **ប៊ុន ប៊ូកា៉រ៉ា** និងអ្នកស្រី **មាស នរ៉ា**........................... ២០ ដុល្លារ
. ឧបាសិកា **ហួន សម្បត្តិ**...................................................... ២០ ដុល្លារ
. ឧបាសិកា **ជួប ស៊ីមន** ...................................................... ២០ ដុល្លារ
. ឧបាសិកា **អ៊ុំ កន្និដ្ឋា** ...................................................... ២០ ដុល្លារ
. ឧបាសក **អ៊ុម អ៊ន** .......................................................... ២០ ដុល្លារ

| | |
|---|---|
| . ឧបាសក **សេក សារុន** | ២០ ដុល្លារ |
| . ឧបាសិកា **គង់ រំផា** | ២០ ដុល្លារ |
| . អ្នកស្រី **យ៉ុង កែវ វ៉ាន់រិទ្ធ** | ២០ ដុល្លារ |
| . ឧបាសិកា **គិម មួយហៀង** | ២០ ដុល្លារ |
| . ឧបាសិកា **ស្រុន ចេង** | ២០ ដុល្លារ |
| . ឧបាសិកា **សិម ចាន់នី** | ២០ ដុល្លារ |
| . អ្នកស្រី **មាន សុគន្ធណាលី** | ២០ ដុល្លារ |
| . អ្នកស្រី **ទេព វណ្ណា** | ២០ ដុល្លារ |
| . អ្នកស្រី **ផូ សុតី** | ២០ ដុល្លារ |
| . អ្នកស្រី **ឡឹក រតនា** | ២០ ដុល្លារ |
| . អ្នកស្រី **ហេង ហ្គេចអេង** | ២០ ដុល្លារ |
| . ឧបាសក **គឹក ប៊ុនប៉ុង** និងឧបាសិកា **អ៊ុយ សាម៉ាលី** | ២០ ដុល្លារ |
| . ឧបាសិកា **អ៊ុក ស៊ីម** | ២០ ដុល្លារ |
| . លោក **ឡុក ហួត** និងអ្នកស្រី **តាត សៀកលីវ** | ២០ ដុល្លារ |
| . ក្រុមកុមារា កុមារី ចៅៗ ឧបាសក **អ៊ុំ ហ៊ាន** | ២០ ដុល្លារ |
| . លោកយាយ **ស** | ២០ ដុល្លារ |
| . អ្នកស្រី **ផាន សាវុទ្ធ** | ១០ ដុល្លារ |
| . ឧបាសក **ព្រហ្ម ឡុក** និងឧបាសិកា **ស៊ុយ ឡួយ** | ១០ ដុល្លារ |
| . លោក **យី សុខជុំ** និងអ្នកស្រី Cleara | ១០ ដុល្លារ |
| . លោក **យី សទ្ធា** និងអ្នស្រី Ivanka Andrea | ១០ ដុល្លារ |
| . ឧបាសិកា **សិម ចាន់ណារី** | ១០ ដុល្លារ |
| . លោកយាយ **យី** | ៥ ដុល្លារ |

| | |
|---|---|
| . អ្នកស្រី **ឱក កុលធីតា** និងស្វាមីព្រមទាំងបុត្រ (Australia) ....... | ៣០០ U.S |
| . លោក **ភឿក ភាថា** និងអ្នកស្រី **ភឿក ហ្វលី** (Virginia) .......... | ២០០ U.S |
| . លោក **រស់ សុខុម** (កម្ពុជា)................................................ | ១០០ U.S |
| . ឧបាសក **ថាំង សុខហេង** និងឧបាសិកា **ហោ ផល្លា** កូនចៅ ... | ១០០ U.S |
| . លោក **រស់ សុខុម** (កម្ពុជា)................................................ | ១០០ U.S |
| . លោក **អ៊ូន សុផា** (កម្ពុជា)................................................ | ៥០ U.S |
| . អ្នកស្រី **ម៉ូ សុផាណាវី** Jenny Woo (Florida) ....................... | ៤០ U.S |
| . អ្នកស្រី **កែម ណាវី** (កម្ពុជា) ............................................ | ២០ U.S |
| . ទាយិកា **ឈឿង សុធាវណ្ណ** (កម្ពុជា) ...................................... | ២០ U.S |
| . ទាយិកា **ហួរ ស៊ុនហ៊ាប** (កម្ពុជា) ......................................... | ៨០០០០ រ |
| . ទាយិកា **អេង សុគន្ធា** (កម្ពុជា) .......................................... | ១៥ U.S |
| . រោងពុម្ព **ណូវ៉ា ខេមបូឌា** (កម្ពុជា) ...................................... | ២០០ ក្បាល |

**NOVA (Cambodia) Co., Ltd.**

2F-09, Raintree, #299 Preah Ang Duong,

Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia

Tel. +855 (0) 23 223 577 I info@novacambodia.com"

**គេហដ្ឋាន**

**អភិរក្សមរតកព្រះពុទ្ធសាសនាខ្មែរ**

ក្រុងម៉ុងរេអាល - កេបិក - កាណាដា

❖ **សៀវភៅដែលផ្សព្វផ្សាយហើយ ៖**

០១. ស្នាព្រះហស្តក្រោយបង្អស់នៃសម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត**
០២. ធម៌នមស្ការព្រះរតនត្រ័យ ពិស្តារ - សង្ខេប
០៣. ប្រស្នា គិហិប្រតិបត្តិពិស្តារ ( ឈឹម ទូច, សុង ស៊ីវ )
០៤. ប្រជុំនានាធម៌សង្វេគ ( ជ័យ ម៉ៃ )
០៥. អានាបាណស្សតិកម្មដ្ឋាន វិបស្សនាបញ្ញាធម្មបរិយាយ ( គង់ ឌឹប )
០៦. ធម្មនិយាម ៣០ និងកំណាព្យផ្សេង ៗ ( ប៊ុត សាវង្ស, ភិក្ខុ សាន សុជា )
០៧. ជីវិតកថា ( ម៉ិញ សាវ៉ាន ) ថ្មី
០៨. ធម្មប្រទីប ( ប្រជុំកងធម៌ យិន វន់ )
០៩. រឿង ព្រះភិក្ខុពនេចរ ( ឱម ណាគ្រី )
១០. រឿង នគរកាយ ( ចាប ពិន )
១១. ច្បាប់គោរពមាតាបិតា ( អ៊ូ ចុង )
១២. នត្ថិធម្មាធិប្បាយ ( ព្រះបិដកធម្ម អ៊ុម ស៊ុម )
១៣. ត្រៃកូដធម៌ ( សុង ស៊ីវ )
១៤. ឱវាទបាតិមោក្ខ ( ចាប ពិន )
១៥. កម្រងកំណាព្យ ( ហ៊ិម ឆាន់ ) ថ្មី

១៦.	ឧបនីយតិសូត្រ ( ព្រះមហាវិរិយបណ្ឌិតោ ប៉ាង ខាត់ )
១៧.	ធម្មទ្វេស ៤ យ៉ាង ( ម៉ិញ សាវ៉ាន ) ថ្មី
១៨.	ធម៌នមស្ការសង្ខេបសម្រាប់យុវវ័យ Khmère-Français ( វ៉ាត ភិរក្ស ) ថ្មី
១៩.	ធម៌នមស្ការសង្ខេបសម្រាប់យុវវ័យ Khmère-Anglais ( វ៉ាត ភិរក្ស ) ថ្មី
២០.	លោកនីតិបករណ៍ ( អ៊ុក ដា )
២១.	មង្គលសូត្រ ៣៨ ប្រការ ( ព្រះវិន័យធរអនុគណ ឯក ញឹម ធម្មិស្សរោ )
២២.	កម្រងកំណាព្យ ភាគ ២ ( ហ៊ុម ឆាន់ ) ថ្មី
២៣.	ព្រះបាទឡាត់ឃោសនាគ ហែម ចៀវ វីរបុរស ( គង់ សម្ភារ )
២៤.	ចំណងដៃឆ្នាំថ្មី ( ម៉ិញ សាវ៉ាន ) ថ្មី
២៥.	ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាសង្ខេប( សម្ដេចព្រះពោធិវង្សហួត តាត )
២៦.	ឱវាទ ៤ «ខ» របស់លោក **លៀវ ហ្វាន**(បកប្រែដោយលោកយាយ ចំរើន ចារូន )
២៧.	គុណមាតាបិតា ( ម៉ិញ សាវ៉ាន ) ថ្មី
២៨.	ទស្សនៈសម្ដេចព្រះសង្ឃរាជ ជួន ណាត ( គង់ សម្ភារ )
២៩.	អភិធម្មបរមត្ថសង្ខេប ( ព្រះគ្រូ. យ៉ាង ផាន់ និង ព្រះមហា. អ៊ុម ប៉ុណ្ណ )
៣០.	កម្រងកំណាព្យ ភាគទី ៣( ហ៊ុម ឆាន់ ) ថ្មី
៣១.	រឿង ព្រះភិក្ខុពនេចរ ភាគ ២ ( ធម្មឃោស - ចំរើន ចារូន )
៣២.	អ្នករូតរាំងននសង្គម ( បណ្ឌិត កែម ឡី )
៣៣.	រឿង ព្រះភិក្ខុពនេចរ ភាគ ៣ ( ធម្មឃោស - ចំរើន ចារូន )
៣៤.	ចតុរារិយសច្ចធម៌ ( ប៉ុស ឆេងអ៊ាង )
៣៥.	កម្រងកំណាព្យភាគទី ៤ ( ហ៊ុម ឆាន់ ) ថ្មី
៣៦.	បដិបត្តិធម៌ គឺការអភិវឌ្ឍជីវិត ( ភិក្ខុ ឃឿន សំណាង ) ថ្មី
៣៧.	កើតទៀតឬទេ ? ( ព្រះមហាវិរិយបណ្ឌិតោ ប៉ាង ខាត់ )
៣៨.	ឃើញធម៌ ឃើញព្រះ ( ភិក្ខុ ឃឿន សំណាង ) ថ្មី
៣៩.	១០ ឆ្នាំប៉ុន្មានដង ? ( ភិក្ខុ ឥន្ទញ្ញាណោ ហ៊ីម គិមសត់ ) ថ្មី
៤០.	វិបរិណាមធម៌ ( ហ៊ុម ឆាន់ ) ថ្មី
៤១.	សំណោរបច្ចិមវ័យ ( ហ៊ុម ឆាន់ ) ថ្មី

៤២. មាគ៌ាជីវិត ( មុិញ សារ៉ាន ) ថ្មី

❖ ចាស CD, DVD, MP3 ដែលផ្សព្វផ្សាយហើយ ៖

០១. ព្រះត្រៃបិដក ភាគទី ១ ដល់ភាគទី ១១០ ( PDF )
០២. ព្រះវិន័យបិដក ភាគទី ១ ដល់ភាគទី ១៣ ( MP3 )
០៣. ព្រះសុត្តន្តបិដក ភាគទី ១៤ ដល់ភាគទី ៣៧ ( MP3 )
០៤. ព្រះសុត្តន្តបិដក ភាគទី ៣៨ ដល់ភាគទី ៦២ ( MP3 )
០៥. ព្រះគុណម៉ែ ( MP3 )
០៦. ព្រះភិក្ខុពនេចរ ( MP3 )
០៧. វិធីសាស្រ្តចំរើនអានាបាណស្សតិកម្មដ្ឋាន ( MP3 )
០៨. ព្រះពុទ្ធដីកា ( MP3 )
០៩. ព្រះសុត្តន្តបិដក ភាគទី ៦៣ ដល់ភាគទី ៧៧ ( MP3 )
១០. អាមិសទាន និង ធម្មទាន ( MP3 )
១១. ៤៨ ធម្មទស្សន៍ ព្រះពុទ្ធសាសនា ( ខ្លឹមសារគួរយល់ដឹង ) ( MP3 )
១២. ព្រះអភិធម្ម ភាគទី ៧៨ ដល់ភាគទី ១១០ ( MP3 )
១៣. ប្រវត្តិមហាឧបាសិកា **វិសាខា** ( DVD )
១៤. ព្រះវេស្សន្តរជាតក ( DVD )
១៥. ទុក្ខសច្ចៈ( DVD ) ៖ ភិក្ខុ **នៅ សាខន**
១៦. សមថវិបស្សនា (MP3) វគ្គទី ១ និងវគ្គទី ២ : មហាវិមលធម្ម **ពិន សែម**
១៧. ភាពយន្តឯកសារ ( DVD ) Angkor Land Of The Gods
១៨. វិធីសាស្រ្តចំរើនអាការៈ ៣២ (MP3) ព្រះមហាវិមលធម្ម **ពិន សែម**
១៩. ព្រះធម្មទេសនានានា (MP3) ព្រះភិក្ខុ **ធឹង ធីម ចន្ទត្ថេរ**
២០. កំណាព្យរូបភាព ភាគទី ១ ( DVD ) ៖ **ហុិម ឆាន់**

២១. ព្រះធម្មទេសនា១០ ថ្ងៃ ( MP3 ) ជាភាសាខ្មែរ និងភាសាបារាំង ៖ លោកអាចារ្យប្រមុខ GOENKA

២២. សម្លេងកំណាព្យរូបភាព ភាគទី២ (DVD)៖ ភិក្ខុវណ្ណគុត្តោ **ស្វាត សារឿម** និង **ហ៊ិម ឆាន់**

២៣. ឱវាទ ៤ «ខ» របស់លោក លៀវ ហ្វាន ៖ **ហ៊ិម ឆាន់**

២៤. សម្លេងព្រះអដ្ឋកថា

២៥. កំណាព្យរូបភាព ភាគទី ៣, ៤, ៥

២៦. គុណមាតាបិតា

២៧. ព្រះភិក្ខុពនេចរ ភាគ ២ ( MP3 )

២៨. សំនៀងកេរ សំណេរខ្ញុំ

២៩. ព្រះភិក្ខុពនេចរ ភាគ ៣ ( MP3 )

៣០. តើមានអ្វីកើតឡើងនៅពេលស្លាប់ ?

៣១. សម្លេងនិទានជាតក ៖ **ហ៊ិម ឆាន់** និង **សាមិត សុភ័ណ**

៣២. រូបភាពប្រជុំនិទានជាតក ( DVD )

៣៣. ព្រះពុទ្ធ ៖ ភាពយន្តឥណ្ឌា

៣៤. វត្តគោរពបូជា ៨ យ៉ាង ( DVD ) ( ភិក្ខុ **នៅ សាខន** )

៣៥. រឿងលីលាវតីភាគទី ១ និងភាគទី ២

៣៦. ការសិក្សាព្រះអភិធម្ម ( **អមរា ទេវី** ) ជម្រុះមន្ទិល ៖ ២២ DVD

៣៧. ការសិក្សាព្រះអភិធម្ម ( **អមរា ទេវី** ) បរិច្ឆេទទី ១ ៖ ២៨ DVD

---

សូមប្រគេន និងជំរាប ដល់ព្រះតេជព្រះគុណព្រមទាំងបងប្អូនពុទ្ធបរិស័ទជាសទ្ធាសម្បន្ន និងសទ្ធាសម្បន្នាទាំងអស់ដែលចង់អាន ឬចង់ស្តាប់នូវព្រះធម៌ណាមួយ ឬក៏មានសទ្ធាជ្រះថ្លាចូលរួមក្នុងការបោះពុម្ពសៀវភៅ និងធ្វើ CD DVD MP3 សម្រាប់ចែកជាធម្មទាន សូមនិមន្ត និងអញ្ជើញទំនាក់ទំនងតាមរយៈ ៖

## គេហដ្ឋាន
## អភិរក្សមរតកព្រះពុទ្ធសាសនាខ្មែរ

ក្រុងម៉ុងរេអាល - កេបិក - កាណាដា


- ឧបាសក **ម៉ិញ សាវ៉ាន** 514 - 735 - 5975
- ឧបាសក **ហ៊ិម ឆាន់** 514 - 277 - 4129

  តាម Facebook Chhann Him ( chhann@live.ca )
- ឧបាសក **វ៉ាត ភិរក្ស** 514 - 894 - 8272

  តាម Facebook Phireak Vat ( phireak.vat@gmail.com )


ម្យ៉ាងទៀតសៀវភៅចាស់ៗ ដែលបានចម្លងថ្មី មានចុះផ្សាយនៅក្នុង

https://www.facebook.com/groups/KhmerBuddhistBookClub

និង http://www.5000-years.org ផងដែរ ។

សូមអស់លោកពុទ្ធបរិស័ទអញ្ជើញអានដោយមេត្រី...